ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៤៦៨**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Dec-2016, 09:42
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| កញ្ញា អង់គា ហ្គីសសេ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក ស្ទីហ្វិន ម័ររីស (2-TCE-98) | អង់គ្លេស |
| លោកស្រី ព្រាប សុឃឿន (2-TCCP-1064) | ខ្មែរ |

# ឧបសម្ព័ន្ធ


**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ស្ទីហ្វិន ម័ររីស** (2-TCE-98)

សួរបន្តដោយលោក នីកូឡាស គូមជែន ផ្តើមពី ........................ ទំព័រ ២

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................ ទំព័រ ១៨

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........................ ទំព័រ ៣០

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ព្រាប សុឃឿន** (2-TCCP-1064)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................ ទំព័រ ៥២

សួរដោយលោក ឡៅ ជុនធី ផ្តើមពី........................ ទំព័រ ៥៥

សួរដោយលោក ពេជ អង្គ ផ្តើមពី ........................ ទំព័រ ៧០

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី........................ ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ ម៉ុរីស បញ្ចប់ ហើយនិងមានត្រៀមនូវដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម 2-TCCP-1064។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះនៃរឿងក្តីនេះមានវត្តមាន។

*(មានបញ្ហាបច្ចេកទេស)*

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ស្ទីហ្វិន ម៉ុរីស លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCCP-1064។ សូមអរគុណលោកប្រធាន។

[០៩:០២:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់ចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ

របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទ២០ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះជាប្រចាំ ហើយកាន់តែឈឺនៅពេលអង្គុយយូរ និងផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:០៨]

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**លោក នីកូឡាស គូមជែន៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក នីកូឡាស គូមជែន៖**

**ស៖** ជម្រាបសួរលោកសាស្ត្រាចារ្យ។ អ្នកជំនាញសូមលោកចាំដល់ពេលមីក្រូមានពណ៌ក្រហមសិន ហើយខ្ញុំនឹងបង្អង់បន្តិចផងដែរ។ ម្សិលមិញនៅពេលដែលយើងបញ្ចប់ការតាំងសំណួរ យើងបាន

សួរអំពីទំនាក់ទំនងរវាងចិន សូវៀត និងវៀតណាម តើទំនាក់ទាំងបីប្រទេសនេះវាប៉ះពាល់ដល់កម្ពុជាយ៉ាងដូចម្ដេច? ខ្ញុំសូមសួរលោកអំពីប្រតិកម្មរបស់ប្រទេសចិន នៅថ្ងៃ២៥ ធ្នូ ៧៨ ពាក់ព័ន្ធទៅនឹងកិច្ចឈ្លានពានមកចូលប្រទេសកម្ពុជា ពីសំណាក់ប្រទេសវៀតណាម។ នៅពេលដែលវៀតណាមក្ដោបក្ដាប់ទីក្រុងភ្នំពេញ នៅថ្ងៃ០៧ មករា ១៩៧៩ តើប្រទេសចិនមានប្រតិកម្មយ៉ាងដូចម្ដេចដែរចំពោះបញ្ហានេះ?

[០៩:០៥:៣៦]

**លោក ស្ទីហ្វិន ម៉ររីស៖**

**ឆ៖** ប្រទេសចិនមានប្រតិកម្មខឹងសម្បារណាស់ ហើយបានបញ្ជូនទ័ពទៅតាមព្រំដែន ហើយចាប់ផ្ដើមធ្វើសង្គ្រាមតូចមួយជាមួយប្រទេសវៀតណាម។

**ស៖** នៅពេលដែលលោកនិយាយថា “សង្គ្រាមតូចមួយ” តើមានអ្វីកើតឡើងនៅក្នុងជម្លោះនេះ?

**ឆ៖** ការវាយប្រយុទ្ធគ្នាហ្នឹង គឺបានកើតមានឡើងនៅភូមិភាគខាងជើងនៃប្រទេសវៀតណាមជាប់ព្រំដែនប្រទេសចិន ហើយចិនបានបញ្ជូនកងទ័ព និងកងកាំភ្លើងធំជាច្រើនដើម្បីកុំឲ្យប្រទេសវៀត-ណាមហ្នឹងបញ្ជូនកងទ័ពទាំងអស់ហ្នឹងចូលមកក្នុងប្រទេសកម្ពុជាបាន។

**ស៖** ខ្ញុំគិតថា <បើលោកគិតថាវា>សមស្រប<> បើសិនជាលោកអាចប្រៀបធៀបបាន តើអាចប្រៀបធៀប ប្រតិកម្មកងទ័ពចិនចូលទៅវៀតណាមចំពោះការឈ្លានពាន<ពីរដង>របស់វៀតណាមនៅចុងឆ្នាំ៧៧ នៅពេលដែលនោះ វៀតណាមបាន<ឈ្លានពានចូលមក ហើយបានដក>ទ័ព<>នៅដំណាច់ឆ្នាំ៧៨<និងការឈ្លានពាននៅចុងឆ្នាំ១៩៧៨ នៅពេលដែលពួកគេបានអុកឡុកប្រទេសកម្ពុជា>? តើលោកអាចប្រៀបធៀបរវាងការបញ្ជូនកងទ័ពចិនទាំងពីរលើកនេះបានទេ វាមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬក៏យ៉ាងណា?

**ឆ៖** ការបញ្ជូនលើកទី១ វាច្រើនជាងការបញ្ជូនលើកទី២ គឺថាគេមានការពាក់ព័ន្ធគ្នាតែនៅខេត្តភាគខាងជើងនៃទឹកដីវៀតណាមប៉ុណ្ណោះ។

[០៩:០៧:៣៥]

**ស៖** តើលោកនិយាយថា គោលបំណងរបស់ចិន គឺចង់បង្រៀនមេរៀនមួយទៅដល់វៀតណាមនិងព្រមានទៅដល់ប្រទេសជិតខាងមួយដែលខ្លួនមានសក្ដានុពលយោធាជាងនោះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ការបង្រៀនមេរៀនដល់ប្រទេសវៀតណាម គឺជាពាក្យមួយដែល តេងស៊ាវពីង បានប្រើប្រាស់ដើម្បីរៀបរាប់ពីឥរិយាបថ ឬក៏ចេតនាមួយចំពោះវៀតណាម មិនមែនមាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បំណងគ្រប់គ្រង ឬត្រួតត្រាប្រទេសវៀតណាមទេ គ្រាន់តែជាការព្រមានវៀតណាមកុំឱ្យបញ្ជូនកងទ័ពមកប្រទេសកម្ពុជា ឬក៏យ៉ាងហោចណាស់ ក៏បង្អាក់អំពីការបញ្ជូនកងទ័ពបន្ថែមមកក្នុងប្រទេសកម្ពុជា។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលពីរបីចំណុចទៅក្នុងនិក្ខេបបទរបស់លោក នៅក្នុងនិក្ខេបបទគឺ E3/10699។ ចំណុចទី១ ដែលខ្ញុំចង់សួរលោកនោះគឺ 01335193 នៃនិក្ខេបបទរបស់លោកនេះដែលលោកបានសរសេរដូចតទៅនេះ៖ “ចន្លោះពីខែមករា ទៅដល់<មេសា>ឆ្នាំ៧៨ ហាណូយបាន<ប្ដូរការហៅរបស់ខ្លួនពី “អាជ្ញាធរកម្ពុជា” ទៅជា> “<>អាជ្ញាធរទីក្រុងភ្នំពេញ។” <ដល់ខែមិថុនា វាបានក្លាយទៅជា>ពួកបនបរិវារ ប៉ុល ពត, អៀង សារី។” <ខ្ញុំចង់ឱ្យលោកមានមតិចំពោះឃ្លានេះ ប៉ុន្តែ>មានចំណុចមួយដែលបានដកស្រង់កាលពីម្សិលមិញ ខ្ញុំសូមលើកឡើងម្តងទៀតគឺ ឌីមីទ្រី នេះគឺ E3/9644, ខ្មែរ ERN 01120075, បារាំង 01125304 ហើយជាភាសាអង់គ្លេស 01085974 ដល់ 75។ “ឡេ យន់ ដែលជាមេដឹកនាំបក្សកុម្មុយនីស្តវៀតណាម នៅក្នុងការសន្ទនាជាមួយនឹងឯកអគ្គរដ្ឋទូតសូវៀតបានហៅ<អ្នក>នយោបាយគាំទ្រទៅដល់វៀតណាម<ថាជាអ្នកដែលមាន>តួនាទីទី២ ដ៏សំខាន់នៅក្នុងបក្ស។” គឺគាត់សំដៅទៅលើ នួន ជា នេះឯង។ វៀតណាមចាត់ទុកថា នួន ជា ជាមនុស្សសំខាន់ទី២នៅក្នុងបក្ស។ តើលោកអាចពន្យល់បានទេថាហេតុអ្វីបានគេប្រើពាក្យថា “បនប៉ុល ពត, អៀង សារី” យ៉ាងដូច្នេះ?

[០៩:១០:៣៦]

**ឆ៖** ប៉ុល ពត និង អៀង សារី នេះជាសាច់ថ្លៃនឹងគ្នា គឺថាប្រពន្ធរបស់ពួកគាត់ទាំងពីរជាបងប្អូនបង្កើតនឹងគ្នា។ ហើយខ្ញុំជឿជាក់ថា វៀតណាមចាត់ទុកពួកគាត់ទាំងពីរជិតដិតនឹងគ្នាខ្លាំង<ជាងភាព>ពាក់ព័ន្ធ<ជាក់ស្តែងរបស់គាត់នៅក្នុង>ឋានានុក្រមនៃអំណាច។ លើសពីនេះទៅទៀត វៀតណាមមិនបានដឹង<ពី> ប៉ុល ពត និង អៀង សារី <នៅ>ក្នុងជួរបក្សឥណ្ឌូចិន<>នៅពេល<>បណ្តុះបណ្តាល <ទេ។> ហើយមិនដឹងថាពួកគាត់ទាំងពីរ<មិនស្ថិតនៅក្នុងថ្នាក់ដឹកនាំកម្ពុជា>ដែល<ត្រូវបានទទួលការបណ្តុះបណ្តាល>នៅឯហាណូយ<ទេ។> ដោយសារតែរឿងមិនដឹងនេះហើយ <គេឱ្យអំណាចទៅអៀង សារី ខុសកម្រិត>។ អ៊ីចឹង អៀង សារី នេះមិនមែនជាមនុស្សដែលសំខាន់ទី២ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជានោះទេ គឺថាគេចាត់ទុកគាត់ថាទាបជាង។ ឯ នួន ជា ហ្នឹងគាត់មានតួនាទី ឬក៏ឋានៈហ្នឹងគឺទី២នៅក្នុងជួរបក្ស។ អ៊ីចឹងវៀតណាមយល់ខុសអំពីឋានានុក្រមនេះ។

**ស៖** បាទ សូមអរគុណ។ សូមបញ្ជាក់ឱ្យបានច្បាស់ពីចំណុចនេះ។ <សម្តីរបស់> មូស្ស៊ីកូហ្វ

*(Mosyakov)* <ដែលខ្ញុំបាន>ដកស្រង់<> គាត់និយាយសំដៅទៅ នួន ជា ថាជាអ្នកទទួលបានតួនាទីសំខាន់ទី២នៅក្នុងជួរបក្ស។ ខ្ញុំបានអានសម្រង់ពីសៀវភៅរបស់លោក បីបួនរួចមកហើយ អំពីការពិចារណារបស់វៀតណាមទៅលើ នួន ជា នោះ ថាមានសមានចិត្តទៅលើវៀតណាម "ហើយជាមនុស្សរបស់យើង" ហើយជាមនុស្សដែលគាំទ្រ<វៀតណាម>។ <អ៊ីចឹង សំណួរមួយទៀតដែលខ្ញុំចង់សួរទៅលោកគឺ> ក្រោយការឈ្លានពាន នៅដើមឆ្នាំ៧៩ ខ្ញុំដឹងថាលោកដឹងថា វៀតណាមបានបើកសវនាការកំបាំងមុខនៅទីក្រុងភ្នំពេញ ដោយមិនមានវត្តមាន ប៉ុល ពត, អៀង សារី ទេ បើសិនជាវៀត-ណាមដឹងថា នួន ជា ជាមនុស្សទី២នៅក្នុងជួរបក្ស ម៉េចក៏មិនបានសម្រេចកាត់ទោសគាត់ផង?

[០៩:១៣:១៥]

**ផ៖** ខ្ញុំមិនដឹងវៀតណាមដឹងថានៅក្នុងរបបនោះ នួន ជា មានឋានៈទី២នោះទេ ហើយដូចដែលខ្ញុំបាននិយាយហើយ វៀតណាមហ្នឹងយល់ច្រឡំពាក់ព័ន្ធទៅនឹងទំនាក់ទំនងអំណាច <ប៉ុល ពត> ជាមួយនឹង អៀង សារី។ មិនមែន<>ថា អៀង សារី <>មិនមានអំណាចទេ គឺមិនមានអំណាចដូច នួន ជា ទៀតផង។

**ស៖** ខ្ញុំសូមឲ្យលោកពិចារណាចំណុចដូចខាងក្រោមនេះ។ នៅពេលនោះ ខ្មែរក្រហមនៅមានកម្លាំងយោធានៅឡើយទេ បើសិនណាវៀតណាមជឿថា មនុស្សរបស់គាត់ដែលមានសមានចិត្តទៅលើវៀតណាមគឺ នួន ជា នេះឯង ចំណុចចុងក្រោយដែលចង់ធ្វើនេះគឺ<ផ្តាច់លទ្ធភាពរបស់> នួន ជា <ដែលអាចឲ្យ>គាត់អាចបំបែកចេញពីក្រុមខ្មែរក្រហម ហើយអាចនឹងចូលទៅចរចាជាមួយវៀតណាម។ តើលោកអាចឆ្លើយតបចំណុចនេះបានទេ?

ក្បាលមីក្រូខ្ញុំបើកទេ ក៏ប៉ុន្តែអ្នកជំនាញឲ្យខ្ញុំសួរម្តងទៀត ខ្ញុំសួរម្តងទៀត។ ខ្ញុំសូមសួរចង់ដឹងអំពីប្រតិកម្មរបស់លោក។ នៅពេលនោះ នៅក្នុងឆ្នាំ១៩៧៩ ខ្មែរក្រហមនៅតែមានអំណាចយោធាវាយប្រយុទ្ធតបទៅជាមួយវៀតណាមវិញនៅឡើយ។ ប្រសិនបើវៀតណាមសង្ឃឹមថា និងរំពឹងប្រកបទៅដោយហេតុផលថា ខ្មែរក្រហមហ្នឹងអាចបាក់បែកពីគ្នា ពេលនោះអាចមានភាគីមួយអាចនឹងសម្របសម្រួល ឬក៏ចុះចូលជាមួយនឹងភាគីវៀតណាម ហើយបើវៀតណាមជឿថា នួន ជា ជាមនុស្សរបស់វៀតណាម ជាអ្នកដែលគាំទ្រ មានសមានចិត្តចំពោះវៀតណាម ប្រហែលជាគេមិនចង់កាត់សេចក្តីគាត់ប្រហារជីវិត ឬក៏ថាអស់មួយជីវិតអ៊ីចឹង ប្រហែលជាអាចនឹងបំបែកគាត់ចេញពី ប៉ុល ពត ហើយ។ តើលោកយល់យ៉ាងណាដែរ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:១៥:២៩]

**ឆ៖** ខ្ញុំគិតថា នេះជាសម្មតិកម្មមួយសមហេតុផល។ អ្វីដែលវៀតណាមគិតអំពី នួន ជា នៅឆ្នាំ ១៩៧៩ ខ្ញុំមិនអាចមានមតិយោបល់អ្វីទេ ព្រោះខ្ញុំគ្មានភស្តុតាងអ្វី ដើម្បីយកមកវិភាគទេ។ សម្រង់ដែលខ្ញុំបានផ្តល់នោះ គឺបានតាំងពីឆ្នាំមុនៗមកម្ល៉េះ គឺមុនការឈ្លានពាន។ សំណួរសួរថា ក្រោយការឈ្លានពានហ្នឹង តើគិតថាអំពី នួន ជា នៅតែជាមនុស្សមួយមានសមានចិត្ត ឬយ៉ាងណានោះ? គឺថាខ្ញុំមិនដឹងទេ។ <អ៊ីចឹងហ្នឹងអាចជាការពន្យល់ម៉្យាងទៀត ពីហេតុអ្វីបានជាពួកគេធ្វើអ្វីដែលពួកគេបានធ្វើហ្នឹង។> ក៏ប៉ុន្តែខ្ញុំសូមសង្កត់ធ្ងន់ថា ការធ្វើមិនដឹងមិនឮរបស់វៀតណាមអំពីថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យនេះ គឺធ្វើឱ្យវៀតណាមគិតថា អំពើប្រល័យពូជសាសន៍នេះ គឺជាអំពើប្រល័យពូជសាសន៍របស់ ប៉ុល ពត ហើយនិង អៀង សារី តែប៉ុណ្ណោះ។

**ស៖** ចំណុចសំខាន់មួយទៀតពាក់ព័ន្ធទៅនឹងប្រជាប្រិយភាព<នៃ>អ្វីដែល សីហនុ ហៅថា <ខ្មែរក្រហមគឺ> "ចលនាកុម្មុយនីស្តនៅក្នុងវៀតណាមមុនរដ្ឋប្រហាររបស់ លន់ នល់ <និងសម្ព័ន្ធភាពជាមួយ>សម្តេច នរោត្តម សីហនុ"។ នៅក្នុងឆ្នាំ១៩៥៥នោះ នៅពេលមានការបោះឆ្នោត តើគេមានការយល់ឃើញដូចម្តេចដែរ?

**ឆ៖** ខ្ញុំនឹងមិនឃើញ<ថា>ការបោះឆ្នោតនៅឆ្នាំ១៩៥៥<ប្រព្រឹត្តទៅបានល្អចំពោះពួកគេ>នោះទេ។ ខ្ញុំមិនគិតថា ពួកគាត់មានប្រជាប្រិយភាពនោះទេ។

**ស៖** ខ្ញុំអានសម្រង់ចេញពីនិក្ខេបបទរបស់លោក។ នេះគឺឯកសារចេញពីឯកសារតែមួយ ERN 01335066 គាត់បានសរសេរថា៖ "ប្រជាជន<បានតិចណាស់> ដោយសារថាបក្សដែលគាំទ្រវៀតណាមឈ្នះតែ<២៩,៥០៩>សំឡេង<ដែលគិតទៅគឺតែបួនភាគរយ>នៃចំនួនសំឡេងឆ្នោតសរុប។" ទី១ ខ្ញុំសួរថាតើ បក្សប្រជាជនហ្នឹងជាបក្សណាដែរ?

[០៩:១៨:២៣]

**ឆ៖** នេះជាបក្សរបស់រណសិរ្ស ដែលគាំទ្រទៅដល់ចលនាកុម្មុយនីស្តវៀតណាម។

**ស៖** តើអ្នកដែលនៅក្នុងបក្សប្រជាជននេះ ក្រោយមកគឺជាអ្នកដែលត្រូវបាន សម្តេច សីហនុ ហៅថា "ខ្មែរក្រហម" នោះឬ?

**ឆ៖** នៅពេលនោះ សីហនុ ហៅខ្មែរក្រហមនោះ គឺថាមិនទាន់បានបង្កើតនៅឡើយទេ។

**ស៖** ហើយអ៊ីចឹង<តើសមាជិក>បក្សនេះ ក្រោយមកចូលរួមចលនាខ្មែរក្រហមនេះឬ?

**ឆ៖** បាទ។

**ស៖** នៅក្នុងពេលមេធាវីសួរលោក គឺ មេធាវីបានសួរលោកទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យជាមួយប្រទេសថៃ។ ហើយថាតើគេមានទំនាក់ទំនង និងមានមូលហេតុអ្វីដែរទេ ចំពោះព្រំដែនពីលិច? សូមបង្ហាញឯកសារមួយចំនួន ទី១ គឺឯកសារ E3/8177។ លោកសាស្ត្រាចារ្យនេះជាសារព័ត៌មានចុះថ្ងៃទី២៣ ធ្នូ ៧៧ របស់កាសែតញូវយ៉កថាមស៍។ ERN គឺអង់គ្លេស <001665991>, ខ្មែរ 00631175 ដល់ 77 ហើយបារាំង 00597761 ដល់62។ នេះគឺជាសារព័ត៌មានស្ដីអំពីដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីថៃមកកាន់ព្រំដែន។

[០៩:២០:៤០]

សូមដកស្រង់៖ “នាយករដ្ឋមន្ត្រី ក្រាំងសាក់ ចាម៉ាណាន់ ដែលអមដំណើរដោយមន្ត្រីជាន់ខ្ពស់យោធា បានចាកចេញថ្ងៃ<នេះ> ធ្វើដំណើរទស្សនកិច្ចមកព្រំដែនកម្ពុជារយៈពេលពីរថ្ងៃ ពាក់ព័ន្ធភាពតានតឹង ប្រយុទ្ធគ្នាតានតឹងនៅព្រំដែន។ ហើយនៅក្នុងឆ្នាំហ្នឹង ថៃចំនួន១៧៣នាក់ រួមមានជនស៊ីវិល ១១៧នាក់ផងដែរ ត្រូវបានរាយការណ៍ថា សម្លាប់ដោយការប្រយុទ្ធពីសំណាក់កម្ពុជា និងដោយសារការដាក់គ្រាប់មីន និងការលបបាញ់ស្នាក់។ ក្នុងនោះមានប្រជាជន២៧២នាក់ រួមមានជនស៊ីវិល១០៧នាក់ បានទទួលរងរបួស។ បន្ថែមលើសនេះទៀត ជនស៊ីវិល៤២ ត្រូវបានគេនាំខ្លួនចូលមកក្នុងប្រទេសកម្ពុជា ដែលយោងទៅតាមប្រភពព័ត៌មានរបស់ថៃដែលគួរឲ្យជឿជាក់បានថា ភាគច្រើនហ្នឹង ក៏ត្រូវបានសម្លាប់ក្រោយពីសួរចម្លើយរួច។” បញ្ចប់ការដកស្រង់។

មកខាងក្រោមនេះ ពីរបីកថាខណ្ឌ៖ “មន្ត្រីថៃនេះគឺ<ឆ្លល់ពី>ភាពតានតឹងក្នុងការវាយប្រយុទ្ធគ្នានៅតាមព្រំដែនថៃ។ ហើយនៅពេលនេះ មានរបាយការណ៍ថា ហើយមានការគួរឲ្យជឿជាក់ <បញ្ជាក់ថា>មានការវាយប្រយុទ្ធគ្នា នៅព្រំដែន<កម្ពុជា>ខាងកើតជាមួយនឹងវៀតណាមផងដែរ នៅពេលជាមួយគ្នានេះ។” បញ្ចប់ការដកស្រង់។

[០៩:២២:១០]

មុនពេលខ្ញុំសួរពីមតិរបស់លោក ខ្ញុំក៏សូមបង្ហាញឯកសារ<មួយ>ទៀតសិន។ នេះគឺជាកាសែតឡូសអេនជេឡេស ចុះថ្ងៃទី២៩ សីហា ឆ្នាំ១៩៧៧។ លោកប្រធាន នេះគឺឯកសារ E3/8272, ERN អង់គ្លេស 0166112, ខ្មែរ 00834835, បារាំង 00822432។ អត្ថបទនេះបានសរសេរដូចតទៅ៖ “កម្ពុជាបាននិយាយថា នៅថ្ងៃចន្ទហ្នឹង កងទ័ពកម្ពុជាបានវាយប្រយុទ្ធជាមួយទ័ពបរទេសនៅតំបន់ចំនួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បួន។ ហើយមានការរាយការណ៍ថា មានការវាយប្រយុទ្ធគ្នានៅ<តាមព្រំដែន>ជាមួយវៀតណាម ឡាវ និងថៃ នោះផងដែរ។ វិទ្យុទីក្រុងភ្នំពេញបានតាមដាន គឺវិទ្យុទីក្រុងភ្នំពេញប្រចាំបាងកកហ្នឹង និយាយថា "សូមឲ្យកងទ័ពរដ្ឋាភិបាលសម្រាប់ការការពារប្រកបទៅដោយវីរភាពរបស់ខ្លួន ប្រឆាំងនឹងកងទ័ពបរទេសនៅភាគខាងជើង ភាគពាយ័ព្យ នៅបូព៌ា និងនៅព្លសាន។ <គេមិនបានបញ្ជាក់ថាខាងណាជាកម្លាំងរបស់បរទេសទេ ប៉ុន្តែ>នាយករដ្ឋមន្ត្រីថៃ ថានីន ខាវវីជិន បាននិយាយថា នៅដើមខែនេះ កម្ពុជា គឺមានឥរិយាបថដូចគោឆ្កួតនៅតាមព្រំដែនជាមួយឡាវ វៀតណាម និង<ថៃ>។" ដូច្នេះដោយពិចារណាទៅដោយវិទ្យុទីក្រុងភ្នំពេញនិយាយអំពីការបាញ់បោះដាក់គ្នានៅតាមព្រំដែន នៅភាគខាងលិច នៅភាគពាយ័ព្យ នៅភាគបូព៌ា និងនៅព្លសាន <និងសម្តីរបស់នាយករដ្ឋមន្ត្រីថៃ> តើលោកមានយោបល់ថា ដូចម្តេចដែរ? ហើយមេធាវីការពារក្តី ក៏បានសួរទៅលោកដែរ ថាតើទំនាក់ទំនង<របស់កម្ពុជាប្រជាធិបតេយ្យ>ជាមួយប្រទេសថៃហ្នឹង នៅតាមព្រំដែនខាងលិចហ្នឹង វាមានលក្ខណៈដូចម្តេចផងដែរ?

**ឆ៖** ខ្ញុំចាត់ទុកថា ឥរិយាបថរបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យគឺថា មានការរើសអើងគ្មានហេតុផល។ ដូចដែលនិយាយអ៊ីចឹងថា គឺហាក់បីដូចជាគោឆ្កួតមួយ គឺថារត់មិនដឹងទិសតំបន់។ គឺថា ប៉ុល ពត ចង់បង្ហាញថា ចង់បង្ហាញទៅដល់ប្រទេសជិតខាងរបស់គាត់ថា បដិវត្តន៍របស់គាត់នេះគឺជាបដិវត្តន៍<កុម្មុយនីស្តដ៏>បរិសុទ្ធ ហើយអាចគំរាមកំហែង ឬក៏ប្រើប្រាស់កម្លាំងបាន។ ខ្ញុំជឿជាក់ថា នេះគឺមិនសមហេតុទេ ពីព្រោះថា មានកម្លាំងយោធាហ្នឹង គឺថាប្រឆាំងទៅនឹងកងទ័ពកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺថាមានអំណាចខ្លាំងជាងណាស់។ ប៉ុន្តែទោះបីជាជម្លោះណាក៏ដោយ <ដែល>ថាកម្ពុជាមានការប្រយុទ្ធប្រឆាំងកម្ពុជាជាមួយវៀតណាមគឺថាមិនមានន័យអីនោះទេ បើប្រៀបធៀបនឹងការប្រយុទ្ធជាមួយនឹងថៃ ហើយនិងឡាវនោះ។ នេះវាខុសពីការពិត ខុសពីការយល់ឃើញការពិតរបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យហើយ។

[០៩:២៦:២២]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសុំចូលទៅសួរលោកអំពីសារទូរលេខមួយចំនួន។ មេធាវីការពារក្តីក៏បានសួរលោកខ្លះមកហើយ អំពីឯកសារសម័យកម្ពុជាប្រជាធិបតេយ្យនោះ <ហើយលោកបញ្ជាក់ថាវាមិនមែនជាផ្នែកមួយនៃការស្រាវជ្រាវរបស់លោកនោះទេ>។ <ដូច្នេះ>ខ្ញុំសុំឲ្យលោកពិចារណា ទី១ គឺឯកសារ E3/243 ជាសារទូរលេខ១៥ ចុះថ្ងៃទី១៩ មករា <១៩៧៨> ពី ឆុន គឺគេជឿជាក់ថាជា សោ ភឹម ហើយដែលបានផ្ញើជូនមក បងប៉ុល ចម្លងជូន អ៊ំនួន, បងវ៉ាន់, បងវ៉ន <និងមន្ទីរ>។ ឯកសារនេះ

មានតែមួយទំព័រទេ គឺឯកសារ E3/243។ សារទូរលេខបានបញ្ជាក់ដូចតទៅនេះ គឺសារទូរលេខមកពីភូមិភាគបូព៌ា៖“យើងបានពួនវាយស្ទាក់នៅ<ដែនដីរបស់វា ចម្ងាយ២គីឡូម៉ែត្រពី>ព្រំដែន<យើង> គឺថាយើងបានកម្ទេចផ្ទះកងទ័ពហ្នឹង៣០ផ្ទះ ហើយដុតផ្ទះជនស៊ីវិលហ្នឹងជាច្រើនផ្ទះ ហើយយើងបានកម្ទេចខ្មាំង ទូករបស់ពួកខ្មាំង<ពីរ>។ ហើយ<>ពួកខ្មាំង<នៅក្នុងទូក>ត្រូវបានកម្ទេចចោលទាំងអស់។ សរុបទៅ គឺថាខ្មាំង៣០នាក់ត្រូវបានកម្ទេចចោលនៅថ្ងៃទី១៨ មករា។ ហើយនៅថ្ងៃទី១៨ មករានេះ នៅម៉ោងបីព្រឹកនេះ យើងបានបន្តបាញ់ផ្លោងអាវុធ១០៧ចូលទៅផ្សារហុកងឺ។ យើងមិនអាចក្តាប់លទ្ធផលនេះ ក៏ប៉ុន្តែយើងឃើញថាផ្សារនេះគឺឆេះ។”

អ៊ីចឹង<នេះជាសារទូរលេខចុះ>នៅថ្ងៃទី១៩ មករា <> ៧៨ <ក្រោយពេលវៀតណាម>ដក<ទ័ព>ចេញ <>នៅពេលដែលចិនចង់បង្រៀនមេរៀនមួយទៅដល់វៀតណាម <ពេលដែលវៀតណាមឈ្លានពាននៅឆ្នាំ១៩៧៧>។

[០៩:២៨:៣០]

សារទូរលេខមួយចុះថ្ងៃទី០៨ មេសា ១៩៧៨ នេះគឺឯកសារ E3/1076។ ឯកសារនេះមានតែមួយទំព័រទេ។ មានអក្សរសរសេរដោយដៃដែលថាចម្លងជូន បងវ៉ាន់ ជាឈ្មោះហៅក្រៅរបស់ អៀង សារី។ កថាខណ្ឌទី១ បានរាយការណ៍ដូចតទៅ៖ “យើងបានវាយប្រយុទ្ធ និងចូលទៅតំបន់ទីប្រជុំជនដុងថាប់ ហើយនិងផ្សារភាគខាងត្បូងត្រពាំងព្រាម ហើយនិងតឹងចូវ។ យើងបានសម្លាប់ ហើយនិងធ្វើឲ្យរងរបួសមនុស្សជាច្រើន ព្រមទាំងបានដុតផ្ទះសម្បែងជាច្រើនចោល។ យើងបន្តបាញ់ផ្លោងអាវុធ១០៧មីល្លីម៉ែត្រ និងដេកា-៧៥ ចូលទៅតឹងចូវ។” បញ្ចប់ការដកស្រង់។

សំណួរដែលខ្ញុំបានសួរលោកពីម្សិលមិញ លោកបានបញ្ជាក់ថា កម្ពុជាបានវាយចូល បន្តវាយចូលទៅក្នុងទឹកដីវៀតណាម ក្រោយពីវៀតណាមបានដកចេញនៅក្នុងឆ្នាំ១៩៧៨។ តើសារទូរលេខមួយនេះ វាជួយគាំទ្រដល់ជំហរបញ្ជាក់អះអាងរបស់លោកដែរទេ?

**ឆ៖** បាទ គឺជួយ។

**ស៖** ហើយតើវាមានផ្តល់ភស្តុតាងទៅដល់លោកថាការវាយប្រយុទ្ធចូលទៅក្នុងទឹកដីវៀតណាមហ្នឹងគឺថាផ្តួចផ្តើមឡើងដោយមេបញ្ជាការមូលដ្ឋាន ឬក៏ថាដោយមានការទទួលបញ្ជាពីថ្នាក់មជ្ឈិមដែរ?

**ឆ៖** នៅក្នុងពេលជម្លោះហ្នឹង គឺថាយើង<>ពិបាកក្នុងការជឿជាក់ដែលថាពួកគេ<ធ្វើសកម្មភាពទាំងអស់ហ្នឹងដោយ>មិនបានរាយការណ៍ទៅមជ្ឈិម ហើយនិង<ដោយ>មិនទទួលបានការយល់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រមពីមជ្ឈិមនោះឡើយ។ វាជាយុទ្ធសាស្ត្រទូទៅដែលគេត្រូវតែរាយការណ៍ទៅមជ្ឈិម។

[០៩:៣០:៣៧]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ មុននឹងខ្ញុំបន្តទៅប្រធានបទចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរលោកនូវសំណួរពីរបីបន្ថែមទៀត ទាក់ទងទៅនឹងតួនាទីរបស់លោកក្នុងបញ្ហានេះ។ លោកបានផ្តល់ចម្លើយទៅដល់មេធាវីការពារក្តីថា លោកបានរិះគន់ទៅដល់ ប៉ែន យៀរនិន ដោយសារតែ ប៉ែន យៀរនិន គាត់បានទទួលស្គាល់យឺត ហើយមិនបាននិយាយឱ្យទាន់ពេលវេលាអំពីអំពើហិង្សានៅក្នុងខ្មែរក្រហម។ <តើមានអ្នកផ្សេងទៀតទេដែល>លោកគិតថា ពួកគេមិនបាននិយាយឱ្យបានទាន់ពេលវេលាអំពីអំពើហិង្សានៅក្នុងរបបខ្មែរក្រហម<>?

**ឆ៖** បាទ ពិតហើយ។ អ្នករាយការណ៍ជាច្រើនដូចជា <ហ្គារេថ ព័រធ័រ និង> ចច ឃីលឌីប្រានដ៍ ជាដើមហ្នឹងគឺបាន<សរសេរសៀវភៅ "កម្ពុជា៖> ភាពអត់ឃ្លាន <ឬក៏បដិវត្តន៍" បោះពុម្ពផ្សាយនៅ> ឆ្នាំ៧៦។ ហើយគេនិយាយ<លើក>អំពីការពិសោធរបស់កម្ពុជាប្រជាធិបតេយ្យ ហើយបានបដិសេធរបាយការណ៍នៃអំពើសាហាវព្រៃផ្សៃនៅកម្ពុជានេះ។ <ក្រោយៗមកទៀត ហ្គារេថ ព័រធ័រ> ក៏បានបដិសេធអំពីរបាយការណ៍<នៃអំពើសាហាវព្រៃផ្សៃនៅក្នុងកម្ពុជាប្រជាធិបតេយ្យ> នៅក្នុងពេលរាយការណ៍ទៅដល់សភា<តំណាងអនុគណៈកម្មការទំនាក់ទំនងបរទេសនៅ>តំបន់<អាស៊ី>ប៉ាស៊ីហ្វិក។ ខ្ញុំគិតថាគេធ្វើរបាយការណ៍នេះក្នុង<ខែមេសា> ឆ្នាំ៧៧។ <អ៊ីចឹងគឺមាន>ពួកគាត់ទាំងពីរនេះ <ហើយក៏មានមនុស្សដូចជា ម៉ាល់ខូម ខាដវែល> ត្រូវបានគេសម្លាប់នៅឆ្នាំ៧៨ <នៅភ្នំពេញ។ ខ្ញុំគិតថា រីឆាដ ឌុដម៉ាន> គឺជាមនុស្សម្នាក់ដែលមកជាមួយ អេលីហ្សាបេត បេកឃ័រ បានន័យថា គេមិនទទួលស្គាល់ឱ្យទាន់ពេលវេលានោះឡើយ។ គឺថា គឺគេនៅតែបន្តគិតថា <រឿងមិនអាក្រក់ដូចគេគិតទេ>។ គឺថាមានមនុស្សជាច្រើននៅខាងឆ្វេងនិយមហ្នឹង គឺមានទាំង ហ្គារេថ ព័រធ័រ ហើយនិង ប៉ែន យៀរនិន ជាដើមហ្នឹង ពួកគាត់ធ្វើការសន្និដ្ឋានខុសអំពីកម្ពុជាប្រជាធិបតេយ្យ គឺទាល់តែដល់ពេលវៀតណាមប្រកាសអំពីអំពើព្រៃផ្សៃចំពោះវៀតណាម ទើបពួកគេទទួលស្គាល់។

**ស៖** ចុះ ស៊ីដនី ស្កេនប៊ឺក ហើយនិងញូវយ៉កថាមស៍វិញ តើយ៉ាងម៉េចដែរ?

[០៩:៣៣:០៩]

**ឆ៖** ចំពោះ ស៊ីដនី ស្កេនប៊ឺក គឺគាត់យឺតយ៉ាវមិនបានរាយការណ៍អំពី -- <នេះនិយាយពីការយល់ឃើញក្នុងឋានៈជាអ្នកយកសារព័ត៌នៅកម្ពុជាក្នុងពេលសង្គ្រាមក្នុងអំឡុងឆ្នាំ ៧០ ដល់ ៧៥> គឺថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនបានយល់អំពីអ្វីដែលខ្មែរក្រហមប្រុងនឹងធ្វើ ប៉ុន្តែគាត់បានរាយការណ៍ ដោយមានភាពត្រឹមត្រូវ សមស្របមួយទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយនិងប៉ុន្មានថ្ងៃក្រោយមកក្រោយការជម្លៀសនោះ។

**ស៖** <>មនុស្សមួយចំនួនគិតថា សក្ខីកម្មរបស់លោកគឺហាក់ដូចជាគាំទ្រទៅដល់រដ្ឋាភិបាល <វៀតណាមជាងកម្ពុជា> ប៉ុន្តែតើលោកមានជំហរជាសាធារណៈបែបណាចំពោះអាមេរិក ហើយនិងអូស្ត្រាលីដែលបានចូលរួមនៅក្នុងសង្គ្រាមវៀតណាម? ថាតើលោកអាចពន្យល់អំពីគោលជំហរជាសាធារណៈរបស់លោកចំពោះការចូលរួមរបស់អាមេរិក និងអូស្ត្រាលីនៅសង្គ្រាមវៀតណាមទេ?

**ឆ៖** ខ្ញុំគាំទ្រការធ្វើអន្តរាគមន៍របស់អាមេរិកនិងអូស្ត្រាលី<នៅវៀតណាម> គឺខ្ញុំគាំទ្រជាសា-ធារណៈ។ ហើយខ្ញុំជឿជាក់ថាជម្លោះមួយនេះ គឺជាជម្លោះយុទ្ធសាស្ត្រ ទោះបីថាវាមិនមែនជាការយល់ឃើញដែលមានការគាំទ្រច្រើនក៏ដោយ ប៉ុន្តែខ្ញុំគិតថាការអន្តរាគមន៍ហ្នឹង ជាការអន្តរាគមន៍ប្រកបដោយយុទ្ធសាស្ត្រ។ ដូច្នេះអ្វីដែលកើតឡើងនៅបច្ចុប្បន្ននេះ គឺវាមិនពាក់ព័ន្ធនឹងអ្វីកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ៦០នោះឡើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទមួយទៀត ទាក់ទងនឹងខ្មែរក្រហម គឺសកម្មភាពរបស់ខ្មែរក្រហមប្រឆាំងជនជាតិវៀតណាម។ ដំបូងខ្ញុំសូមដកស្រង់សៀវភៅរបស់ ណាយ៉ាន់ ចាន់ដា គឺE3/2376, អង់គ្លេសមានលេខ 00192271, បារាំងមានលេខ 00236981, ខ្មែរមានលេខ 00191401 ដល់ 02។ ខ្ញុំគិតថា លោកបានអានសៀវភៅរបស់ ចាន់ដា រួចហើយ ប៉ុន្តែខ្ញុំអាចថា លោកមិនចាំអំពីទំព័រនេះ ប៉ុន្តែក្នុងទំព័រនេះ គាត់សម្ភាសជាមួយមនុស្សម្នាក់នៅឆ្នាំ៨១ គឺសម្ភាសជាមួយបុរសម្នាក់ឈ្មោះ រស់ សារិន ជាជាងនៅយានដ្ឋាន។

[០៩:៣៦:០៤]

គាត់និយាយថា រស់ សារិន បានប្រាប់គាត់ថា៖ “គឺនៅដើម<>ឆ្នាំ៧៧ នៅឧដុង្គ ក្នុងពេលដែលរង់ចាំមេស្រុកខ្មែរក្រហមមកដល់ ដើម្បីណែនាំគាត់អំពីឡានណាដែលត្រូវជួសជុលនោះ គឺថាគាត់ងាកករបស់គាត់ ហើយគាត់ឃើញលិខិតនៅលើតុមួយ ដែលសរសេរថា បញ្ជាពី៨៧០ គឺលិខិតនោះ ចុះថ្ងៃទី០១ មេសា ឆ្នាំ១៩៧៧។” ហើយចាន់ដា និយាយថា៖ “ការបញ្ជាហ្នឹងគឺច្បាស់ណាស់ គឺថាជនជាតិវៀតណាមទាំងអស់នៅក្នុងស្រុក ហើយនិងខ្មែរទាំងអស់ដែលចេះភាសាវៀតណាម ឬក៏មានមិត្តភក្តិជាវៀត-ណាម ហ្នឹងគួរត្រូវប្រគល់ទៅសន្តិសុខរបស់រដ្ឋ។”

មុននឹងខ្ញុំឲ្យលោកបញ្ចេញមតិទៅលើចំណុចនេះ ខ្ញុំក៏ចង់អានទូវប្រតិចារឹកនៃសក្ខីកម្មនៅក្នុងតុលាការនេះ គឺនៅដើមឆ្នាំនេះ គឺនៅថ្ងៃ០២ កុម្ភៈ ឆ្នាំ២០១៦ គឺជាប្រតិចារឹក E1/386.1 គឺជាការសន្ទនាដែលខ្ញុំ គឺនៅនាទី១៥:៥៧:៣០វិនាទី គឺសាក្សី មាស វឿន។ ត្រូវបានគេសួរថា៖ “តើលោកធ្លាប់ឮថាមានផែនការកម្ទេចវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ទេ?” ខ្ញុំគួរបញ្ជាក់ប្រាប់លោកថា មាស វឿន គឺជាមេបញ្ជាការមួយ គឺជាមេបញ្ជាការ<កងពល>របស់ខ្មែរក្រហម។ គាត់ឆ្លើយថា៖ “បាទ ខ្ញុំធ្លាប់ឮអំពីផែនការនេះ។ ខ្ញុំឮអំពីជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ គាត់និយាយថា ដំបូងចាប់ពីឆ្នាំ១៩៧០ ពួកគាត់ត្រូវបានគេបញ្ជូនត្រឡប់ទៅប្រទេសរបស់គេដោយរដ្ឋាភិបាលកម្ពុជា ហើយបន្តរហូតដល់ឆ្នាំ៧៥។ ប៉ុន្តែបន្ទាប់ពីនោះមក គឺថាគេបញ្ជាឲ្យយើងថា ត្រូវកម្ទេចវៀតណាម ពីព្រោះវៀតណាមទាំងអស់នោះ មិនត្រឡប់ទៅប្រទេសរបស់ពួកគេ។ បន្ទាប់មកទៀត មានការប៉ះទង្គិចនៅតាមព្រំដែនដោយសារតែបញ្ហានេះ។ នេះគឺជាអ្វីដែលខ្ញុំបានឮ។” អ្នកជំនាញ ខ្ញុំចង់សួរលោកថា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

មួយណា ឥឡូវមួយណាមុន? វ៉ិចទ័រ កូប៉េ មុន។

[០៩:៣៨:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អរគុណលោកប្រធាន។ ពួកយើងងើបឈរឡើងប្រហែលគ្នា ខ្ញុំមិនដឹងថា យើងជំទាស់ដូចគ្នា ឬក៏ខុសគ្នាទេ។ ប៉ុន្តែអ្វីក៏ដោយ គឺថាចាំបាច់ត្រូវតែសួរនូវសំណួរបើក ជាជាងការដែលនាំមុខសាក្សី ឬក៏អ្នកជំនាញឲ្យឆ្លើយទៅតាមអ្វីដែលព្រះរាជអាជ្ញាចង់បានបែបនេះ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេ៖**

លើសពីហ្នឹងទៅទៀត គឺខ្ញុំចាំណាស់ពីសាក្សីរូបនេះ ព្រោះថា ខ្ញុំបានសួរផ្ទួញគាត់កាលនោះ ខ្ញុំក៏ចាំផងដែរថា ថ្ងៃបន្ទាប់មកទៀតនោះ ក្នុងពេលខ្ញុំសួរផ្ទួញដែរ ហើយនៅពេលដែលគាត់ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាគឺ វ៉ាំងសង់ ដឺវីល កាលថ្ងៃនោះៗ សាក្សីរូបនេះ គាត់បានកែប្រែចម្លើយរបស់គាត់។ អ៊ីចឹងដើម្បីគ្រប់ជ្រុងជ្រោយ ឲ្យពេញលេញ កាលណាយើងផ្តល់ឯកសារមួយ ចម្លើយមួយទៅនឹងអ្នក

ជំនាញនេះ សូមធ្វើយ៉ាងម៉េចឲ្យឯកសារទាំងមូលទៅគាត់តែម្តងទៅ។ ក្រុមរបស់ខ្ញុំកំពុងតែរកឯកសារហ្នឹងហើយ។ អ៊ីចឹងគួរតែផ្តល់ឯកសារទាំងស្រុងតែម្តងទៅគាត់ ដើម្បីកុំឲ្យនាំមុខអ្នកជំនាញរូបនេះ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា សក្ខីកម្មរបស់ មាស វឿន ច្បាស់ណាស់ ប៉ុន្តែមេធាវីការពារក្តីចង់លើកនូវផ្នែកបន្តិចទៀតរបស់សក្ខីកម្មនេះ ខ្ញុំគិតថាគាត់មានឱកាសនឹងធ្វើបាន ហើយគាត់អាចធ្វើបាន។ <ឆ្លើយតបទៅនឹងការជំទាស់ទី១> គឺថាខ្ញុំចង់បញ្ជាក់ថានេះជាអ្នកជំនាញ ដូច្នេះខ្ញុំអត់ទាន់បានសួរសំណួរណាមួយដែលបង្ហាញថាខ្ញុំនាំមុខនោះឡើយ ប៉ុន្តែគាត់មានសិទ្ធិបញ្ចេញមតិយោបល់ក្នុងនាមជាអ្នកជំនាញ។ ហើយខ្ញុំគិតថាមេធាវីការពារក្តី ក៏ធ្លាប់បែបនេះដែរ ដាក់នូវព័ត៌មានចំពោះមុខគាត់ ហើយៗសួរគាត់ ខ្ញុំកំពុងតែធ្វើដូចគ្នានេះឯង។ ខ្ញុំគិតថាប្រហែលជាមេធាវីការពារក្តីយល់ច្រឡំអំពីតួនាទីរបស់អ្នកជំនាញ និងអ្វីដែលខ្ញុំគ្រោងនឹងសួរហើយមើលទៅ។

[០៩:៤១:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

ឥឡូវនេះ ខ្ញុំរកឯកសារយោងនេះឃើញហើយ ខ្ញុំអាចផ្តល់ជូនអង្គជំនុំជម្រះបាន គឺសាក្សីដដែលកាលពីសវនាការនៅថ្ងៃទី០៣ ខែកុម្ភៈ។

**លោក នីកូឡាស គូមជែន៖**

មេធាវី ខៀវ សំផន មានឱកាសធ្វើបាន ហេតុអីក៏មិនរង់ចាំដល់វេនគាត់ធ្វើទៅ។ <ម៉េចក៏មកតវ៉ាអីឥឡូវហ្នឹង?> អានេះមិនមែនជាការជំទាស់ទេ វាជាទៅជារឿងការពារក្តីខ្លួនគាត់ទៅវិញទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាអ្វីដែលព្រះរាជអាជ្ញាតែងតែធ្វើ<អ៊ីចឹង>ដាក់យើងដូចគ្នា <ហើយរួចខ្លួនរហូត> ហើយយើងខ្ញុំបានសួរនូវសាក្សីជាអ្នកជំនាញនូវសំណួរបើក ហើយបន្ទាប់មកទៀតបានយើងសួរដេញដោលនូវសំណួរទាំងអស់នេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បានហើយ! បានហើយ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅបន្ត! បន្តការតាំងសំណួរលោកសហព្រះរាជអាជ្ញាអន្តរជាតិ។

[០៩:៤១:៤៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោកប្រធាន។ អ្វីដែលខ្ញុំចង់សួរគឺថា ខ្ញុំគិតថានៅពេលមេធាវីការពារក្តីបានស្តាប់ឮសំណួរខ្ញុំ គាត់ដឹងច្បាស់ថាខ្ញុំនឹងមិនផ្អែកទៅលើអ្វីដែលខ្ញុំអាននេះទេ គឺថាខ្ញុំផ្អែកទៅលើការស្រាវជ្រាវរបស់លោក។ គឺថាភស្តុតាងដែលខ្ញុំបង្ហាញនេះគឺបានន័យថា ខ្មែរក្រហមគឺផ្តោតគោលដៅទៅលើវៀតណាម ហើយនិងជនជាតិវៀតណាម<នៅក្នុងប្រទេសកម្ពុជា> គឺនិយាយ ថាតើព័ត៌មានហ្នឹងដឹងដល់អាជ្ញាធររបស់វៀតណាមទេ?

**លោក ស្ទីហ្វិន ម៉ររីស៖**

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** តើមានរបាយការណ៍សារព័ត៌មានអ្វីដែលរាយការណ៍ថា ជនជាតិវៀតណាមត្រូវបានគេកំណត់គោលដៅនៅកម្ពុជាអ្វីដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងថា មានរបាយការណ៍ ឬក៏មានសេចក្តីរាយការណ៍ព័ត៌មានអ្វីនោះទេ ទោះបីបើមាន ក៏ខ្ញុំអត់ចាំដែរ។

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវសម្រង់មួយចំនួនទៀតគឺជា ទី១ គឺសម្រង់នៅក្នុងសៀវភៅរបស់លោក ទំព័រ១០៤គឺ ERN មានលេខ 01001771។ លោកបាននិយាយអំពីអ្វីដែលខ្មែរក្រហមបាននិយាយ ទាក់ទងទៅនឹងការយកជ័យជម្នះលើវៀតណាមនៅក្នុងឆ្នាំ៧៧។ លោកបាននិយាយថា៖ "ការអះអាងថា បានសម្រេចត្រឹមតែ១ភាគ៣០នៃការបាត់បង់របស់ជនជាតិវៀតណាមហ្នឹង គឺជារឿងប្រឌិតទាំងស្រុង។ ប៉ុន្តែយោងទៅតាមតក្កវិជ្ជានៃរូបមន្តផ្លូវការបច្ចុប្បន្ននេះ ទស្សនៈរបស់កម្ពុជាប្រជាធិបតេយ្យ គឺវាមានភាពភ្លឺស្វាងនៅក្នុងអនាគត ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធជាមួយវៀតណាម។"

[០៩:៤៤:០១]

ហើយលោកបានដកស្រង់នូវវិទ្យុភ្នំពេញ នៅថ្ងៃទី១០ ឧសភា ឆ្នាំ៧៨។ លោកបាននិយាយអំពីការផ្សព្វផ្សាយរបស់វិទ្យុនេះ៖ "ការប្រើប្រាស់រូបភាពទិន្នន័យទាំងអស់នេះ ទាហានកម្ពុជាម្នាក់គឺស្មើនឹងទាហានវៀតណាម៣០នាក់ ប្រសិនបើយើងមានទាហាន២លាន ពេលនុំងគឺត្រូវមានទាហានវៀតណាម៦០លានដែរ។ ដោយសារហេតុផលទាំងអស់នេះ ទាហាន២លានគួរតែគ្រប់គ្រាន់ដើម្បីវាយប្រហារ

ជាមួយវៀតណាម ព្រោះវៀតណាមមានប្រជាជនត្រឹមតែ៥០លានប៉ុណ្ណោះ។ យើងមិនត្រូវការដល់ ៨លាននោះទេ យើងត្រូវការត្រឹមតែទាហាន២លាននាក់ដើម្បីកម្ទេចពួកវៀតណាម៥០លាននាក់ ហើយ យើងនៅសល់ប្រជាជន៦លាននាក់ទៀត”។

ហើយនិងឯកសារមួយទៀតដែលខ្ញុំចង់ឲ្យលោកចាប់អារម្មណ៍ ផ្តោតអារម្មណ៍ផងដែរគឺឯកសារ <E3/4640> គឺជាទស្សនាវដ្តីទង់បដិវត្ត ខែមេសា ឆ្នាំ៧៨ គឺជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ។ ERN ជាភាសាអង់គ្លេសមានលេខ 00519833 ដល់ទំព័របន្ទាប់, ខ្មែរមានលេខ 00064713 និងបារាំង មានលេខ 00520344។ គឺឯកសារនេះ គឺឯកសារខែមេសា ៧៨ ជាទស្សនាវដ្តីទង់បដិវត្តនេះ បាន សរសេរថា គឺនិយាយអំពីសុន្ទរកថារបស់ ប៉ុល ពត ក្នុងខួបលើកទី៣ ថ្ងៃជ័យជម្នះ ១៧ មេសា។ គឺ សុន្ទរកថានេះបាននិយាយដូចតទៅនេះ៖ “ប្រហែលជាមានទស្សនថាយួនគឺធំ ហើយយួនមានប្រជាជន ៥០លាននាក់ ហើយកម្ពុជាមានប្រជាជនត្រឹមតែ៨លាន។ ដូច្នេះតើយើងឈ្នះដោយរបៀបណា? គឺវា ពិបាក ដោយសារតែពួកយួនមានទាហានប្រហែល១លាននាក់ ចំណែកទាហានរបស់យើងមានតិចជាង ១សែននាក់ទេ។ ដូច្នេះតើ៨លានវ៉ៃជាមួយពួកឈ្លានពាន៥០លាននាក់ដោយរបៀបណា? ហើយគាត់បាន និយាយថា បក្សសម្រេចថាកម្ទេច ហើយនិងវ៉ៃជាមួយនឹងកងកម្លាំងដែលមានទំហំធំ ហើយនិងការពារ កម្លាំងរបស់យើងជាអតិបរិមា គឺមានពាក្យស្លោករបស់យើង ប្រសិនបើយើងមើលទៅលើចំនួន គឺថាខ្មែរ ម្នាក់វ៉ៃយួន៣០នាក់។ ប្រសិនបើយើងអនុវត្តនូវពាក្យស្លោកនេះបាន យើងឈ្នះ។ <អ៊ីចឹងនៅពេល ដែល>យើងមានប្រជាជន២លាន ដូច្នេះយើងមានកម្លាំងលើសពីអ្វីដែលយើងត្រូវវ៉ៃ។ យើងមិនចាំបាច់ ត្រូវការដល់៨លាននោះទេ យើងប្រើប្រាស់កម្លាំងតែ២លាននាក់ដើម្បីវ៉ៃកម្ទេចយួន <ព្រោះពួកវាមានតែ ៥០លានប៉ុណ្ណោះ។> ហើយយើង<មិនត្រូវការប្រើប្រាស់កម្លាំង>៨លាននាក់ទៀត <យើងប្រើតែកម្លាំង ២លាននាក់ហ្នឹង ដើម្បីវ៉ៃកម្ទេចយួន៥០លាននាក់ ហើយយើង>នៅសល់ប្រជាជន៦លាននាក់ទៀត។”

ដូច្នេះខ្ញុំ<សុំឲ្យ>លោក<មានមតិចំពោះ>សេចក្តីថ្លែងការណ៍ ឬក៏សុន្ទរកថារបស់កម្ពុជាប្រជា ធិបតេយ្យដែលនិយាយថា សុខចិត្តលះបង់ប្រជាជន២លាននាក់ ដើម្បីកម្ទេចយួន៥០លាននាក់នោះទេ?

[០៩:៤៧:២៨]

**ឆ៖** ខ្ញុំគិតថា ការគណនាដែលគេប្រើប្រាស់នេះ គឺជាការស្រមើស្រមៃទាក់ទងទៅនឹងចំនួន មនុស្សដែលបានសម្លាប់<ម្តងៗក្នុងពេលជម្លោះ> គឺវាគ្រាន់តែជាការស្រមើស្រមៃដ៏ងងើល វាមិនមាន លក្ខណៈជាការពិតអ្វីទាល់តែសោះ។ វាអាចមានភាពប្រហាក់ប្រហែលទៅនឹងប្រធាន ម៉ៅ ដែល

និយាយអំពីសង្គ្រាមនុយក្លេអ៊ែ ឬក៏សង្គ្រាមបរិមាណូ ដែលគាត់គ្រោងនឹងធ្វើនោះ<ថា បើទោះជាមានសង្គ្រាមនុយក្លេអ៊ែ ចិនក៏នៅតែឈានមុខគេដែរព្រោះចិនមានប្រជាជនច្រើនទៀត>។ ប៉ុន្តែនេះវាគ្រាន់តែជាការគណនាដែលមិនមានអ្វីជាការពិតនោះ។ ខ្ញុំគិតថា នៅក្នុងសេចក្តីថ្លែងការណ៍នេះ គឺមិនមានអ្វីទាក់ទងទៅនឹងស្ថានភាពពិតប្រាកដនោះឡើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំមានសំណួរមួយទៀតនៅសល់ ដែលខ្ញុំទាក់ទងទៅនឹងការដកស្រង់ទាក់ទងទៅនឹងការកម្ទេចយួន។ នៅក្នុងឯកសាររបស់លោកគឺ <E3/10699> <នៅត្រង់ទំព័រ 01335066> គឺលោកបានសរសេរដូចតទៅនេះ៖ "<និស្សិត>ខ្មែរវ៉ាឌីកាល់បានរិះគន់<ប្រជាជនខ្មែរដែល>ប្រើប្រាស់ពាក្យយួន ដើម្បីសំដៅទៅលើវៀតណាម។" តើវាជាការត្រឹមត្រូវទេ ដែលការស្រាវជ្រាវបានបង្ហាញថា ខ្មែររ៉ាឌីកាល់ឆ្វេងនិយម រិះគន់ការប្រើប្រាស់ពាក្យថា"យួន" ដែលជាពាក្យប្រមាថមើលងាយចំពោះវៀតណាមនោះ?

**ឆ៖** បាទគឺពិតហើយ គឺមានការយោងទៅលើប្រភពព័ត៌មានរបស់ខ្ញុំ ដែលជានិស្សិតមួយរូប <ដែលរៀនជាមួយមេដឹកនាំខ្មែរក្រហមខ្លះ> គឺគាត់ជានិស្សិតរៀននៅប្រទេសបារាំងក្នុងឆ្នាំ១៩៥០ ប្រហែលជានៅចុងទសវត្សរ៍៤០ ឬក៏ដើមទសវត្សរ៍ឆ្នាំ៥០។ នៅពេលនេះ គឺថានិស្សិតរ៉ាឌីកាល់ឆ្វេងនិយម គឺគេហាក់ដូចជាមានសមានចិត្តជាមួយវៀតណាម ហើយគេគាំទ្រវៀតណាម ហើយគេមិនដែលគិតថា វៀតណាមជាខ្មាំងទេនៅពេលនោះ។ ហេតុដូច្នេះហើយ ទើបគេមិនចង់ប្រើប្រាស់ពាក្យប្រមាថមើលងាយហៅថា "យួន" នោះទេ។

[០៩:៤៩:៥៧]

**ស៖** ខ្ញុំចង់សួរនូវផ្នែកមួយទៀតនៅក្នុងសៀវភៅរបស់លោក គឺអង់គ្លេសមានលេខ <01001707> គឺនៅប្រធានបទដដែល ទាក់ទងទៅនឹងទំនាក់ទំនងកម្ពុជាជាមួយនឹងវៀតណាម។ ហើយនៅត្រង់ចំណុចនេះ លោកនិយាយអំពីអ្វីដែលសម្តេច សីហនុ បានសរសេរនៅក្នុងសៀវភៅរបស់គាត់។ លោកបាននិយាយថា៖ "សម្តេច សីហនុ បានទទួលស្គាល់ថា ប្រជាជនកម្ពុជាភាគច្រើន<ស្អប់>វៀតណាម<ណាស់>ហើយពួកគេអាចនឹង<យក>ទឹកដីមួយចំនួន<ដែលបានបាត់បង់មកវិញ"។ ប៉ុន្តែគាត់ប្រើរបៀបផ្សេងវិញ សូមដកស្រង់៖> "ប៉ុន្តែក្នុងទំនាក់ទំនងរបស់ខ្ញុំជាមួយវៀតណាម ខ្ញុំតែងតែអនុវត្តនូវអាកប្បកិរិយាសមស្រប ហើយខ្ញុំគិតថា<ឋានសួគ៌បានធ្វើឲ្យ>ពួកគាត់ជាអ្នកជិតខាងរបស់ខ្ញុំ<ជានិរន្តរ។> ក្នុងឆ្នាំ៦០ <ប្រជាជនគេបានកើនឡើងនៅខាងជើង និងខាងត្បូងរហូតជិតដល់៥០លាន គឺលើស

ប្រជាជនកម្ពុជាដល់ទៅ៥០ដងនៅពេលនោះ។> ទោះបីយ៉ាងណាក៏ដោយ ពួកគាត់គឺ<>ជាអ្នកជិតខាងដ៏គ្រោះថ្នាក់បំផុត <ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ក្នុងពេលធ្វើការទំនាក់ទំនងគ្នា>។" ថាតើលោកយល់យ៉ាងណាដែរ ចំពោះអ្វីដែលសម្តេច សីហនុ បានសរសេរនេះ?

**ឆ៖** ខ្ញុំគិតថា សម្តេច សីហនុ ហាក់ដូចជាខ្លាំងក្លាបន្តិច ទាក់ទងទៅនឹងអ្វីដែលគាត់និយាយអំពីវៀតណាម ដែលគាត់សរសេរថា ដែលគាត់បារម្ភអំពីវៀតណាម។ ប៉ុន្តែពេលក្នុងពេលជាមួយគ្នានេះគាត់បែរនិយាយថា ត្រូវប្រុងប្រយ័ត្ន ដោយមិនត្រូវបង្ករឿងជាមួយវៀតណាម មិនត្រូវឲ្យវៀតណាមបង្ករឿងជាមួយកម្ពុជា។ ប៉ុន្តែក្នុងពេលជាមួយគ្នាហ្នឹង កម្ពុជាប្រជាធិបតេយ្យដែលជាអ្នកបន្តវេនពីព្រះអង្គក្នុងឆ្នាំ៧៥ហ្នឹង <ដោយសារតែមនោគមន៍វិជ្ជារបស់ពួកគេៗ>បែរជាធ្វើរឿងមួយដែលមិនសមស្រប ឬក៏ធ្វើរឿងមួយដែលថាជាបដិវត្តសុទ្ធសាធនោះទៅវិញ។ ខ្ញុំគិតថា ដំណើរការទូទៅ គឺវាមិនសមស្របនៅក្នុងនយោបាយអន្តរជាតិទូទៅ ដែលយកមកធ្វើនៅក្នុងប្រទេសកម្ពុជា។ គឺថាដោយសារតែ<ពួកកុម្មុយនីស្ត>កម្ពុជាគិតថា ខ្លួនឯងនោះខ្លាំងក្លាជាងគេ <គិតថាបដិវត្តន៍របស់ខ្លួន>អស្ចារ្យជាងគេអស្ចារ្យជាងវៀតណាម អស្ចារ្យជាងអ្វីទៅទៀត។ ដូច្នេះអ្វីដែលកម្ពុជាប្រជាធិបតេយ្យធ្វើ គឺមនុស្សទូទៅគិតថា មិនមែនជារឿងប្រាកដនិយមឡើយ។ ដូច្នេះចំពោះ<ការដឹកនាំរបស់>កម្ពុជា<ប្រជាធិបតេយ្យ>វិញ ខ្ញុំគិតថា ដោយសារតែមនោគមន៍វិជ្ជា ហើយនិងការយល់ខុសអំពីកម្លាំងរបស់ខ្លួន ទើបកម្ពុជាប្រជាធិបតេយ្យមិនយល់ឃើញដូចសម្តេចព្រះបរមរតនកោដ្ឋ។

[០៩:៥៣:០៤]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ ឥឡូវនេះខ្ញុំមានសំណួរចុងក្រោយ ក្នុងរយៈ៣ថ្ងៃកន្លងមកដែលយើងនិយាយអំពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យចំពោះវៀតណាមវិញ ហើយនិងចំពោះជនស៊ីវិលវៀតណាមនៅក្នុងកម្ពុជា ក៏ដូចនៅប្រទេសវៀតណាមដែរ ក្នុងទស្សនៈលោកជាអ្នកជំនាញថាតើគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង វាមានឥទ្ធិពលអ្វីចំពោះជាតិកម្ពុជា ចំពោះប្រទេសមួយដែលមានបូរណភាពទឹកដី និងមានឯករាជ្យភាព តើវាមានផលប៉ះពេលអ្វីដល់កម្ពុជា?

**ឆ៖** ខ្ញុំជឿជាក់ថា គោលនយោបាយ និងអាកប្បកិរិយានេះ រួមចំណែកដល់ការឈ្លានពាន និងការគ្រប់គ្រងរបស់វៀតណាមមកលើកម្ពុជា។ ដូចដែលខ្ញុំបង្ហាញនៅក្នុងសៀវភៅរបស់ខ្ញុំអ៊ីចឹង វៀត-ណាមតែងតែចង់បាននូវការគ្រប់គ្រងទៅលើខាងកិច្ចការរបស់កម្ពុជា ប៉ុន្តែគេត្រូវកែសម្រួលនូវយុទ្ធ-សាស្ត្ររបស់គេ ចាប់ពីឆ្នាំ៧៥។ ប៉ុន្តែអ្វីដែលជាគោលនយោបាយរបស់ ប៉ុល ពត បានធ្វើពាក់ព័ន្ធទៅនឹង

វៀតណាមនោះ គឺហាក់ដូចជាផ្តល់នូវអាជ្ញាប័ណ្ណដល់វៀតណាម ដើម្បីឲ្យវៀតណាមមានសិទ្ធិគ្រប់គ្រាន់មកឈ្លានពាន គ្រប់គ្រងកម្ពុជា និងលុបបំបាត់នូវឯករាជ្យភាពរបស់កម្ពុជា។

[០៩:៥៤:៣២]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកអ្នកជំនាញ។ លោកប្រធាន អង្គជំនុំជម្រះទាំងមូល ខ្ញុំសូមបញ្ចប់ការសាកសួររបស់ខ្ញុំ ហើយខ្ញុំសូមប្រគល់វេទិកាជូនទៅសហការីរបស់ខ្ញុំ គឺសហមេធាវីនាំមុខ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកអ្នកជំនាញ ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំតំណាងឲ្យក្រុមជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំជាមួយលោកមេធាវី ពេជ អង្គ តំណាងឲ្យពួកគាត់។ លោកបាននិយាយរឿងរ៉ាវជាច្រើនមកហើយនៅក្នុងអំឡុងរយៈពេល៣ថ្ងៃមកនេះ។ ដូច្នេះខ្ញុំចង់សួរបញ្ជាក់លោកមួយចំនួន។ បើលោកមានអារម្មណ៍ថា លោកបានឆ្លើយគ្រប់ជ្រុងជ្រោយទៅនឹងសំណួររបស់ខ្ញុំរួមមកហើយ លោកអាចប្រាប់ខ្ញុំបាន។

[០៩:៥៥:៣៥]

ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធនឹងវប្បធម៌នយោបាយនៃរបប ម៉ាក្ស-ឡេនីន និយម។ ដូចដែលលោកបានជម្រាបក្នុងរយៈពេលពីរបីថ្ងៃមកនេះ លោកថាភាពភ័យខ្លាច ឬក៏ជំងឺត្រដេវរិចនេះគឺជាចំណុចស្នូល។ ដូច្នេះខ្ញុំចង់សួរលោកអ្វីដែលលោកថា “ម៉ៅជ្រុលនិយម” ហើយនិងផលប៉ះពាល់នៃម៉ៅជ្រុលនិយមនេះ ទៅលើកម្ពុជានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ជាដំបូងខ្ញុំសូមចាប់ផ្តើមសួរលោកពាក់ព័ន្ធនឹងវិសាលភាពនៃវប្បធម៌នយោបាយរបស់របប ម៉ាក្ស-ឡេនីន និយម ដែលបង្ហាញនូវនិន្នាការនៃការភ័យខ្លាចស្រមោលខ្លួនឯង។ ខ្ញុំយល់ត្រូវ មិនត្រូវទេ កាលពីម្សិលមិញនេះលោកចាត់ទុកបក្សកុម្មុយ-

នីស្តកម្ពុជាហ្នឹងដូចគ្នាអ៊ីចឹងដែរ គឺថា ពួកគាត់តែងតែមានភាពភ័យខ្លាចនូវស្រមោលរបស់ខ្លួនឯងនោះ?

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** បាទ គឺលោកស្រីយល់ច្បាស់ហើយគឺថា ពួកគេហាក់ដូចជាខ្លាចស្រមោលខ្លួនឯងគឺថា ជាវប្បធម៌នយោបាយរបស់កម្ពុជាប្រជាធិបតេយ្យដែលខ្លាចស្រមោលខ្លួនឯងនេះ។

**ស៖** សូមអរគុណ។ នៅក្នុងសៀវភៅរបស់លោក ៗបានពន្យល់ថា វប្បធម៌នេះដោយសារតែអត្តចរិតរបស់អ្នកដឹកនាំ ជាពិសេសលោកនិយាយអំពី ស្តាលីន និង ហ៊ីត្លែរ នៅទំព័រ១៣នៃសៀវភៅរបស់លោក 01001682 ERN ហើយលោកបានប្រៀបធៀបជាមួយនឹង ម៉ៅ សេទុង និង ប៉ុល ពត។ នៅទំព័របន្ទាប់នៃសៀវភៅរបស់លោក លោកបានពន្យល់ថា៖ “សម្រាប់ឥស្សរជនទាំងអស់នេះ គឺមានជំងឺខ្លាចស្រមោលខ្លួនឯង គឺមានន័យថា ជាជំងឺត្រូដេវវិច ហើយនិងមានជំងឺរវើរវាយ ការរវើរវាយចង់បានអំណាច។” តើលោកអាចពន្យល់នូវវិសាលភាពទាំងពីរនេះរបស់មេដឹកនាំនេះ ដែលតែងតែមានគំនិតតរវើរវាយចង់បានអំណាច ហើយនិងជំងឺខ្លាចស្រមោលខ្លួនឯងនោះ?

[០៩:៥៨:១៥]

**ឆ៖** បាទ គឺថាជនផ្តាច់ការនិយម គឺអ្នកដែលមានអំណាចផ្តាច់ការនេះ តែងតែមានការស្រមើស្រមៃអំពីភាពអស្ចារ្យ មហិមារបស់ខ្លួន។ ហើយពួកគេបានបង្កើតនូវលក្ខណៈមួយដូចដែល ស្តាលីន ក៏ដូចជាកម្ពុជាប្រជាធិបតេយ្យបានធ្វើដែរ គឺគេបង្កើតលក្ខណៈផ្ទាល់ខ្លួនមួយ គឺដែល ស្តាលីន ដែល ម៉ៅ ជាដើមបានបង្កើតគំនិតមួយថា ពួកគេដូចជាព្រះជាម្ចាស់អ៊ីចឹង <ដូចពួកកូរ៉េខាងជើងដែរ> គឺបានន័យថា វាជា ដូចជាសម្ព័ន្ធ គឺថាពួកទាំងអស់នេះហាក់ដូចជាសម្ព័ន្ធមិត្តរបស់<>កម្ពុជាប្រជាធិបតេយ្យ។ ហើយម្យ៉ាងទៀត ចំពោះការភ័យខ្លាច និងការខ្លាចស្រមោលខ្លួនឯងហ្នឹង គឺដោយសារតែបដិវត្តន៍ ដោយសារតែមេដឹកនាំបដិវត្តន៍ គាត់ចេញពីសង្គមរបស់គាត់ ៗព្យាយាមបំបែកខ្លួនឲ្យខុសពីសង្គមរបស់គាត់ ព្រោះថាគាត់ដឹងថា វាមានរឿងអាក្រក់ មិនល្អជាច្រើនកើតឡើងចំពោះប្រជាជនរបស់គាត់ <ទោះជាគាត់មិនគិតថាវាជាឧក្រិដ្ឋកម្មក៏ដោយ>។ ដូច្នេះហើយគាត់មានការខ្លាចថា ជនរងគ្រោះដទៃទៀតហ្នឹង <មានការអន់ចិត្ត និងខឹងសម្បាចំពោះគាត់>។ ដូច្នេះហើយគឺថា ចំណុចនេះពន្យល់ឲ្យឃើញអំពីការខ្លាចស្រមោលខ្លួនឯង។

ហើយមួយទៀតខ្ញុំចង់បង្ហាញថា ចលនាមួយនេះ គឺចលនារបស់ជនផ្តាច់ការនិយមហ្នឹង គឺជាចលនាដែលគ្រោះថ្នាក់ គឺថាបានន័យថា ពួកគេកើតចេញពីបរិយាកាសនយោបាយដ៏ច្របូកច្របល់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយដោយសារតែស្ថានភាពបរិយាកាសច្របូកច្របល់ហ្នឹង បានបង្កើតឲ្យមានវប្បធម៌នយោបាយខ្លាចស្រមោលខ្លួនឯងអ៊ីចឹង។ ដោយសារតែពួកគាត់ធ្លាប់តែគិតអំពីផែនការកម្ទេចគេ ដូច្នេះគាត់ចេះតែខ្លាចថា គេរៀបផែនការកម្ទេចគាត់ទៅវិញ។ អាហ្នឹងហើយគឺវាដក់នៅក្នុងខួរក្បាល ក៏ដូចជា កប់យ៉ាងជ្រៅនៅក្នុងចលនា<បដិវត្តន៍>។ ហេតុដូច្នេះហើយ ទើបជនផ្តាច់ការភាគច្រើនតែងតែមានលក្ខណៈមួយនេះនៅក្នុងខ្លួនរបស់ពួកគេ។

[១០:០០:៣៤]

**ស៖** សូមអរគុណ។ ខ្ញុំគិតថា លោកបានសង្ខេបអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅរួចមកហើយ។ ហើយនៅក្នុងសេចក្តីសន្និដ្ឋាន នៅទំព័រ២៣៩ 01001912 ម៉ាក្ស-ឡេនីន និយមនេះគឺ<មិនទទួលយកនូវអ្វីដែលកើតឡើងក្នុងប្រវត្តិសាស្ត្រថាជាការចៃដន្យនោះទេ គឺ>មាននិន្នាការមួយក្នុងការបង្កឲ្យមានការផ្សំគំនិត។ អ៊ីចឹងតើវាអនុវត្តដូចគ្នានៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** ខ្ញុំគិតថា គឺជាអ្វីដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺមានការរួមគំនិត ក៏ដូចជាការចូលដៃនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងនឹងរដ្ឋ <ពេលដែលពួកគេនៅក្រៅអំណាច ហើយប្រឆាំងនឹងប្រជាពលរដ្ឋទូទៅពេលដែលពួកគេមានអំណាច>។ ខ្ញុំគិតថា កម្ពុជាប្រជាធិបតេយ្យបានបញ្ចេញនូវទស្សនៈនៃការរួមគំនិតទៅបរិយាកាសអន្តរជាតិ ដោយសារតែគិតថា ពួកគេគិតថា នៅជុំវិញគេមានខ្មាំង។ ដូច្នេះទស្សនៈខ្មាំងគឺវា មាននៅគ្រប់របបទាំងអស់ ដូចជា របបស្តាលីន, <ម៉ៅ,> គីម ជុងអ៊ីល, គីម អ៊ីលស៊ុង, ប៉ុល ពត ទាំងអស់ហ្នឹងសុទ្ធតែមានការគិតដូចគ្នា ដែលគេគិតថា ពិភពលោកជុំវិញគេហ្នឹង គឺជាខ្មាំងទាំងអស់។ ហេតុដូច្នេះ ពួកគេតែងតែធ្វើបែបនេះ ដូចដែលយើងឃើញរាល់ថ្ងៃអ៊ីចឹង គឺថាកូរ៉េខាងជើង គេតែងតែអនុវត្តបង្កើរឿង ជាមួយប្រទេសដទៃនៅជុំវិញពិភពលោក គឺដូចគ្នានេះឯង។

[១០:០២:២៣]

**ស៖** សូមអរគុណ។ លោកបានបរិយាយលម្អិតអំពីនិន្នាការខ្លាចស្រមោលខ្លួនឯង នៅក្នុងគោលការណ៍នយោបាយនៃរបបនោះ ហើយលោកហៅថា ជាសហគមន៍ក្លែងក្លាយ។ ហើយខ្ញុំសូមដកស្រង់សម្រង់នៅក្នុងសៀវភៅរបស់លោកជាភាសាអង់គ្លេស សូមអ្នកបកប្រែត្រៀមខ្លួន ខ្ញុំនឹងអានជាភាសាអង់គ្លេសនូវអ្វីដែលលោកបកស្រាយនៅក្នុងសៀវភៅរបស់លោក។ ខ្ញុំសូមដកស្រង់៖ "ចំណុចសំខាន់មួយទៀត អំពីការភ័យខ្លាចហ្នឹងគឺការបង្កើតឡើងនូវសហគមន៍ *ស៊ូដូ-ផារ៉ាណយ* – សហគមន៍ក្លែង

ក្លាយ។ គំនិតឃោបល់នៃការ<រេរើសវាយជាលក្ខណៈបុគ្គលបានរីករាលដាលជាលក្ខណៈប្រព័ន្ធ។> ការបំបែកប្រជាជនទៅជាក្រុមៗ រៀបចំចាត់តាំងតាមរបៀបមួយដើម្បីឲ្យមនុស្សទាំងអស់ហ្នឹងយល់ឃើញថា <ជនដែលដល់គឺចូលជាក្រុមតែមួយដើម្បី>ឲ្យ<>មានឱកាសអាចធ្វើការបង្កើតជាការក្បត់ណាមួយ<ប្រឆាំងនឹងខ្លួន>។"

លោកក៏បានសរសេរបន្ថែមទៀតផងដែរថា៖ "យើងត្រូវនឹកឃើញថា តើរបបនីមួយៗនៃការបាក់បែកនយោបាយផ្ទៃក្នុង<ដោយរបៀបណា ហើយសូម្បីតែ "ខ្មាំង" ថ្នាក់សង្គម>ដែលត្រូវកំណត់គោលដៅដោយរបប គឺថាត្រូវគេយល់ថា ជាភ្នាក់ងារនៃការប្រទូសរ៉ាយដើម្បីអំណាចបរទេស។"

លោកអាចពន្យល់បន្ថែមបន្តិចបានទេ ពាក់ព័ន្ធនឹងការកសាងប្រព័ន្ធមួយដែលតាមរយៈនោះ ខ្មាំងទាំងអស់ ក្លាយទៅជាភ្នាក់ងារដែលមានអំណាចបរទេសប្រឆាំងនឹងរបបរបស់ខ្លួននោះ?

**ឆ៖** បាទ ដូច ស្តាលីន បង្កើតពួកប្រឆាំង ពួកឆ្វេងនិយមប្រឆាំងរបស់គាត់ ហើយពួកកុម្មុយនីស្តដែលអាចមាននិន្នាការទៅលើចក្រភពអង់គ្លេស បារាំង <ចិន> អាមេរិកាំងជាដើម។ ដូច្នេះ ប៉ុល ពត នេះបង្កើតសហគមន៍ក្លែងក្លាយ ឬក៏ហៅថាភាពភ័យខ្លាចនៅក្នុងសហគមន៍ណាមួយ ដោយយល់ឃើញថា ខ្មាំងហ្នឹងវាអាចមានខ្មាំងផ្ទៃក្នុងដែលបង្កប់ មាន សេ.អ៊ី.អា, កា.ហ្សេ.បេ ជាដើម <ដូចដែលខ្ញុំបាននិយាយហើយថា ពួកគេមិនមានសម្ព័ន្ធមិត្តនឹងគ្នាទាល់តែសោះ។ ផ្ទុយទៅវិញ គឺពួកគេមានទំនាក់ទំនងច្របូកច្របល់ណាស់។> ក៏ប៉ុន្តែជនផ្តាច់ការ<ដាក់សម្ព័ន្ធ>ឲ្យសត្រូវទាំងពីរហ្នឹង<ថា> សត្រូវទាំងពីរហ្នឹងរួបរួមគ្នាប្រឆាំងទៅនឹងរូបគាត់ ឬក៏របបរបស់គាត់។ នេះគឺជាការពន្យល់ពាក់ព័ន្ធទៅ<នឹងសេចក្តីថ្លែងការណ៍ចម្លែកៗដែលយើងបានឮនៅក្នុងសវនាការ>នេះ។

[១០:០៥:៥៧]

**ស៖** សូមអរគុណ។ លោកទើបតែនិយាយអំពី ប៉ុល ពត និងរបប ប៉ុល ពត។ លោកបានលើកឡើងអំពីអត្តចរិត និងបុគ្គលភាពរបស់ ប៉ុល ពត ដូច្នេះការស្រាវជ្រាវរបស់លោកអាចឲ្យលោកគិតអំពីតួនាទីរបស់អង្គការដែលជាអង្គភាពមួយ ធៀបទៅនឹង ប៉ុល ពត។ អ៊ីចឹងតើអ្នកណាជាអ្នកដែលមានជំងឺត្រដេវរិច ឬក៏ជំងឺភ័យខ្លាចស្រមោលខ្លួនឯងហ្នឹង? ហើយនិងតើលោកមានបានសិក្សាអំពីទំនាក់ទំនង ប៉ុល ពត និងអ្នកដែលនៅជុំវិញខ្លួនគាត់ទេ?

**ឆ៖** សូមលោកស្រីសួរសំណួរឡើងវិញបានទេ?

**ស៖** លោកបាននិយាយជាញឹកញាប់អំពី ប៉ុល ពត។ លោករៀបរាប់ថា គាត់មានជំងឺត្រដេវរិច

ឬក៏ជំងឺខ្លាចស្រមោលខ្លួនឯងនេះ។ អ៊ីចឹងខ្ញុំចង់សួរថាតើការស្រាវជ្រាវរបស់លោក អាចឲ្យលោកពង្រីកគំនិតហ្នឹងទៅរកសមាជិកបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតទេ? លោកគិតថា បុគ្គលភាពរបស់ ប៉ុល ពត នេះគឺជាកត្តាកំណត់ដ៏សំខាន់មួយទេ?

**ឆ៖** ខ្ញុំគិតថា ចលនានយោបាយនៃបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯងនេះ ជាអង្គការ<ឃុបឃិត> មួយ <ដែលទទួលរងនូវឥទ្ធិពលនៃ>វប្បធម៌នៃជំងឺត្រដេវរិចនេះឯង។ ខ្ញុំចង់និយាយថា ជនផ្តាច់ការដែលគ្រប់គ្រងអំណាចបែបហ្នឹង គឺថាកាន់តែខ្លាចខ្លាំងឡើង ជាងសហការីរបស់គេ។ អ៊ីចឹងទេ កម្រិតនៃជំងឺត្រដេវរិចនេះ គឺថាវាមាននៅជួរក្នុង វាមាននៅក្នុងវង់នៃបក្សកុម្មុយនីស្តនេះឯង។ នេះដោយសារថាបក្សហ្នឹងគឺថាជាបក្សមួយដែលបង្កឲ្យមានការភ័យខ្លាចបែបនេះ។

[១០:០៨:១៧]

**ស៖** កាលពីម្សិលមិញ <លោកបានប្រើពាក្យមួយថា "ការរួមគំនិតដ៏អស្ចារ្យ">។ ពេលហ្នឹងគឺលោកនិយាយអំពីបាតុភូតនៃការបង្កើតសហគមន៍ក្លែងក្លាយ ឬក៏ការស្រមើស្រមៃថាមានខ្មាំង<មកពីច្រើនកន្លែងបង្រួបបង្រួមគ្នាដោយរបបនោះ>។ អ៊ីចឹងពាក្យហ្នឹង លោកអាចពន្យល់ឲ្យច្បាស់បន្តិចបានទេ ពាក្យថា "<>ការសមគំនិតក្បត់<ដ៏អស្ចារ្យ>"នេះ?

**ឆ៖** អំពើក្បត់នេះមិនមែនកើតចេញពីអ្វីនោះទេ គឺដោយមានការឃុបឃិតគ្នា រួបរួមគ្នាពីកម្លាំងខាងក្រៅប្រឆាំងទៅនឹងរបបហ្នឹង។ <វាជាការស្រមើស្រមៃទាំងស្រុង។> ខ្ញុំមិនមែនចង់និយាយថា មិនមានផែនការក្បត់ប្រឆាំងទៅនឹងរបបនោះទេ ក៏ប៉ុន្តែមានន័យថា ការកសាងអំពើក្បត់ហ្នឹង គឺវាពិបាកនឹងជឿ។ <ពេលដែលខ្ញុំនិយាយពីសង្គមត្រដេវរិច ដែលថា កា.ហ្សេ.បេ និង សេ.អ៊ី.អា រួមគំនិតជាមួយគ្នាដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺ>វាជាការរវើរវាយ<សុទ្ធសាធ>។

**ស៖** សូមអរគុណ។ ខ្ញុំចង់ដកស្រង់ចម្លើយមួយរបស់ នួន ជា ដែលគាត់បានឆ្លើយកាលពីសវនាការថ្ងៃទី៣១ តុលា ឆ្នាំ២០១៣។ គាត់បាននិយាយទៅកាន់ប្រជាជនកម្ពុជាដើម្បីបង្ហាញអំពីការយល់ឃើញរបស់គាត់ ទៅលើហេតុការណ៍ដែលបានកើតឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៣១ តុលា ឆ្នាំ២០១៣ ប្រតិចារឹកសវនាការ E1/237.1 ម៉ោង១០:៣៦:៤៣វិនាទី។ ខ្ញុំសូមដកស្រង់នូវសម្តីរបស់គាត់។

[១០:១០:២៣]

នួន ជា និយាយទៅកាន់អង្គជំនុំជម្រះ នៅពេលដែលគាត់ឆ្លើយសំណួរ៖ "ដើម្បីឆ្លើយទៅនឹង

សំណួរដែលសួរដោយអង្គជំនុំជម្រះ និងសាធារណជន ខ្ញុំសូមឆ្លើយថា ហេតុការណ៍យុទ្ធសាស្ត្របាន កើតឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺវាកើតឡើងដោយសារមូលហេតុដូចតទៅនេះ។ ទី១ បក្សកុម្មុយនីស្តកម្ពុជា បានសម្រេចខុសក្នុងការជ្រើសរើសកម្មាភិបាលមួយចំនួនដែលបានក្បត់ ហើយនិងមិនយល់អំពីមាគ៌ាបក្ស។ អ្នកខ្លះ នៅធ្វើការនៅភ្នំពេញ ដោយមិនដែលចុះទៅតាមសហករណ៍ ទាល់តែសោះ។ ទី២ មេភូមិភាគ និងមេតំបន់ឯករាជ្យមួយចំនួន កម្មាភិបាលមួយចំនួន គឺជាភ្នាក់ងារ បង្កប់របស់វៀតណាម និងអាមេរិក ហើយពួកគេបានក្បត់បដិវត្តន៍។ សកម្មភាពរបស់ពួកគេ គឺមាន គោលបំណងកម្ទេចចលនារបស់បក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនកម្ពុជា ក៏ដូចជាប្រទេសកម្ពុជា។ ពួកគេមិនបានអនុវត្តតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងសេចក្តីណែនាំរបស់បក្ស ទេ។ ពួកគេសម្លាប់ និងធ្វើបាបប្រជាជន ដោយបង្អត់ពួកគេឲ្យអត់ឃ្លាន ហើយនិងបង្ខំឲ្យធ្វើការតាម ទំនើងចិត្តរបស់ពួកគេ។ ហើយពួកគេបានលាក់បាំងក្នុងរបាយការណ៍ ដោយធ្វើរបាយការណ៍ក្លែងក្លាយ ផ្ញើជូនគណៈមជ្ឈិមបក្ស។ ពួកគេបានប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាង ដើម្បីជំរុញឲ្យប្រជាជន ប្រឆាំងបដិវត្តន៍។ ចំណុចនេះបានធ្វើឲ្យបដិវត្តន៍ចុះខ្សោយ ហើយនិងមានការជ្រៀតចូលដោយពួកខ្មាំង។ ប្រធានភូមិភាគបូព៌ា បានបង្អត់អាហារដល់ប្រជាជន ហើយបានលួចនាំចេញស្រូវទៅកាន់វៀតណាម។ គឺពួកគេធ្វើឲ្យខាងក្រៅហ្នឹងគឺថាខ្មោច ប៉ុន្តែនៅខាងក្នុងនៅ។" ខ្ញុំសូមបញ្ចប់ត្រឹមនេះ។ នេះជាចម្លើយ របស់លោក នួន ជា។

ដូច្នេះតើលោកមានឃើញនៅនិរន្តរភាពដូចដែលលោកបានរៀបរាប់នោះ គឺថាជាការប្រមូលផ្តុំ សត្រូវ ហើយនិងមានការសមគំនិតក្បត់? ដូច្នេះតើលោកមើលឃើញអំពីនិរន្តរភាពរបស់គោលនយោ-បាយរបស់បក្ស<កុម្មុយនីស្ត>កម្ពុជា ហើយនិងការការពារខ្លួនរបស់ នួន ជា នៅក្នុងសវនាការនេះទេ?

[១០:១៣:២៦]

**ឆ៖** ខ្ញុំយល់ឧទាហរណ៍មួយចំនួននៅទីនេះ។ អ្វីដែល នួន ជា បាននិយាយនោះ គឺដើម្បីទម្លាក់ កំហុសទៅដល់សមាសធាតុ ដែលក្រោយមកថា ខ្លួនបានឃុបឃិតចងសម្ព័ន្ធមិត្តជាមួយវៀតណាម។ ខ្ញុំ មិនមែនជាអ្នកជំនាញខាងផ្នែកលក្ខខណ្ឌ ឬក៏ស្ថានភាពយល់ដឹងអំពីស្ថានភាពនៅតាមភូមិភាគផ្សេងៗ <នៃប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>នោះទេ ក៏ប៉ុន្តែបុគ្គលម្នាក់បានធ្វើជាសាក្សីនៅ ចំពោះមុខអង្គជំនុំជម្រះនេះ ជាអ្នកជំនាញនេះគឺ ស្ទីហ្វិន ហេដឌ័រ។ គាត់ថា ប្រជាជនរស់នៅភូមិភាគ បូព៌ាហ្នឹងមានហូបចុកគ្រាន់បើជាងភូមិភាគដទៃៗទៀត។ ខ្ញុំមិនជឿថា បញ្ហានៃភាពអត់ឃ្លាន និងជំងឺ

តម្កាត់ហ្នឹង គឺជាមូលហេតុចម្បងដែលបណ្ដាលឲ្យប្រជាជនស្លាប់ជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ខ្ញុំមិនជឿថាភាពអត់ឃ្លាត និងជំងឺតម្កាត់ហ្នឹង ថាជារឿងដែលបង្កឡើងដោយគោលនយោបាយរបស់ពួកភាគបូព៌ានោះទេ។ <ខ្ញុំជឿថាវាជាគោលការណ៍របស់ថ្នាក់មជ្ឈិម។> ការបណ្ដេញប្រជាជនចេញពីទីក្រុង ការបំបាត់លុយកាក់ ការបង្កើតសហករណ៍ ពលកម្មដ៏ធ្ងន់ធ្ងរ លក្ខខណ្ឌការងារដ៏ឃោរឃៅ ការខ្វះថ្នាំសង្កូវនេះ ជា<លទ្ធផលនៃដាក់គោលការណ៍>របស់ថ្នាក់មជ្ឈិមហើយ មិនមែនជាស្ថានភាពដែលត្រូវបានបង្កើតឡើងដោយភូមិភាគបូព៌ានោះទេ។ ហេតុដូច្នេះឯងខ្ញុំគិតថា នួន ជា ព្យាយាមមិនឲ្យមជ្ឈិមបក្សទទួលនូវកំហុសនេះទេ គឺថាទម្លាក់កំហុសទៅអ្នកដទៃទៀតទៅវិញ។

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាន! បានហើយ! បានហើយ! ដល់ម៉ោងសម្រាកហើយ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់កាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៦ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីអ្នកជំនាញ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការពេលប្រហែលជា១៥នាទីអីទៀតទេ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** លោកអ្នកជំនាញ ដើម្បីត្រឡប់មកនិយាយពីសេចក្តីប្រកាសរបស់ នួន ជា ដែលគាត់បានប្រកាសនៅថ្ងៃទី៣១ តុលា ឆ្នាំ២០១៣ នៅក្នុងសាលសវនាការនេះ ហើយលោកនៅតែគិតថា កម្លាំងបង្កប់របស់វៀតណាម <និងអាមេរិក>ហ្នឹង នៅតែជាអ្នកទទួលខុសត្រូវ ហើយដោយសារកម្លាំងបង្កប់ទាំងអស់នេះ សុទ្ធតែជាអ្នកក្បត់នឹងបដិវត្ត។ អ៊ីចឹងលោកបានសិក្សាអំពីរប្បធម៌របបនយោបាយទាំងអស់នេះគឺ ម៉ាក្ស-ឡេនីន។ អ៊ីចឹងខ្ញុំសូមសួរលោក ថាតើវាមានអសមត្ថភាពជាដាច់ខាតនៃរបបនេះ ដែលមិនអាចចេះចោទសំណួរខ្លួនឯង សួរថាតើខ្លួនឯងច្រឡំដែរឬទេ ហើយអ៊ីចឹងចេះតែបង្កើតថា ដោយសារតែខ្មាំងហ្នឹងហើយបានបរាជ័យហ្នឹង?

[១០:៣៨:០៦]

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** បាទ ពិតហើយ គឺថាខ្ញុំចង់ចង្អុលបង្ហាញផងដែរថា នួន ជា បានប្រើប្រាស់ឧទាហរណ៍របស់អាមេរិកដែលបញ្ជូនភ្នាក់ងារទៅចូលបក្សរបស់គាត់ដូច្នេះដែរ។ គឺថាអ្នកដែលមានមនោសញ្ចេតនាល្អចំពោះអាមេរិក អាចនឹងយល់ពីចំណុចនេះ។ ក្នុងសង្គ្រាម<វៀតណាម> គឺគេមិនចង់ឲ្យមានការជ្រៀតចូលទៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តវៀតណាម ទោះបីថាពួកគេ<មាន>ពេលវេលា២០ឆ្នាំ ដើម្បីលុបបំបាត់នេះក៏ដោយ ប៉ុន្តែអាមេរិកព្យាយាមយ៉ាងណា ក៏មិនអាចចូលជ្រៀតជ្រែកទៅក្នុងបក្សកុម្មុយនីស្តរបស់វៀតណាមបានដែរ <ទោះបីជាពួកគេមានសកម្មជនវៀតណាមធ្វើការជាមួយពួកគេក៏ដោយ>។ ដូច្នេះថាតើអាមេរិកធ្វើយ៉ាងណា ដើម្បីចូលមក គឺថាជ្រៀតខ្លួនបង្កប់ចូលក្នុងកម្ពុជាបាន ប្រសិនបើពួកគាត់មានទំនាក់ទំនងតិចតួចបំផុតជាមួយកម្ពុជា ហើយ<ក្នុងពេលសង្គ្រាម> គេក៏មិនមានធនធានគ្រប់គ្រាន់នៅក្នុងកម្ពុជាដែរ។ ដូច្នេះប្រាកដណាស់ថា អាមេរិកមិនអាចជ្រៀតចូលបង្កប់ខ្លួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបានឡើយ ទោះបីថា គេចង់ ក៏គេមិនអាចមានសមត្ថភាព ហើយក៏គេមិនដែលមានការបង្ហាញណាមួយ ថាពួកគេអាចមានលទ្ធភាពជ្រៀតចូលក្នុងបក្សកុម្មុយនីស្តកម្ពុជាបានឡើយ។

ខ្ញុំគិតថា ការពន្យល់ដូចដែលលោកស្រីបាននិយាយអ៊ីចឹង គឺថាវាមានបញ្ហានៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ គឺថាគេតែងតែបន្ទោសខ្មាំងបរទេសដែលជះឥទ្ធិពលទៅលើកម្មាភិបាលក្នុងស្រុក។ ខ្ញុំគិតថា វាជាការឆ្លុះបញ្ចាំងអំពី<អសមត្ថភាពនៃ>ការវាយតម្លៃដោយខ្លួនឯង។ ទោះបីថាគេបាននិយាយអំពីការទិតៀន ស្វ័យទិតៀនក៏ដោយ ប៉ុន្តែ<ថ្នាក់ដឹកនាំជាន់ខ្ពស់មិនសូវមានសមត្ថភាពក្នុងការទិតៀន>ខ្លួនឯង

<ទេ>។

[១០:៤០:០៨]

**ស៖** សូមអរគុណ។ នៅក្នុងសវនាការយើងនេះ យើងមាននិយាយអំពី សោ ភឹម លោកបាននិយាយនៅក្នុងសៀវភៅរបស់លោក។ លោកនិយាយពីព័ត៌មានលម្អិតមួយដែលយើងមិនទាន់បានលើកឡើងមកនិយាយក្នុងសវនាការនេះទេ គឺនៅទំព័រទី១០៩ ហើយនិង១១០ នៅក្នុងសៀវភៅរបស់លោក គឺ ERN 01001776 ហើយនិង 1777។ ហើយលោកបាននិយាយអំពីការប្រឹងប្រែងរបស់ ឡេ យន់ ដើម្បីរកមនុស្សរបស់ខ្លួន អ៊ីចឹងមានលើកឈ្មោះ សោ ភឹម។ លោកបាននិយាយនៅក្នុងសៀវភៅរបស់លោកដូចតទៅនេះ និយាយថា៖ “ឡេ យន់ ហ្នឹងបានប្រាប់ថា បក្សកុម្មុយនីស្តវៀតណាមព្យាយាមទាក់ទង សោ ភឹម ហើយកាលនោះ សោ ភឹម ស្លាប់៣ខែបាត់ទៅហើយ។” នេះបើតាមលោកបង្ហាញហ្នឹងគឺថាតាមពិតទៅ អត់មានទំនាក់ទំនងអ្វីរវាង សោ ភឹម និងវៀតណាមទេ មុនពេលដែល សោ ភឹម បានធ្វើអត្តឃាតខ្លួនឯងនោះ។ តើលោកអាចពន្យល់បញ្ជាក់ឲ្យបានច្បាស់ពីចំណុចនេះបានទេ?

**ឆ៖** បាទ គឺថាខ្ញុំលើកចំណុចនេះឡើងជាឧទាហរណ៍បង្ហាញថា វៀតណាមមិនបានដឹងអំពីអ្វីដែលបានកើតឡើងនៅកម្ពុជានោះទេ។ ប្រសិនគេព្យាយាមទាក់ទងមុនពេលដែល សោ ភឹម ស្លាប់ហ្នឹងគឺប្រាកដណាស់ថា គឺវាដូចដែល ប្រសិនបើដូចដែល នួន ជា គិតនោះវិញគឺថា ទាំងអស់នេះវាបានផ្ទុះបញ្ជាំង ការមិនមាន<សមត្ថភាពក្នុងការដឹងនូវ>អ្វីដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យអ៊ីចឹង <ជាជាងរបបមួយដែល>ដឹងច្បាស់អំពីអ្វីដែលកើតឡើងនៅក្នុងរបបមួយនេះ <និងមានសមត្ថភាព>។

[១០:៤២:១៧]

**ស៖** ខ្ញុំសូមអរគុណ។ ហើយយើងបាននិយាយអំពីការផ្សំគំនិតក្បត់រយៈពេល៣ថ្ងៃកន្លងមកនេះក្នុងសវនាការយើង។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ចេញប្រតិកម្មទៅលើពាក្យសម្ដីរបស់ នួន ជា តាមរយៈមេធាវីរបស់គាត់នោះ ហើយនិងភាគីផ្សេងៗទៀតនៅក្នុងសវនាការយើងនេះ។ ខ្ញុំក៏សុំឲ្យលោកបញ្ចេញប្រតិកម្មទៅលើការយល់ឃើញរបស់ នួន ជា ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញ ការបោសសម្អាតជាដើម ហើយនិងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ <ពាក់ព័ន្ធនឹង>មន្ទីរសន្តិសុខ<បី>។ នួន ជា គាត់បានលើកឡើងដូចតទៅនេះ អំពីឧក្រិដ្ឋកម្មទាំងអស់នោះ គឺឯកសារ E3/395/2 ERN គឺ01251288 គឺកថាខណ្ឌ២៧។ មេធាវីរបស់ នួន ជា បានលើកឡើងដូចតទៅនេះ នៅពេលដែលគាត់និយាយអំពីការប៉ុនប៉ងធ្វើរដ្ឋប្រហារ៖ “ការណ៍នេះបង្ហាញថា ចំនួនប្រជាជនយ៉ាងច្រើនមិនត្រូវបានសម្លាប់ដោយផ្អែកទៅ

លើជំនឿនយោបាយពិតប្រាកដ ឬក៏ប្រមើលឡើយ។ ប៉ុន្តែវាមានការសង្ស័យត្រឹមត្រូវអំពីការចូលរួមនៅក្នុងការក្បត់ រួមបញ្ចូលទាំងសកម្មភាពត្រៀមរៀបចំបះបោរ និងធ្វើវិទ្ធង្សនា។ គោលជំហររបស់មេធាវីការពារក្ដីគឺថា ដោយសារមូលហេតុនេះហើយទើបធ្វើឱ្យ<ដកបន្ទុក> នួន ជា <បានមួយផ្នែកដែរ> ចំពោះបទចោទមួយនេះ។"

ខ្ញុំសុំដកស្រង់សម្រង់មួយទៀតនៃសារណារបស់ក្រុម នួន ជា ដដែលហ្នឹង គឺឯកសារដដែលអម្បាញ់មិញហ្នឹង។ នៅក្នុងសារណាហ្នឹង គឺមេធាវីគាត់បានបង្ហាញអំពីយុទ្ធសាស្ត្រការពារ នួន ជា។ គាត់និយាយដូចតទៅនេះ សូមដកស្រង់ជាភាសាអង់គ្លេស៖ "គឺជាបញ្ហារបស់មេធាវីការពារក្ដីដែលថា <ពួកមេ>បះបោរក្បត់ <>ត្រូវទទួលខុសត្រូវចំពោះការសម្លាប់ និងអំពើឧក្រិដ្ឋកម្មនៅក្នុងតំបន់ដែលពួកគេគ្រប់គ្រង។" សំណួរ ដូចសំណួរអម្បាញ់មិញដែរ តើយុទ្ធសាស្ត្រនៃការការពាររបស់ នួន ជា ហ្នឹងមិនប្រែប្រួលទេ<>តាំងពី៤០ឆ្នាំមកហើយនោះ <គឺ>នៅតែយុទ្ធសាស្ត្រការពារដដែលនោះ។ តើវាផ្ទុះបញ្ចាំងអំពីអសមត្ថភាពរបស់អ្នកដឹកនាំ មេដឹកនាំខ្មែរក្រហមដែលមិនមានលទ្ធភាពចោទសំណួរសួរខ្លួនឯងថា អេ្ហ! ខ្លួនឯងខុសទេដឹងនេះ?

[១០:៤៥:៤១]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ វាជាសំណួរល្អមែនទែន ហើយខ្ញុំគិតថា ជាលើកដំបូងហើយនៅក្នុងសាលសវនាការនេះ ដែលមានការលើកឡើងពីគោលជំហររបស់មេធាវីការពារក្ដី ដើម្បីសួរទៅអ្នកជំនាញបែបនេះ។ ខ្ញុំមិនប្រាកដថា តើវាជាការត្រឹមត្រូវ ឬក៏អត់ក្នុងការលើកយកមកចោទសួរបែបនេះ ប៉ុន្តែខ្ញុំកំពុងតែគិត ថាតើត្រូវឆ្លើយតបដោយរបៀបណា? ប៉ុន្តែខ្ញុំគិតថា នេះជាការកត់សម្គាល់មិនមែនជាការជំទាស់ទេ។ ប៉ុន្តែការសន្និដ្ឋានរបស់មេធាវីការពារក្ដី គឺផ្អែកទៅលើអ្វីដែលយើងជឿជាក់ ក៏ដូចជាផ្អែកទៅលើភស្តុតាងដែលបង្ហាញថា វាមានចេតនាធ្វើរដ្ឋប្រហារជាច្រើនដែលផ្អែកទៅលើសក្ខីកម្មរបស់សាក្សីជាច្រើន ក៏ដូចជាឯកសារដែលសល់ពីសម័យនោះ ក៏ដូចជាខ្សែវីដេអូរបស់ រ៉ូប៊ឺត លឹមគិន ជាដើម។ ដូច្នេះខ្ញុំគិតថា គួរតែយកការវិភាគ ប្រភពវិភាគនានា មកសួរដេញដោលសាក្សី<អ្នកជំនាញ>ជាជាង

ការដែលលើកយកសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី មកសួរសាក្សីអ្នកជំនាញបែបនេះទៅវិញ។

[១០:៤៧:១៣]

**លោកស្រី ម៉ារី ហ្គ័រ៉ូដ៖**

លោកប្រធាន ខ្ញុំដកសំណួរខ្ញុំចេញ។ ការជំទាស់នោះ គួរឲ្យចាប់អារម្មណ៍ដែរ។ ខ្ញុំសូមសួរ៥នាទីទៀត។

**សួរដោយលោកស្រី ម៉ារី ហ្គ័រ៉ូដ៖**

**ស៖** លោកបាននិយាយថា ការអនុវត្តលទ្ធិម៉ៅហ្នឹងហួសហេតុ។ នៅក្នុងសៀវភៅរបស់លោក ទំព័រទី១៧គឺ<01001686> លោកដូចជាផ្សារភ្ជាប់ទស្សនទានដែលអនុវត្តលទ្ធិម៉ៅហួសហេតុនោះ ទៅនឹងទស្សនទានរបស់ខ្មែរក្រហម ដែលខំធ្វើយ៉ាងណាឲ្យអនុវត្តឲ្យលឿនជាង<ចិន>ទៅទៀត ដោយសារខ្មែរហ្នឹងមានអារម្មណ៍ថាអន់ជាងចិន។ អ៊ីចឹងតើលោកអាចពន្យល់អំពីទំនាក់ទំនងថា ខ្មែរហ្នឹងអន់ជាងចិនហ្នឹង អន់ជាងពួកម៉ៅនិយមហ្នឹងយ៉ាងម៉េចដែរ? សូមលោកជួយពន្យល់ចំណុចនេះឲ្យបានច្បាស់លាស់បន្តិចមើល។

[១០:៤៨:២៦]

**ឆ៖** បាទ គឺថា ដោយសារហេតុនេះហើយទើបខ្ញុំហៅថា ម៉ៅនិយមជ្រុលដែលជាភាពជ្រុលនិយមនៅលើការអនុវត្តទ្រឹស្ដីម៉ៅ។ គឺជាការព្យាយាមអនុវត្តអ្វីដែលគេធ្វើក្នុងរយៈពេលយូរមកធ្វើក្នុងរយៈពេលឆាប់។ ខ្ញុំគិតថា កម្ពុជាមិនចង់ទទួលរងនូវផលប៉ះពាល់នៃទំនាក់ទំនងជាមួយវៀតណាម។ ហើយគេគិតថា វៀតណាមមើលងាយកម្ពុជា។ ដូច្នេះខ្ញុំគិតថា ពួកគេព្យាយាមងាកចេញពីអ្វីដែលម៉ៅសេទុង ហើយនិង គីម អ៊ីលស៊ុង នៅកូរ៉េខាងជើងបានធ្វើ។ គឺគិតថា ពួកគេត្រូវតែបង្ហាញថា ខ្លួនពួកគេហ្នឹង គឺជាកុម្មុយនីស្តដ៏អស្ចារ្យពិតប្រាកដ ត្រឹមត្រូវ ដោយយកអ្វីដែលម៉ៅបានធ្វើ ប៉ុន្តែធ្វើក្នុងរយៈពេលដែលឆាប់រហ័ស ហើយនិងសង្កត់ធ្ងន់ឲ្យខ្លាំងជាងអ្វីដែល ម៉ៅ បានធ្វើទៅទៀត។ កម្ពុជាជាប្រទេសតូចមួយ ដូច្នេះហើយ ជាទូទៅប្រទេសតូចតែងតែគិតថា ខ្លួនឯងអន់ បើធៀបជាមួយប្រទេសដែលធំ។ ដូច្នេះហើយវាតែងតែមានការប្រៀបធៀបខ្លួនឯងបែបនេះ។

ដូច្នេះខ្ញុំគិតថា ចលនាមនោគមន៍វិជ្ជា គឺតែងតែតម្រូវឲ្យពួកគេគិតថាពួកគេជាកុម្មុយនីស្តបរិសុទ្ធ ឬក៏វាអស្ចារ្យជាងគេនោះ។ ខ្ញុំគិតថាខ្ញុំត្រូវការពេលវេលាច្រើន ប្រសិនបើខ្ញុំត្រូវពន្យល់អំពីអ្វីដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ។ ខ្ញុំប្រើប្រាស់ពាក្យសីលធម៌ គឺផ្អែកទៅលើអ្វីដែលកម្ពុជាប្រជា-

ធិបតេយ្យបានប្រើ មិនមែនជាពាក្យរបស់ខ្ញុំនោះទេ។

[១០:៥០:២៧]

**ស៖** ខ្ញុំសូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ តើលោកឃើញមានទំនាក់ទំនងរវាងការធ្វើឲ្យឆាប់រហ័សដែលគម្រោងបដិវត្តហ្នឹងខំធ្វើឲ្យលឿនហ្នឹង ទំនាក់ទំនងជាមួយនឹងបទឧក្រិដ្ឋដែលគេចោទប្រកាន់នៅក្នុងវិសាលភាពនៃការជំនុំជម្រះសេចក្តីនៃតុលាការយើងនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំយល់ស្រប។ គឺមានចេតនាលុបបំបាត់ចោលនូវវណ្ណៈសង្គម ក៏ដូចជាក្រុមពូជសាសន៍ គឺគេចង់លុបបំបាត់នូវភាពខុសគ្នានៅក្នុងសង្គម ខុសគ្នាផ្នែកនយោបាយ វប្បធម៌ សេដ្ឋកិច្ច គឺគេចង់បង្កើតសង្គមគំរូមួយ។ ខ្ញុំគិតថា ខ្ញុំត្រូវការពេលវេលាច្រើនដើម្បីពន្យល់ទៅលើអ្វីដែលគេចង់ធ្វើ។ ឧទាហរណ៍ដូចជា នៅពេលដែលខ្ញុំប្រើពាក្យថា "ម៉ៅនិយមជ្រុល" គឺមានឧទាហរណ៍<មិន>ច្រើន<ទេ> ដូចជាការអប់រំរៀនសូត្រ<ក្នុងន័យចិន> គឺជាការអប់រំរៀនសូត្រផ្នែកមនោគមន៍វិជ្ជា។ ចំណែកកម្ពុជាប្រជាធិបតេយ្យ ក៏គេប្រើប្រាស់ដូចគ្នាដែរ។ ឧទាហរណ៍ដូចថា ប្រសិនបើគេចាប់បានខ្មាំង គេមិនយកទៅរៀនសូត្រមែនទែនទេ គឺគេយកទៅកម្ទេចជាដើម។ នេះគឺជាផ្នែកមួយនៃការប្រញិចប្រញាប់ដើម្បីបង្កើតសង្គមកុម្មុយនីស្តដែលស្រមើស្រមៃហួសនិយម។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកអ្នកជំនាញដែលបានឆ្លើយនឹងសំណួរខ្ញុំ។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញរូបនេះ។

[១០:៥២:៣៧]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់គ្នា ជម្រាបសួរអស់លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ម័ររីស ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំនឹងចោទសំណួរបន្ថែមមួយចំនួន ធៀបទៅនឹងចំណុចមួយចំនួនដែលបានលើកឡើងហើយ។ ហើយខ្ញុំនឹងសុំការបំភ្លឺពីលោក ហើយនិងខ្ញុំពិភាក្សាអំពីឯកសារមួយចំនួនជាមួយលោកផងដែរ។ ជាបឋមខ្ញុំសូមត្រឡប់មកនិយាយអំពីការស្រាវជ្រាវរបស់នៅបណ្ណសារសូវៀត។ ក្នុងសៀវ-ភៅរបស់លោក តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា ប្រភពដែលសំខាន់ជាងគេបំផុតនោះនៃការសរសេរសៀវភៅរបស់លោកនោះ គឺបណ្ណសារសូវៀត។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** នៅក្នុងបណ្ណសារសូវៀតនេះ លោកបាននិយាយថា លោកមានសំណាងដែលបានពិគ្រោះឯកសារជាច្រើន ហើយនៅក្នុងឯកសារទំព័រចង្អុលបង្ហាញហ្នឹង លោកបានបង្ហាញថាលោកបានរកឃើញឯកសារដែលលោកចង់បានជាច្រើន។ ហើយនៅក្នុងចំណោមឯកសារទាំងអស់នោះ <ខ្ញុំមិនដឹងថា>មានឯកសារមួយចំនួនដែលនិយាយអំពីកិច្ចការពិភាក្សាគ្នាដោយផ្ទាល់ រវាងសមាជិកការទូតរុស្ស៊ី ហើយនិងបុគ្គលផ្សេងទៀតដែលបាននិយាយគ្នា ពិភាក្សាគ្នា<ជាមួយ>មេដឹកនាំរបស់កម្ពុជាប្រជាធិប-តេយ្យ។

[១០:៥៤:២៦]

**ឆ៖** លោកស្រីសួរខ្ញុំ ថាតើបានរកឃើញភស្តុតាងនៃការជជែកគ្នារវាងមន្ត្រីប្រទេសណាមួយ<ជាមួយនឹង>កម្ពុជាប្រជាធិបតេយ្យ<មែនទេ>? ខ្ញុំស្តាប់អត់ទាន់។

**ស៖** លោកបានពន្យល់ថា នៅក្នុងបណ្ណសារដែលលោកបានពិគ្រោះនោះគឺថាមានរបាយការណ៍ការទូតរបស់សហភាពសូវៀតកាលពីសម័យនោះ។ អ៊ីចឹងខ្ញុំសួរថាតើនៅក្នុងរបាយការណ៍ទាំងអស់នោះមានធាតុផ្សំណាមួយដែលអំពីការពិភាក្សាគ្នារវាងរុស្ស៊ី ហើយនិងកម្ពុជាប្រជាធិបតេយ្យដែរឬទេ? <តើលោកមានរកឃើញធាតុផ្សំផ្ទាល់ទេ?> ឬក៏រាល់ដងនោះ <វាជារបាយការណ៍ចេញដោយ>ប្រទេសវៀតណាម <ឬក៏អ្នកដទៃទៀត>ទេ?

**ឆ៖** ខ្ញុំអត់មានកំណត់ត្រានៃការពិភាក្សារបស់មន្ត្រីសហភាពសូវៀត និងកម្ពុជាប្រជាធិបតេយ្យនោះទេ គឺមានតែការសន្ទនារវាងមន្ត្រីសូវៀត ជាមួយនឹងថ្នាក់ដឹកនាំវៀតណាមនោះទេ។

**ស៖** ដូច្នេះបើខ្ញុំមិនច្រឡំទេ នៅពេលដែលលោកប្រើបណ្ណសារទាំងអស់នោះ ដើម្បីនិយាយ

បញ្ជាក់អំពីគោលជំហររបស់កម្ពុជាប្រជាធិបតេយ្យនោះ គឺតាមរយៈការលើកឡើងរបស់ប្រទេសវៀត-ណាម ជាមួយនឹងអាជ្ញាធររុស្ស៊ី ស្ដីអំពីកម្ពុជាប្រជាធិបតេយ្យទេ។ តើអ៊ីចឹងមែនទេ?

[១០:៥៦:១៥]

**ឆ៖** បាទ ខ្ញុំប្រើប្រាស់ឯកសារទាំងអស់ ទាក់ទងទៅនឹងអ្វីដែលវៀតណាមគិតថាជាស្ថានភាពនៅក្នុងកម្ពុជា។ ពិតហើយ វាអាចថាមិនមែនជាស្ថានភាពពិតប្រាកដនៅក្នុងកម្ពុជាទេ។ ដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ ថាវៀតណាមមិនបានយល់ច្បាស់លាស់អំពីស្ថានភាពនៅក្នុងកម្ពុជាប្រជាធិប-តេយ្យ ហើយគេក៏មិនយល់អំពីអាកប្បកិរិយាពិតប្រាកដរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះដែរ។

**ស៖**សំណួរខ្ញុំហ្នឹង សួរដូចដដែលដែរ ទាក់ទងទៅនឹងរយៈកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ។ យើងដឹងថា មានទំនាក់ទំនងជាក់លាក់រវាងវៀតណាម និងអ្នកដែលនឹងក្លាយជាមេដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ។ តើ<ស្ថានភាពនៅតែដដែលក្នុងអំឡុងពេលនោះឬ?> ខ្ញុំសួរលោកថាអ៊ីចេះ តើសហភាពសូវៀតនោះ ទទួលព័ត៌មានហ្នឹង អាស្រ័យទៅតាមការរៀបរាប់របស់វៀតណាម ស្ដីអំពីមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ<ក្នុងអំឡុងឆ្នាំ៧០ ដល់៧៥> ឬក៏យ៉ាងណា? <>

**ឆ៖** បាទ សូវៀតមានព័ត៌មានតែពីខាងវៀតណាម អំពីអ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ៧០ ដល់៧៥។ ប៉ុន្តែខ្ញុំចង់បង្ហាញផងដែរថា ខ្ញុំបានទទួលបាន មានឯកសារដែលទទួលបាននៅក្នុងពេលសង្គ្រាម ហើយខ្ញុំព្យាយាមយល់អំពីអ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ៧០ ដល់៧៥ គឺជាឯកសារដែលសហរដ្ឋអាមេរិកចាប់បាន មិនមែនជាឯកសារដែលខ្ញុំរកឃើញនៅក្នុងបណ្ណសារសូវៀតទេ។

[១០:៥៨:១៥]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីរយៈកាលហ្នឹង ថារយៈកាលមុនឆ្នាំ១៩៧៥ហ្នឹងបន្តិចទៀត។ ឥឡូវខ្ញុំចូលនិយាយអំពីការកត់សម្គាល់របស់លោកកាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់មេធាវី កូប៉េ ទាក់ទងទៅនឹងការរិះគន់របស់ ដេវីដ ឆេនដ៍ល័រ លើសៀវភៅរបស់លោក។ លោកបាននិយាយថា ដូចការរិះគន់ផ្សេងៗទៀតដែរ ថាមានអ្នកប្រវត្តិវិទូជាច្រើន។ កាលពីម្សិលមិញនោះ ប្រហែលម៉ោង១៤:១៩នាទីហ្នឹង លោកបានលើកឡើងដូចតទៅនេះ៖ "ដូចប្រវត្តិវិទូផ្សេងទៀតដែរ ដែលបានរិះគន់លើសៀវភៅខ្ញុំហ្នឹង គឺការរិះគន់របស់គាត់មិនទាក់ទងទៅនឹងប្រវត្តិសាស្ត្រទេ ទាក់ទងតែទៅនឹងវិទ្យាសាស្ត្រនយោបាយ <ដែលខ្ញុំយល់ឃើញថាវាមិនសមទំនងទាល់តែសោះ>។ <ការលើក

សំអាងរបស់ខ្ញុំ ដែលថាការមិនសមទំនង គឺជាស្នូលនៃជម្លោះ>នៅក្នុងឥណ្ឌូចិនហ្នឹង<> <វាផ្ទុយពីសាមគ្គីភាព និងសច្ចសីលភាព នៃការរកឃើញជាក់ស្តែងរបស់ខ្ញុំ>។”

ឥឡូវខ្ញុំសូមដកស្រង់ការរិះគន់របស់ ដេវីដ ឆេនដ័ល័រ មួយទៅលើសៀវភៅរបស់លោក។ ដេវីដ ឆេនដ័ល័រ និយាយដូចតទៅនេះ គឺឯកសារ E3/10703, ERN ជាភាសាអង់គ្លេសគឺ 01335287 តែជាភាសាអង់គ្លេសមួយហ្នឹងទេ អត់មាន ERN ជាភាសាផ្សេងទៀតទេ។ នៅទំព័រ៦៨ ហើយនិង៧២ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ “នៅទំព័រ៦៨ និងកន្លែងផ្សេងទៀត ម័ររីស បាននិយាយអំពីខ្មែរក្រហមថាមានទំនាក់ទំនងបរទេសមិនសមស្រប ហើយមិនត្រឹមត្រូវ។ ប៉ុន្តែ<គាត់មិនបានលើកឡើងថា>គោលនយោបាយចំពោះវៀតណាម<ជាអ្វីនោះទេ ក្រៅពីបង្អោនទៅតាមការការពារ និងតម្រូវការរបស់វៀតណាម។> ចំពោះវៀតណាមផ្ទាល់ខ្លួន <ទោះជាក្នុងករណីណាក៏ដោយ នឹងប្រើ>នូវ<គោលនយោបាយមិនសមទំនង>ប្រហាក់ប្រហែលគ្នា<>ចំពោះចិន ដោយផ្អែកទៅលើ<គោលការណ៍ភ័យខ្លាចស្រមោលខ្លួនឯងរបស់> ម៉ាក្ស-ឡេនីន <តិចជាងការយល់ឃើញនៃការគំរាមកំហែងចំពោះអធិបតេយ្យភាពផ្នែកផ្នែកខ្លះលើការពិចារណានូវប្រវត្តិសាស្ត្រនៃវប្បធម៌>។ <នេះបើតាមអ្វីដែល ម័ររីស បានលើកឡើង>។ នៅទំព័រ៧២វិញ ម័ររីស អះអាងថាមានភស្តុតាង<ឯករាជ្យតិចតួច>ដែលថា ថៃហើយនិងវៀតណាមវាយប្រហារកម្ពុជានៅក្នុងឆ្នាំ៧៦។ តាមពិតទៅឯកសារខ្មែរក្រហមជាច្រើនដែលទាក់ទងជាមួយការការពារជាតិបង្ហាញនៅទីក្រុងភ្នំពេញ<តាំងពី ម័ររីស បានបញ្ចប់ការស្រាវជ្រាវរបស់គាត់ម្ល៉េះ>។ បញ្ហានេះបានបង្ហាញថា ពីឆ្នាំ៧០រហូតមក <>គឺថាមានការបះបោរនៅតាមព្រំដែន<កម្ពុជា ធ្វើឡើងដោយថៃ វៀតណាម និងកម្លាំងខ្មែរជាញឹកញាប់>។ ហើយប្រហែលជាមានករណីជាច្រើនដែលថា ធ្វើឱ្យប៉ុល ពត ជឿជាក់កាន់តែខ្លាំង ថាខ្លួនឯងត្រូវហ៊ុមព័ទ្ធទៅដោយខ្មាំង។” សូមបញ្ចប់ការដកស្រង់។

[១១:០១:៥៣]

សម្រង់ដ៏វែងនេះ ឥឡូវដែលជាការរិះគន់ ឬការពិនិត្យឡើងវិញរបស់ ដេវីដ ឆេនដ័ល័រ ទៅលើសៀវភៅរបស់លោកហ្នឹង គឺចង់បង្ហាញថា ការរិះគន់លើសៀវភៅរបស់លោកនេះ មិនមែនជាការវិភាគស៊ីជម្រៅ ដោយផ្អែកលើបណ្ណសាររុស្ស៊ីនោះទេ ក៏ប៉ុន្តែ ទោះយ៉ាងណាក្តី <តាមការយល់ឃើញរបស់មនុស្សមួយចំនួន> បណ្ណសាររុស្ស៊ីនេះជាពិភពដ៏សំខាន់បំផុតនៃការស្រាវជ្រាវរបស់លោក។ អ៊ីចឹងដោយសារ<លោក>មិនបានបញ្ចូលឯកសារដែលបោះពុម្ពផ្សាយនៅសម័យកម្ពុជាប្រជាធិបតេយ្យយើងនោះ ចូលទៅក្នុងសៀវភៅរបស់លោកនោះ ដែលធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវរបស់លោកនោះ អ៊ីចឹង

01365092



ហើយបានធ្វើឲ្យការវិភាគរបស់លោកនោះមិនមានភាពពេញលេញ។ អ៊ីចឹងដោយសារលោកមិនបានផ្អែកទៅលើ មិនបានពិគ្រោះឯកសារដែលគេសរសេរនៅសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងហើយ បានធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវរបស់លោកមិនពេញលេញ។ តើលោកមានគំនិតយោបល់យ៉ាងម៉េចដែរចំពោះការរិះគន់នេះ? <លោកឃើញអ្វីដែលជាបញ្ហានៅទីនេះទេ? គឺវាដោយសារតែពេលលោកសរសេរសៀវភៅរបស់លោកហ្នឹង គឺមិនទាន់មានសមាសធាតុដែលត្រូវបានគេរកឃើញក្រោយមកទៀត។> សហភាតារបស់ខ្ញុំបានលើកឡើងថា ខ្ញុំនិយាយអម្បាញ់មិញនេះ ខ្ញុំច្រឡំថាឆ្នាំ១៩៧០ តាមពិតឆ្នាំ១៩៧៦ទេ។ ខ្ញុំសុំកែប្រែឡើងវិញ។

**ឆ៖** បាទ គឺថាខ្ញុំសុំអភ័យទោសដោយសារតែខ្ញុំមិនបានអានឯកសារ ដោយសារខ្ញុំបានបញ្ចប់សៀវភៅខ្ញុំរួចមកទៅហើយ។ ហើយខ្ញុំក៏មិនមានឱកាសដើម្បីអានឯកសារនេះមុនពេលដែលខ្ញុំបញ្ចប់ការសរសេរសៀវភៅរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំចង់ឃើញឯកសារនេះ ហើយនិងអាចវាយតម្លៃទៅលើឯកសារនេះ ហើយនិងធ្វើការសម្រេច ថាតើឯកសារហ្នឹងវាឆ្លុះបញ្ចាំងពីស្ថានភាពពិតប្រាកដ ឬក៏មិនមែន គឺទាក់ទងទៅនឹងកម្ពុជា វៀតណាម ហើយនិងថៃ។ ដូច្នេះខ្ញុំនេះគឺជាអ្វីដែលខ្ញុំអាចឆ្លើយតបនៅពេលនេះទាក់ទងទៅនឹងការលើកឡើងរបស់លោក ដេវីដ ឆេនដ័ល័រ។ គឺថាយើងត្រូវតែប្រុងប្រយ័ត្ននៅពេលដែលយើងប្រើប្រាស់ឯកសារ ព្រោះយើងក៏ដឹងថា ឯកសារនេះជាឯកសារអ្វី។ ហើយដោយសារតែខ្ញុំមិនអាចផ្តល់ចម្លើយបាន ប្រហែលជាលោកស្រីដឹងថាឯកសារនេះជាឯកសារអ្វី គឺថាលោកស្រីមានស្ថានភាពល្អប្រសើរជាងខ្ញុំ ក្នុងការដឹងអំពីប្រភេទឯកសារនេះ។

[១១:០៤:៥៤]

**ស៖** ខ្ញុំយល់ គឺបើរយៈពេលលោកខ្លីណាស់ អ៊ីចឹងលោកមិនអាចស្គាល់ពីឯកសារដែលយើងមាននៅទីនេះទេ។ អ៊ីចឹងអំមិញនោះលោកឆ្លើយនឹងសំណួរខ្ញុំហើយ អ៊ីចឹងខ្ញុំកត់ត្រាទុកហើយ។ ចំណុចមួយទៀតដែលខ្ញុំចង់ពិភាក្សាជាមួយលោកដែរ គឺបើតាមការធ្វើកោសល្យវិច័យរបស់លោកនោះ លោកនិយាយអំពីរបប ម៉ាក្ស-ឡេនីន លោកនិយាយអំពីជំងឺត្រដេវរិច។ អ៊ីចឹងខ្ញុំសូមសួរសំណួរជាក់លាក់មួយថាតើជំងឺត្រដេវរិចហ្នឹង វាមិនពាក់ព័ន្ធតែនឹងរយៈកាលមួយនៃសង្គ្រាមត្រជាក់ហ្នឹងទេឬ? អ៊ីចឹងសំណួរខ្ញុំមួយទៀត ខ្ញុំចង់ដឹងថាតើនៅក្នុងសង្គ្រាមត្រជាក់ រយៈកាលសង្គ្រាមត្រជាក់នេះ <មិនថាដោយសារ> របៀបដែលយើងទទួលព័ត៌មានបាននោះ តាមរយៈដែលសម្ព័ន្ធភាពដែលគេមាននៅកាលនោះៗ <តើវាមិនមែនជាអំឡុងពេលមួយដែលពិសេសទេឬ? មិនថាចំពោះ>សហភាពសូវៀតក៏ដោយ ខាងវៀតណាម

ក៏ដោយ កម្ពុជាប្រជាធិបតេយ្យក៏ដោយនោះ<>?

**ឆ៖** បាទ វាគឺជាអំឡុងពេលពិសេសមួយ ប៉ុន្តែមិនមែន<ទាំងអស់គ្នា>មានប្រតិកម្មរបៀបជំងឺត្រដេវរិចយ៉ាងដូច្នេះទេ។ ខ្ញុំមានបំណងចង់ពន្យល់ថា ហេតុអ្វីបានជាគេ ពួកគេថាមានការឃុបឃិត ការឃុបឃិបបែបនេះគឺថា មិនគួរឲ្យជឿជាក់បាន នៅពេលដែលគេពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីថា គឺការឃុបឃិតដែលនាំឲ្យឈានទៅដល់ការស្វែងរកខ្មាំង<នៃរបប>នៅក្នុងប្រទេស ហើយដែលអះអាងថា<មានការសហការរវាង>ប្រទេស ឬក៏ស្ថាប័នទាំងអស់នោះ <ដែល>មិនមានទំនាក់ទំនងល្អនេះ <ថាជាពួក>កា.ហ្សេ.បេ, សេ.អ៊ី.អា។ ហេតុដូច្នេះឯង ខ្ញុំក៏បានឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានថា របាយការណ៍ដែលសរសេរថាមានការឃុបឃិបនេះ គឺជាការនាំឲ្យជំងឺត្រដេវរិច។ វាមិនអាចដែលថា កា.ហ្សេ.បេ, សេ.អ៊ី.អា ឃុបឃិតជាមួយសហរដ្ឋអាមេរិក និងសូវៀត<ដើម្បី>ទម្លាក់របបនោះ<>ទេ។

[១១:០៧:៤២]

**ស៖** ទាក់ទងទៅនឹងរយៈកាលជាក់លាក់ហ្នឹង ទាក់ទងទៅនឹងការគ្រប់គ្រងព័ត៌មានអម្បាញ់មិញខ្ញុំសួរសំណួរលោក <ពី>ប្រភព<ព័ត៌មាន>ដែលសហភាពសូវៀត<>ទទួលបាន<អំ>ពីកម្ពុជាប្រជាធិបតេយ្យ ឬក៏វៀតណាម <អំពីចលនាបដិវត្តន៍>។ លោកឆ្លើយថា ប្រភពបានមកពីវៀតណាម រុស្ស៊ីទទួលបានព័ត៌មានពីវៀតណាម។ <លោកក៏បាននិយាយផងដែរថាលោកបានធ្វើការជាមួយ ឌីមីទ្រីមូស្ស៊ីកូហ្វ។> ខ្ញុំសូមសួរពិភាក្សាជាមួយលោកអំពីផ្នែកមួយនៃសៀវភៅរបស់ ឌីមីទ្រី ចំពោះអង្គជំនុំជម្រះគឺឯកសារ E3/9644។ ផ្នែកដែលខ្ញុំចង់ដកស្រង់ហ្នឹងគឺនៅ ERN ជាភាសាបារាំងគឺ 01125311, ជាភាសាអង់គ្លេសគឺ 01085983, ជាភាសាខ្មែរគឺ 01120084។ សូមភាគីឲ្យយោងទៅនឹងផ្នែកនេះទៅ<>សូមសំណួរសួរសំណួរបឋមមួយ។ នៅក្នុងបណ្តាសារដែលលោកបានពិគ្រោះនោះ តើលោកមានចាំទេ ចាំពីការពិភាក្សាណាមួយ ឬក៏ព័ត៌មានណាមួយដែលលោកបានអាន ដែលពាក់ព័ន្ធទៅនឹងឆន្ទៈរបស់សហភាពសូវៀតដែលចង់ជួបមេដឹកនាំខ្មែរក្រហមដែរឬទេ? តើលោកមានអានជួបឯកសារណាមួយដែលបង្ហាញថា សហភាពសូវៀតហ្នឹង ចង់ជួបមេដឹកនាំខ្មែរក្រហមដែរឬទេ?

**ឆ៖** អត់ទេ ខ្ញុំអត់មានបានរកឃើញឯកសារណាមួយនោះទេ។

[១១:០៩:៥៣]

**ស៖** នៅក្នុងឯកសារដែលខ្ញុំនឹងដកស្រង់ជូនលោកនេះ គឺលោក មូស្ស៊ីកូហ្វ គាត់បាននិយាយអំពី

01365094



ការពិភាក្សាមួយនៅខែមេសា ឆ្នាំ១៩៧៤ រវាងឯកអគ្គរាជទូតសូវៀត និង ផាំ វ៉ាន់ដុង។ ខ្ញុំច្រឡំទំព័រហ្នឹង គឺរវាងឯកអគ្គរដ្ឋទូតសូវៀត ហើយនិង ហ៊ុង វ៉ាន់ធីន ដែលជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស<នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម>។ ហើយកាលនោះឯកអគ្គរដ្ឋទូតនោះសុំជួប ខៀវ សំផន ដែលគាត់គិតថា ខៀវ សំផន នោះជាមេដឹកនាំចលនាខ្មែរក្រហម។ មានលើកឡើងដូចតទៅនេះ មុនផ្នែកអ្វីដែលខ្ញុំអានអម្បាញ់មិញនេះ គឺមានពន្យល់ថា ខៀវ សំផន មិនមែនជាបុគ្គលដែលធំជាងគេនោះទេ។ ហើយកាលនោះសហភាពរុស្ស៊ី អត់ទាំងដឹងផង។ ហើយបន្ទាប់មកទៀត <គេបានលើកឡើងពី>វៀត-ណាម<>ថា៖ “ទំនាក់ទំនងរវាងមូស្គូ ហើយនិងខ្មែរក្រហម មិនអាចទៅរួច ទាល់តែ លុះត្រាតែបុគ្គលសំខាន់ៗក្នុងជួរដឹកនាំខ្មែរក្រហម បានចូលរួមដំណើរការនេះ។ ផ្ទុយទៅវិញ វៀតណាមព្យាយាមឲ្យអស់ពីសមត្ថភាពរបស់ខ្លួនក្នុងការទប់ស្កាត់ទំនាក់ទំនងដោយផ្ទាល់រវាងអាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជា និងមូស្គូ ក្នុងបំណងបញ្ចៀសស្ថានភាពមួយដែលអាចនឹងមានភាគីណាមួយផ្សេងទៀត ក្រៅពីវៀតណាម អាចបង្កើតទំនាក់ទំនងជាមួយនឹងខ្មែរក្រហមបាន។ ដោយដឹងថា ទីក្រុងមូស្គូអាចសង្ស័យពីគោលបំណងពិតប្រាកដរបស់ក្រុងហាណូយ ក្នុងការទទូចឲ្យមានការបង្កើតទំនាក់ទំនងរវាងបក្សកុម្មុយនីស្តនៃសហភាពសូវៀត និងបក្សកុម្មុយនីស្តកម្ពុជា មន្ត្រីវៀតណាមតែងតែបានប្រកាសថា បក្សពលករវៀត-ណាមខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការជួយដល់ការជំរុញទំនាក់ទំនងរវាងសមមិត្តកម្ពុជា ហើយនិងសមមិត្តនៃសហភាពសូវៀត។ ហើយបន្ទាប់មក អ្នកនិពន្ធនៃសៀវភៅហ្នឹង គាត់បានរៀបរាប់អំពីកំណត់ហេតុប្រជុំ កំណត់ហេតុនៃកិច្ចសំណេះសំណាលហ្នឹង។ តើលោកមានចាំទេ នៅពេលដែលលោកធ្វើការពិគ្រោះបណ្ណសារសហភាពសូវៀតហ្នឹង មានបានជួបនឹងផ្នែកហ្នឹងទេ?

[១១:១២:៣៦]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំខ្លាចតែខ្ញុំស្តាប់មិនច្រឡំ ប៉ុន្តែសុំឲ្យអ្នកជំនាញច្បាស់ ប៉ុន្តែដូចជាមេធាវីមិនបានផ្តល់ការបរិច្ឆេទឲ្យបានត្រឹមត្រូវទេ។ <នៅខែមេសា ឆ្នាំ១៩៧៤ហ្នឹង វាមិនស្ថិតនៅក្រោមថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យឡើយ>។

**កញ្ញា អង់តា ហ្គីសសេះ**

ជាភាសាបារាំង ខ្ញុំនិយាយច្បាស់ហើយ គឺថានៅខែមេសា ឆ្នាំ១៩៧៤។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងសំណួរខ្ញុំចង់សួរថាអ៊ីចេះ តើសម្រង់ដែលខ្ញុំដកស្រង់ជូនអម្បាញ់មិញនេះធ្វើឲ្យលោកនឹកឃើញទេ? នេះជាសំណួរទី១។ ជាសម្រង់របស់លោក ឌីមីទ្រី។

**លោក ស្ទីហ៊ិន ម៉័ររីស៖**

**ឆ៖** គួរឲ្យសោកស្តាយ ខ្ញុំមិនដែលបានឃើញឯកសារនេះទេ ហើយខ្ញុំក៏នឹកមិនឃើញដែរ។ ហើយលោក មូស្ស៊ីកូហ្វ បានធ្វើកិច្ចការរបស់គាត់ផ្ទាល់នៅឯបណ្ណសារនោះ ពេលជាមួយគ្នា <គាត់ធ្វើការ>ជាមួយខ្ញុំនេះដែរ ប៉ុន្តែគាត់មិនបានបង្ហាញខ្ញុំ នូវឯកសារនេះឲ្យខ្ញុំឃើញទេ។

[១១:១៣:៣៩]

**ស៖** អ៊ីចឹងសំណួរខ្ញុំធៀបទៅនឹងសំណួរមុនៗរបស់ខ្ញុំហ្នឹង គឺក្នុងការគ្រប់គ្រងព័ត៌មាននៅក្នុងអំឡុងពេលសង្គ្រាមត្រជាក់ហ្នឹង <និងសម្ព័ន្ធភាពដែលបានបង្កើតឡើង> តើអ្នកណាអាចជួបអ្នកណាបាន? ព័ត៌មានចេញពីណាទៅណាអីនោះ។ អ៊ីចឹង<នេះជាការគូសបង្ហាញនៃ>ការគ្រប់គ្រងកិច្ចការការទូតរបស់វៀតណាមនោះ តើ<>ដោយសារបរិបទសង្គ្រាមត្រជាក់ហ្នឹងហើយឬ <ជាពិសេសទាក់ទងនឹងអ្វីដែលបានរៀបរាប់មកហើយអំពីការគ្រប់គ្រងកិច្ចការការទូតពីសំណាក់វៀតណាម> បានព័ត៌មានចេះតែលួចលាក់យ៉ាងដូច្នេះ?

**ឆ៖** បាទ ខ្ញុំគិតឃើញថា នេះជាមតិយោបល់មួយត្រឹមត្រូវហើយ។

**ស៖** ទាក់ទងទៅនឹងអំឡុងសង្គ្រាមត្រជាក់ដដែល យើងទាំងអស់គ្នាដឹងហើយ យើងធ្លាប់បានពិភាក្សាពីចំណុចនេះហើយ គឺថាមានជម្លោះតាមព្រំប្រទល់ ក្រៅពីការពិភាក្សាគ្នារវាង វៀតណាម និងកម្ពុជាប្រជាធិបតេយ្យនោះ។ នៅក្នុងសៀវភៅរបស់លោក លោកបាននិយាយអំពីអតីតកាលដែលច្របូកច្របល់រវាងវៀតណាម ហើយនិងខ្មែរ ហើយនិងប្រទេសជិតខាង។ អ៊ីចឹងសំណួរជាក់លាក់របស់ខ្ញុំ ១ចង់ដឹងថាតើលោកមានបានស្រាវជ្រាវជាក់លាក់មួយទាក់ទងនឹងជម្លោះតាមព្រំដែនដែរឬទេ បន្ទាត់ព្រំដែនដែរឬទេ? ឧទាហរណ៍ដូចជាបន្ទាត់ប្រេវីយ៉េជាដើមនេះ ឬក៏ប្រធានបទនេះ វាមិនមែនជាអ្វីដែលធ្វើឲ្យលោកចាប់អារម្មណ៍នោះទេ?

**ឆ៖** នេះមិនមែនជាអ្វីមួយដែលខ្ញុំមានការពាក់ព័ន្ធជាមួយនោះទេ។

**ស៖** ជាទូទៅខ្ញុំ -- <ខ្ញុំនឹងនិយាយអំពី>បញ្ហាកម្ពុជា<>ជាមួយនឹងវៀតណាម<> ឬក៏ជាមួយនឹងប្រទេសថៃ<> បញ្ហាព្រំដែននេះជាទូទៅនេះមិនមែនជាកម្មវត្ថុនៃការស្រាវជ្រាវរបស់លោកទេ អ៊ីចឹង

ឬក៏យ៉ាងណា? ពីព្រោះថាអម្បាញ់មិញនេះ គេបានផ្តល់ទូរលេខជាច្រើនជូនលោក ពាក់ព័ន្ធទៅនឹងបញ្ហាព្រំដែនជាមួយថៃ ជាទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ហើយលោកបានឆ្លើយថា នេះមិនមែនជាកម្មវត្ថុនៃការស្រាវជ្រាវរបស់លោកទេ។ តើឲ្យតែទាក់ទងនឹងជម្លោះព្រំដែននេះ មិនមែនជាកម្មវត្ថុនៃការស្រាវជ្រាវរបស់លោកទេឬ?

[១១:១៦:២៨]

**ឆ៖** អត់ទេ ប្រហែលជា<ខ្ញុំនិយាយមិនខុស។> មិនមែនដោយសារថា វាមិនមែនផ្នែកមួយនៃការស្រាវជ្រាវរបស់ខ្ញុំនោះទេ វាគ្រាន់តែមិនមែនជាការយកចិត្តទុកដាក់ចម្បងរបស់ខ្ញុំតែប៉ុណ្ណោះ អ្នកដទៃទៀតប្រហែលជាគេអាចមានឯកសារនេះ។ ប៉ុន្តែមិនត្រឹមត្រូវទេការដែលនិយាយថា វាមិនមែនជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំនោះ។

**ស៖** បញ្ហាព្រំដែននេះ ដើម្បីឲ្យច្បាស់លាស់ជាងនេះទៅទៀតនោះ តើនៅក្នុងការស្រាវជ្រាវរបស់លោកនោះ លោកមានបានសួរសំណួរខ្លួនឯង ថាតើគោលជំហររបស់ថៃ របស់ខ្មែរ របស់វៀតណាមនោះ ទាក់ទងទៅនឹងការគូសកំណត់ព្រំដែនអីជាដើម <ដែលបន្សល់ទុកតាំងពីជំនាន់អាណានិគមមកនោះ?> គឺទាក់ទងនឹងជម្លោះព្រំដែនហ្នឹង ហើយនិងការពិភាក្សាគ្នារវាងប្រទេសទាំងអស់ហ្នឹង អំពីបញ្ហាព្រំដែនហ្នឹង តើលោកដឹងអីខ្លះដែរ?

**ឆ៖** ខ្ញុំបានអានអំពីបញ្ហានេះ ក៏ប៉ុន្តែអ្វីដែលជាការផ្តោតការយកចិត្តទុកដាក់របស់ខ្ញុំនោះ គឺថាបញ្ហាជម្លោះព្រំដែននេះ គឺជាការបញ្ជាក់ឲ្យឃើញនូវបញ្ហានយោបាយដ៏ជ្រាលជ្រៅ បញ្ហាជម្លោះតាមព្រំដែនគឺវាមិនមែនជាមូលហេតុ ដ៏ជ្រាលជ្រៅនោះទេ។ ក៏ប៉ុន្តែខ្ញុំដឹងពីបញ្ហាថា កម្ពុជាមានជម្លោះព្រំដែនជាមួយនឹងវៀតណាម។

[១១:១៨:២៩]

**ស៖** ខ្ញុំមិនដឹងថា លោកបានអានរបាយការណ៍មួយដែលសរសេរនៅថ្ងៃទី២០ សីហា ឆ្នាំ ១៩៧៥ ដោយស្ថានទូតអូស្ត្រាលីនៅហាណូយដែរឬទេ ក៏ប៉ុន្តែបញ្ហានៃឥទ្ធិពលរបស់វៀតណាមមកលើប្រទេសកម្ពុជាហ្នឹង គឺបានធ្វើឡើងដោយអ្នកសង្កេតការណ៍ជាច្រើន។ គឺឯកសារ E3/9723, ERN ជាភាសាអង់គ្លេសគឺ 01186945, ERN ជាភាសាខ្មែរគឺ 01310869 អត់មាន ERN ជាភាសាបារាំងទេ។ អ្វីដែលខ្ញុំចាប់អារម្មណ៍គឺកថាខណ្ឌ១៤ នៃសារណាមួយដែលស្ថានទូតអូស្ត្រាលីបញ្ជូនទៅក្រសួងការបរទេស។ គេបានសង្ខេបអំពីហានិភ័យដែលអាចកើតឡើង។ នៅកថាខណ្ឌ១៤នៃសារណាហ្នឹង ខ្ញុំសូម

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដកស្រង់ជាភាសាអង់គ្លេស៖ “លើសពីនេះទៅទៀត មានការសង្ស័យពាក់ព័ន្ធទៅនឹង<សេចក្តីប្រាថ្នារបស់វៀតណាមក្នុង>ការបង្កើតនូវបក្សកុម្មុយនីស្តឥណ្ឌូចិនដែល<គេជឿជាក់ថា>កម្ពុជា<មិនអាចទទួលយកបានទេ។ មូរេល្វ បាននិយាយថា គាត់>ជឿថាវៀតណាមនឹងមិនធ្វើដំណើរទៅមុខបានពេញលេញ រហូតដល់ពេល<>ពាក្យសុំទៅដល់អង្គការសហប្រជាជាតិ<របស់ខ្លួន និងប្រទេសមិនចូលបក្សសម្ព័ន្ធលែងជាបញ្ហាតទៅទៀតសិន>។ (ឡូច ក៏បាននិយាយផងដែរ<ថា> នេះគឺជាអាទិភាពរបស់វៀតណាម។) ការដែលនិយាយបែបនេះ គឺថាមហិច្ឆតាវៀតណាម ពិតជាមាន <ក៏ប៉ុន្តែ>ពេលវេលានេះ<មិនសមស្របសម្រាប់ធ្វើឲ្យពួកគេក្លាយជាទីគាប់ចិត្តចំពោះ>ប្រទេសកម្ពុជា<ទេ>។”

អ៊ីចឹងសំណួររបស់ខ្ញុំថា នៅក្នុងការស្រាវជ្រាវរបស់លោកនោះ តើលោកមានធ្លាប់បានសង្កេតមើល ព្រួយបារម្ភ ឬក៏ការសង្កេតដែលធ្វើឡើងដោយឯកអគ្គរដ្ឋទូតអូស្ត្រាលីដែរឬទេ? ហើយទូតផ្សេងទៀតនោះ គេមានបានលើកឡើងពីការព្រួយបារម្ភហ្នឹងដែរឬទេ? ហើយលោកមានបានជួបប្រទះនឹងឯកសារដែលលើកឡើងពីចំណុចនេះ នៅបណ្ណសារសូវៀតដែរឬទេ?

[១១:២១:០៩]

**ឆ៖** ខ្ញុំយល់ឃើញថា មានការពិភាក្សាគ្នាកាលពីម្សិលមិញនេះរួចមកហើយ ពីក្នុងសៀវភៅរបស់ខ្ញុំដែលខ្ញុំដកស្រង់សម្តីអាជ្ញាធររុស្ស៊ីនិយាយអំពីបក្សកុម្មុយនីស្តឥណ្ឌូចិន<នៅឆ្នាំ១៩៧៣>។ ក្រៅពីនេះ ខ្ញុំមិនបានរកឃើញព័ត៌មានណាមួយអំពីសម្ព័ន្ធឥណ្ឌូចិនពីស្ថានទូតណាមួយ ឬពីប្រទេសណាមួយនោះទេ។

**ស៖** ឥឡូវត្រឡប់មកនិយាយអំពីផ្នែកមួយចំនួននៃសៀវភៅរបស់លោកនោះ គឺលោកបាននិយាយអំពីដំណាក់កាលផ្សេងៗ នៃអាកប្បកិរិយារបស់ប្រទេសវៀតណាមក្នុងការគ្រប់គ្រងជម្លោះជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ។ ហើយលោកបាននិយាយផងដែរ ជាមួយសហព្រះរាជអាជ្ញាកាលពីម្សិលមិញនោះ អំពីការវិវត្តភាសាប្រើប្រាស់ជាដើម។ <គាត់បានធ្វើការដកស្រង់សម្រង់មួយដែលធ្វើពី>កម្ពុជាប្រជាធិបតេយ្យ <ទៅ>អាជ្ញាធរភ្នំពេញ ហើយនិងបនប៉ុល ពត, អៀង សារី អីជាដើមនេះ។ អាហ្នឹងគឺយើង គេហៅថា អាហ្នឹងការឃោសនាការ គឺគេប្រើភាសាអ៊ីចឹងឯង។ អ៊ីចឹងសំណួរខ្ញុំនោះ ខ្ញុំសួរលោកថាតើការប្រើពាក្យពេចន៍ទាំងអស់នេះ <>មានញឹកញាប់<ទេ>នៅពេលសង្គ្រាមត្រជាក់ហើយនិង<នៅក្នុងប្រទេសកុម្មុយនីស្ត?> ហើយ<តើនេះជា>ការប្រើប្រាស់<ភាសាទូទៅនៅពេលដែលមាន>ការវិវត្តន៍នៃសម្ព័ន្ធមិត្ត សម្ព័ន្ធភាពអីជាដើមហ្នឹង <>ឬក៏យ៉ាងម៉េច?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ គឺវាផ្ទុះបញ្ចាំងយ៉ាងដូច្នេះ។ លោកស្រីអាចរកឃើញថា សូវៀតបានរៀបរាប់ពាក់ព័ន្ធទៅនឹងប្រទេសយូហ្គោស្លាវី មុន<និងក្រោយ>ពេលដែល ទីតូ នេះ គាត់បានផ្ដាច់ខ្លួន បំបែកខ្លួនចេញពីសូវៀត នៅក្នុងឆ្នាំ១៩៤៨។ អ៊ីចឹងសារនេះ បញ្ជាក់ច្បាស់ណាស់អំពីឥរិយាបថមួយនេះ។

[១១:២៣:៤១]

**ស៖** នៅក្នុងសៀវភៅរបស់លោក គឺនៅទំព័រ១០៥ នៃឯកសារ <E3/7338>, ERN ជាភាសាអង់គ្លេសនៅចុងទំព័រគេ គឺ01001772 លោកនិយាយពីដើមឆ្នាំ១៩៧៨។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ "នៅក្នុងរយៈពេល៤ខែដំបូងនៅឆ្នាំ៧៨ វៀតណាមបានបង្កើត<ជំរំ>បណ្ដាញសម្ងាត់ដើម្បីគោលបំណងនៃការកសាងកងទ័ព<រំដោះ>នៅក្នុងចំណោមជនភៀសខ្លួនដែលបាននាំខ្លួនពីកម្ពុជារត់ចូលទៅក្នុងប្រទេស វៀតណាមនោះ។"

លោកក៏បានលើកឡើងផងដែរ គឺនៅទំព័រ១០៩, ERN គឺ 01001776។ លោកបាននិយាយអំពីកិច្ចប្រជុំ កញ្ញា ឆ្នាំ១៩៧៨ រវាង ឡេ យន់ ហើយនិងឯកអគ្គរដ្ឋទូតសូវៀត។ ERN គឺ01001776 សូមដកស្រង់ជាភាសាអង់គ្លេស៖ "ឡេ យន់ ក៏បាននិយាយថា វៀតណាមទទួលខុសត្រូវ និងលើកស្ទួយទៅដល់ចលនាតស៊ូរបស់កម្ពុជា ដែលថាមានកងវរសេនាតូច<ខ្មែរ>ចំនួនប្រាំបួន ដែលបណ្ដុះបណ្ដាលដោយវៀតណាម ដើម្បីធ្វើប្រតិបត្តិការនាពេលនោះ។ ហើយគេក៏មានការបណ្ដុះបណ្ដាលមេបញ្ជាការថ្នាក់ស្រុក<២០នាក់ ប្រឆាំងនឹងរបបភ្នំពេញ> ហើយដែលអ្នកដែលបណ្ដុះបណ្ដាលទាំងអស់នេះ មានសមានចិត្តជាមួយនឹងវៀតណាម។"

អ៊ីចឹងសំណួរខ្ញុំ ១ចង់ដឹងថា យើងយល់ហើយថា លទ្ធផលនៃការពិភាក្សារវាង ឡេ យន់ ហើយនិងឯករដ្ឋទូតរុស្ស៊ីហ្នឹង តែខ្ញុំចង់សួរលោកថា ក្នុងការស្រាវជ្រាវរបស់លោកនោះ តើលោកមានបានជួបប្រទះនឹងបញ្ហាពាក្យដែលថាមានកងពលចំនួនប្រាំបួន ហើយនិងមានចៅហ្វាយស្រុកហ្នឹងចំនួន២០ដែលអាចនឹងចូលរួមជាមួយកងទ័ពវៀតណាម នៅពេលដែលវៀតណាមសម្រេចចិត្តមកវ៉ៃចូលប្រទេសខ្មែរ?

**ឆ៖** ខ្ញុំអត់មានព័ត៌មានលម្អិតនោះទេ។ បើសិនណាខ្ញុំមានព័ត៌មានលម្អិត ខ្ញុំយកមកសរសេរហើយ។ បើមិនបានសរសេរនៅក្នុងសៀវភៅនេះ ក៏សរសេរនៅលេខយោងជើងទំព័រដែរ។

[១១:២៦:៣៣]

**ស៖** នៅក្នុងសៀវភៅរបស់លោកហ្នឹង លោកបាននិយាយអំពីការខិតចូលគ្នារវាងវៀតណាមហើយនិងសហភាពសូវៀត បន្ទាប់ពីឃើញថា ចិននិងវៀតណាមហ្នឹងត្រូវគ្នា។ <>ហើយក្រោយមក

ចិនថា វៀតណាមហ្នឹងរមិលគុណ។ នៅក្នុងសៀវភៅលោក ៗបានសរសេរថា ការពិភាក្សាគ្នាដែលកើតចេញជាកតិកាសញ្ញាមិត្តភាពរវាងមូស្គូ ហើយនិងហាណូយ បានប្រព្រឹត្តឡើងនៅឆ្នាំ១៩៧៨។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសដែរគឺ ERN 01001775 ERN ជាភាសាអង់គ្លេស។ "នេះមិនមែនជាការពិភាក្សាដោយបើកចំហនោះទេ។ គោលបំណងនៃកិច្ចប្រជុំនោះគឺដើម្បី<ឲ្យវៀតណាមអាច>ធានាថាសូវៀតមានការគាំទ្រទាំងនយោបាយនិងយោធា<ទៅថ្ងៃមុខ> ឬក៏យ៉ាងហោចណាស់ដើម្បីឲ្យសូវៀតមានការគាំទ្រ ក្រែងមានការវាយបកសងសឹកណាមួយពីសំណាក់ប្រទេសចិន។ ប៉ុន្តែការពិតនេះគឺថាមិនបានបង្ហាញឲ្យគេដឹងទេ។ ប៉ុន្តែសន្និសញ្ញានៃកិច្ចសហប្រតិបត្តិការ និងមិត្តភាព<គឺបានចុះហត្ថលេខា> នៅទីក្រុងមូស្គូនៅខែវិច្ឆិកា។" បញ្ចប់ការដកស្រង់។

អ៊ីចឹងឆន្ទៈនៃការខិតចូលជិតសហភាពសូវៀតរបស់វៀតណាមនេះ ដើម្បីប្រឆាំងទៅនឹងមហាចិននេះ តើវាមានបង្ហាញអំពីយុត្តិសាស្ត្រវៀតណាមដែរឬទេ? តើនៅក្នុងគោលការណ៍ខិតចូលជិតសហភាពសូវៀតនេះ នៅក្នុងការស្រាវជ្រាវរបស់លោកនោះ តើលោកមានរកឃើញព័ត៌មានណាមួយដែលពាក់ព័ន្ធ<នឹងការវាយប្រហារការទូតដែលវៀតណាមបានប្រើ> មុនពេលវាយលុកចូលកម្ពុជាប្រជាធិបតេយ្យ<ដែរឬទេ>? <ហើយអ្នកណាខ្លះជាសម្ព័ន្ធមិត្តការទូតនៅពេលនោះ គឺនៅចុងឆ្នាំ១៩៧៧ និងក្នុងអំឡុងឆ្នាំ១៩៧៨>?

[១១:២៩:៣៨]

**ឆះ** ខ្ញុំមិនបានសិក្សាអំពីកិច្ចការទូតនេះទេ ប៉ុន្តែវៀតណាមចាត់ទុកថា វាជាសេចក្ដីសង្ឃឹមដ៏ប្រសើរបំផុតដើម្បីសម្រេចបាននូវទិសដៅរបស់ខ្លួន<នៅក្នុងប្រទេសកម្ពុជា> ដើម្បីឲ្យមានការគាំទ្រពីខាងប្លុកសូវៀត គឺដោយសារថាសូវៀតហ្នឹង គឺមានការឥទ្ធិពលនៅអឺរ៉ុបខាងកើតនោះជាពិសេស។ ខ្ញុំដឹងអំពីការឃោសនារបស់វៀតណាមនៅពេលនោះ ក៏ប៉ុន្តែមិនដឹងអំពីការខិតខំប្រឹងប្រែងតាមការទូតជាមួយនឹងប្លុកណាមួយនោះទេ ក៏ប៉ុន្តែខ្ញុំដឹងថា វៀតណាមខិតខំប្រឹងប្រែងដើម្បីឲ្យទទួលបានការគាំទ្រពីមតិអន្តរជាតិ<ប្រឆាំងនឹងថ្នាក់ដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធានខ្ញុំមើលទៅឃើញម៉ោងដប់មួយកន្លះហើយ តើលោកប្រធានចង់សម្រាកក្នុងពេលនេះសិន ព្រោះថាខ្ញុំត្រូវចូលទៅប្រធានបទផ្សេងទៀតដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោក អង់តា ហ្គីសសេ ត្រូវការប្រើពេលវេលាប្រហែលប៉ុន្មានទៀត ទំនង?

[១១:៣១:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំត្រូវការពេលដែលថា លោកប្រធានកំណត់ឲ្យខ្ញុំប្រើប្រាស់ហ្នឹងគឺថា បើតាមក្នុងការគណនារបស់ខ្ញុំគឺថានៅសល់២៥នាទីទៀត។ ខ្ញុំដឹងហើយថាការគណនារបស់ក្រុមខ្ញុំ ហើយនិងខាងអង្គជំនុំជម្រះហ្នឹងពេលខ្លះអាចខុសគ្នាដែរ។ <ប៉ុន្តែ តាមការគណនារបស់ខ្ញុំ គឺខ្ញុំនៅសល់>ពេល២៥នាទីទៀត លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អរគុណលោកអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះ រសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីជំនាញរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តី

ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក ម៉ូរីស។ មុនពេលសម្រាកនេះ ខ្ញុំបានឈប់នៅត្រង់សំណួរការវាយប្រហារផ្នែកការទូតវៀតណាម។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយពីចំណុចមួយដែលខ្ញុំភ្លេចនិយាយឱ្យបានលម្អិតពីប្រទេសមិនចូលបក្សសម្ព័ន្ធ។ កាលនោះ បើតាមខ្ញុំមិនច្រឡំទេគឺថានិយាយអំពីទូតអូស្ត្រាលីដែលនិយាយថា ចំពោះប្រទេសវៀតណាមហ្នឹងជាការសំខាន់ណាស់ក្នុងការឱ្យអង្គការសហប្រជាជាតិទទួលស្គាល់ ហើយនិងប្រទេសមិនចូលបក្សសម្ព័ន្ធទទួលស្គាល់។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើហេតុអ្វីបានជាមានសារៈសំខាន់ដូច្នេះ នៅក្នុងពេលសង្គ្រាមត្រជាក់នោះ? តើបញ្ហាប្រឈម ឬក៏ការខាត ឬចំណេញរបស់វៀតណាមនោះ វាមានសារៈសំខាន់យ៉ាងណាដែរដើម្បីចូលទៅជាសមាជិកនៃប្រទេសមិនចូលបក្សសម្ព័ន្ធនោះ?

[១៣:៣២:៤៩]

**លោក ស្ទីហ្វិន ម៉ូរីស៖**

**ឆ៖** ជាការសំខាន់ផ្នែកការទូតសម្រាប់វៀតណាមចូល ព្រោះថាវាមានការប្រកួតប្រជែងស្វែងរកភាពស្របច្បាប់ជាអន្តរជាតិ ក៏ដូចជាផែនការដើម្បីឱ្យកម្ពុជា<ហ្នឹងវា>ស្របច្បាប់ជាលក្ខណៈអន្តរ-ជាតិ ដើម្បីឱ្យកម្ពុជាអាចបន្តដំណើរទៅមុខបានដោយខ្លួនឯង។

**ស៖** ចំណុចមួយទៀតទាក់ទងទៅនឹងទំនាក់ទំនងការទូតរបស់ប្រទេសវៀតណាមដែរ តើទំនាក់ទំនងរបស់ប្រទេសវៀតណាមជាមួយអាល្លឺម៉ង់ខាងកើតហ្នឹង យ៉ាងណាដែរ?

**ឆ៖** លោកស្រីនិយាយអំពីចុងទសវត្សរ៍ឆ្នាំ៧0មែនទេ? ប្រសិនបើអ៊ីចឹងមែន គឺថាទំនាក់ទំនងជាមួយអាល្លឺម៉ង់ខាងកើតហ្នឹង គឺជិតស្និទ្ធគ្នាខ្លាំង។

**ស៖** ទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយអម្បាញ់មិញនេះ ទាក់ទងទៅនឹងការឃោសនា<របស់វៀតណាម> ទាក់ទងនឹងការវាយលុកចូលប្រទេសកម្ពុជានេះ នៅក្នុងសំណុំរឿងយើងហ្នឹង គឺយើងមានរបាយការណ៍មួយដែលនិយាយអំពីការពិភាក្សាគ្នារវាងកម្ពុជា<ប្រជាធិបតេយ្យ> និងវៀត-ណាម គឺឯកសារE3/1773 គឺជាឯកសារដែលចេញមកពីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់។ មានរបាយការណ៍ជាច្រើនដែលចុះនៅដើមខែ<មករា> ឆ្នាំ១៩៧៨ គឺមានការចេញផ្សាយនៃសេចក្តីប្រកាសមួយរបស់ប្រទេសវៀតណាមនៅសម័យនោះ នៅពេលនោះ។ ទំព័រដែលខ្ញុំចាប់

អារម្មណ៍ជាទំព័រអង់គ្លេសនោះ ខ្ញុំមានតែជាភាសាអង់គ្លេសទេ គឺERN 01246920។ របាយការណ៍ហ្នឹងចុះថ្ងៃទី<>០១ មករា ឆ្នាំ១៩៧៨។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

[១៣:៣៥:៥៧]

"<ចន្លោះថ្ងៃទី០៤ និង>ថ្ងៃ១១ មករា" – ខ្ញុំគិតថា ប្រហែលជា<សាធារណរដ្ឋសង្គមនិយម>វៀតណាម<> តាមមើលពាក្យហ្នឹង – "អ្នកតំណាងប្រទេសសង្គមនិយម ប្រទេសអភិវឌ្ឍ និងប្រទេសមូលធននិយម បានចេញនូវសេចក្តីប្រកាសរបស់រដ្ឋាភិបាល នៅថ្ងៃ<៣១> ធ្នូ ឆ្នាំ៧៧។ <(ធ្វើឡើងម្តងទៀត>នៅ<ថ្ងៃ>១១-១-<៧៨)> បងប្អូនប្រទេសជាមិត្តសង្គមនិយមត្រូវបានចាត់ទុកថាជា អេស.អ័រ.វី។ ប្រជាជនសាធារណរដ្ឋប្រជាមានិតចិនគាំទ្រ<ជំហរ>របស់<កម្ពុជាប្រជាធិបតេយ្យ> ហើយនិងផ្សព្វផ្សាយអំពីរដ្ឋាភិបាល អេស.អ៊ែ.វេ នៅថ្ងៃ<៣១> ធ្នូ ៧៧។ អេស.អ៊ែ.វេ បានផ្សព្វផ្សាយទៅដល់<សាធារណរដ្ឋប្រជាមានិត>ចិន វាជាការមិនល្អដែលថាបក្សបាន<រាយការណ៍ និង>ស្នើសុំ<ឲ្យរបាយការណ៍អំពី>ជម្លោះ<ដែលកើតមានឡើងត្រូវធ្វើឡើងឲ្យបានត្រឹមត្រូវ>។ នៅពេលដែលចាប់ផ្តើមជម្លោះ គឺ<សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យ>កូរ៉េបានធ្វើការ<លម្អៀងទៅរកសេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងការបោះពុម្ពផ្សាយរបស់ខ្លួន>។ ឯកអគ្គរដ្ឋទូត អេស.អ៊ែ.វេ បាន<ជំទាស់ពីសេចក្តីរាយការណ៍មិនត្រឹមត្រូវ>នេះ។"

ខ្ញុំមានផ្នែកមួយដែលត្រូវដកស្រង់ដែរ។ ឥឡូវខ្ញុំសូមដកស្រង់ផ្នែកទី២ សម្រាប់អ្នកបកប្រែបារាំង គឺ ERN 01246922។ តាមសារណាអាល្លឺម៉ង់ដដែលនេះ គឺមានសរសេរដូចតទៅ៖ "សូវៀត ហ្សេ.ដេ.អ៊ែ និង សេ.អេស.អេស.អ៊ែ គឺសាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី បានគាំទ្រគោលជំហររបស់ អេស.អ៊ែ.វេ ក្នុងការផ្សព្វផ្សាយជាសាធារណៈ។"

អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ ប៉ុន្តែឥឡូវសំណួរទី១ ថាតើលោកស្គាល់ឯកសារហ្នឹងដែរឬទេ? ហើយបើមិនស្គាល់ឯកសារហ្នឹង គឺថាតើ<>លោកមានជួបប្រទះឯកសារខ្លឹមសារប្រកាសដូចគ្នា<ទៅនឹងអ្វីដែលវៀតណាមបានប្រកាស ដើម្បីបង្ហាញពីការយល់ឃើញរបស់ខ្លួន ចំពោះព្រឹត្តិការណ៍ដែលកើតឡើងនោះ>ទេ ពេល<>ដែលលោកស្រាវជ្រាវហ្នឹង?

[១៣:៣៩:១៧]

**ធ៖** ខ្ញុំមិនដែលស្គាល់ មិនដែលឃើញលិខិតនេះទេ ឯកសារនេះទេ ប៉ុន្តែខ្ញុំគិតថា ទាំងចិន ក៏ដូចជាសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ <កូរ៉េខាងជើង> គឺថាជាសម្ព័ន្ធភាពជាមួយកម្ពុជា<ប្រជាធិបតេ-

យ្យ>នៅពេលនោះ។ ដូច្នេះហើយ គឺពួកគេគាំទ្រកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលមានជម្លោះជាមួយវៀតណាម។

**ស៖** នៅក្នុងឯកសារនោះ មានសរសេរថា សេចក្ដីប្រកាសចុះថ្ងៃទី៣១ ធ្នូ ឆ្នាំ១៩៧៧នោះ ត្រូវបានផ្សព្វផ្សាយទូលំទូលាយ ដោយប្រទេសវៀតណាម មិនត្រឹមតែទៅដល់ប្រទេសមិនចូលបក្សសម្ព័ន្ធទេ ហើយឬក៏អ្នកដែលនៅខាងខ្លួននោះទេ ក៏ប៉ុន្តែថែមទាំងផ្សព្វផ្សាយទៅដល់ប្រទេសដទៃផ្សេងទៀតផង។ តើចំណុចនេះលោកមានបានរកឃើញនៅក្នុងការស្រាវជ្រាវរបស់លោកដែរឬទេ? តើក្នុងចំណោមឯកសារនៃសហភាពសូវៀតដែលលោកបានពិគ្រោះហ្នឹងមានចំណុចហ្នឹងទេ មានខ្លឹមសារថាវៀតណាមផ្សព្វផ្សាយទូលំទូលាយអ៊ីចឹងទេ?

**ឆ៖** ខ្ញុំមិនមានព័ត៌មានទាំងអស់នេះនៅក្នុងបណ្ណសាររបស់សូវៀតទេ ប៉ុន្តែខ្ញុំដឹងអំពីយុទ្ធនាការឃោសនាការរបស់វៀតណាម គឺថាទាំងសងខាងបានធ្វើទាំងអស់គ្នា ទាំងវៀតណាមក៏ដូចជាកម្ពុជាប្រជាធិបតេយ្យព្យាយាមស្វែងរកការគាំទ្រជាអន្តរជាតិទៅលើគោលជំហររបស់ខ្លួន។

**ស៖** ទាក់ទងទៅនឹងគោលជំហរការទូតរបស់វៀតណាមចំពោះប្រទេសកម្ពុជា ខ្ញុំចង់សំដៅទៅលើទំនាក់ទំនងពិសេសមួយ តើលោកអាចនិយាយបានដែរឬទេថា វៀតណាមមានប្រៀបជាងក្នុងការទាក់ទងប្រទេសមិនចូលបក្សសម្ព័ន្ធ ឬក៏វៀតណាមនេះគេមានបទពិសោធន៍ច្រើនជាង ទាក់ទងទៅនឹងការគ្រប់គ្រងការទូតច្រើនជាងកម្ពុជា? ឬក៏លោកលោកយល់ខុសពីនេះ?

[១៣:៤១:៣៩]

**ឆ៖** ខ្ញុំគិតថាវៀតណាមងាយស្រួលជាងក្នុងការជួបជាមួយនឹងប្រទេសដែលមិនមែនជាសម្ព័ន្ធមិត្ត ព្រោះវៀតណាមមានទំនាក់ទំនង<ការទូត>ជាប្រវត្តិសាស្ត្រជាមួយប្រទេសច្រើន<ជាង>។ ចំពោះកម្ពុជាប្រជាធិបតេយ្យគឺតែងតែបិទបាំង ឬក៏មិនបើកចំហខ្លួនជាមួយនឹងប្រទេសដទៃទៀតឡើយ គឺមានទំនាក់ទំនងតែជាមួយប្រទេសចំនួនប្រាំបីប៉ុណ្ណោះ។ ប្រាកដណាស់ថា កម្ពុជាប្រជាធិបតេយ្យ គឺមានទំនាក់ទំនងជិតស្និទ្ធជាងគេជាមួយចិន ហើយកូរ៉េខាងជើង ហើយនិងប្រទេសអេហ្ស៊ីបផងដែរ ក្រៅពីនេះនៅមានប្រទេសមួយចំនួនតូចទៀតដែលមានទំនាក់ទំនងការទូតជាមួយកម្ពុជាប្រជាធិបតេយ្យ។ ចំណែកវៀតណាមវិញគឺមានទំនាក់ទំនងការទូតច្រើនជាងឆ្ងាយ ដូច្នេះវៀតណាមមានភាពងាយស្រួលជាងក្នុងការស្វែងរកឥទ្ធិពលគាំទ្រ។

**ស៖** មានចំណុចមួយទៀតដែរ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ ថាតើ

លក្ខខណ្ឌនៃការចរចាគ្នាអង្កាល់ណោះនោះ មានលក្ខណៈយ៉ាងណាដែរ? ព្រោះថាអង្កាល់នុំងមានសង្គ្រាមការទូតផង ហើយនិងសង្គ្រាមនៅនឹងកន្លែងផង តាមមូលដ្ឋានផង តើរវាងអ្នកទាំងអស់គ្នាហ្នឹងកាលពេលមួយនោះ គេចង់ចរចាគ្នា តើលោកនៅចាំទេ អង្កាល់ណោះលក្ខខណ្ឌនៃការចរចាគ្នាហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំភ្លេចអំពីលក្ខខណ្ឌនៅពេលនោះហើយ។

[១៣:៤៣:៣០]

**ស៖** នៅក្នុងឯកសារដដែលហ្នឹង នៅលេខ ERN 01246921 មិនមែនកន្លែងហ្នឹងទេ ខ្ញុំនឹងរកឯកសារហ្នឹងឃើញ។ ឥឡូវខ្ញុំសូមចូលទៅនិយាយពីចំណុចផ្សេងសិន។ លោកបាននិយាយអំពីឆន្ទៈរបស់ប្រទេសវៀតណាមនៅពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញានេះ គឺឆន្ទៈរបស់វៀតណាមក្នុងការចរចាគ្នា បើតាមខ្ញុំយល់ បើសិនជាខ្ញុំច្រឡំសូមកែខ្ញុំផង។ បើតាមការយល់ឃើញរបស់លោកនោះ គឺថាកម្ពុជាប្រជាធិបតេយ្យទេដែលជំទាស់ដាច់ខាតមិនព្រមចរចានោះ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ? លោកនិយាយអ៊ីចឹងមែន ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំគិតថាវៀតណាមមានចេតនាចរចានៅឆ្នាំ៧៧ ប៉ុន្តែគេផ្លាស់ប្តូរចិត្តរបស់គេវិញនៅចុងឆ្នាំ៧៧។ លក្ខខណ្ឌដែលភាគីទាំងពីរបានដាក់គឺថាខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែលក្ខខណ្ឌនុំងគឺថា ភាគីនីមួយៗពិបាកក្នុងការគោរពតាម។ ដូច្នេះតាមខ្ញុំយល់ គឺថាទាំងសងខាង គឺថាមានការលំបាកក្នុងការសម្រេចក៏ដូចជានៅក្នុងគោលជំហរការទូតចំពោះភាគីម្ខាងទៀត។

**ស៖** លោកបាននិយាយពីឯកសារនេះជាមួយនឹងលោកមេធាវី នួន ជា ហើយនិងសហព្រះរាជអាជ្ញាផងដែរ គឺថានិយាយពីរឿង ដូក្លាស នៅចំពោះមុខសមាជ។ ឯកសារ E3/2370 គាត់បានសង្ខេបអំពីគោលជំហររបស់គ្រប់គ្នា នៅ ERN ជាភាសាបារាំងគឺ 00344745, ERN ជាភាសាអង់គ្លេសគឺ 00187393។ គាត់លើកឡើងដូចតទៅនេះ៖ "វៀតណាមបាននិយាយក្រៅផ្លូវការថា គេមិនដកកម្លាំងគេចេញទេ មុនពេលចាប់ចរចាគ្នា។ ប្រទេសកម្ពុជាមិនព្រមចរចាទេ នៅពេលដែលកម្លាំងវៀតណាមមិនព្រមចេញពីប្រទេសកម្ពុជា។ ស្ថានភាពនេះគួរតែអាចជៀសបាន វៀតណាមដកកម្លាំងខ្លួនចេញទៅ <សំអាងលើអង្គហេតុថាពួកគេមិនដែលឈ្លានពានកម្ពុជាពីមុនមកទេ> ហើយប្រទេសកម្ពុជាហ្នឹងគួរតែអះអាងថា បានដេញវៀតណាមចេញហើយ<ដោយមិនចាំបាច់បានធ្វើដូច្នោះឡើយ>។ ហើយក្រោយមកអាចចរចាគ្នាបានទៅហើយ ក៏ប៉ុន្តែគេមិនបានធ្វើយ៉ាងដូច្នេះទេ"។ <បញ្ចប់ការដកស្រង់។>

[១៣:៤៦:៥០]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា ចាំបាច់ត្រូវបញ្ជាក់ឲ្យបានច្បាស់ដែលថា សំណួរដែលខ្ញុំបានសួរកាលពីម្សិលមិញហ្នឹង គឺទាក់ទងទៅនឹងចេតនារបស់វៀតណាមក្នុងការចរចា គឺនៅមុនចុងឆ្នាំ៧៨ គឺនៅមុនការឈ្លានពានឆ្នាំ ៧៨ មិនមែននៅពីក្រោយ មិនមែននៅក្រោយពេលឈ្លានពានឆ្នាំនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

<មិនមានបញ្ហាទេ។> ខ្ញុំបញ្ជាក់កាលបរិច្ឆេទច្បាស់ហើយ កាលបរិច្ឆេទនៃឯកសារ អ៊ីចឹងអ្នកជំនាញគាត់ដឹងច្បាស់ហើយពីអ្វីដែលខ្ញុំនិយាយ ហើយគាត់ក៏បានលើកឡើងដែលថា គោលជំហររបស់វៀតណាមហ្នឹងវិវត្ត។ <អ៊ីចឹង វាមិនគួរជាបញ្ហាទេ។>

[១៣:៤៧:៥០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ទាក់ទងទៅនឹងគោលជំហររបស់វៀតណាមនៅដើមឆ្នាំ៧៨ មានឯកសារមួយទៀត ហើយបន្ទាប់មកខ្ញុំចោទសំណួរបើកទូលាយ។ គឺសម្រង់នៃសៀវភៅរបស់ ណាយ៉ាន់ ចាន់ដា "សត្រូវ" ឯកសារ E3/2376, ERN ជាភាសាបារាំងគឺ 00237080, ជាភាសាខ្មែរគឺ 00191550, ERN ជាភាសាអង់គ្លេសគឺ 001922401*(ស៊ីក)*។ ណាយ៉ាន់ ចាន់ដា បាននិយាយដូចតទៅនេះ៖ "ថ្ងៃទី០៥ កុម្ភៈ ឆ្នាំ ១៩៧៨ វិទ្យុហាណូយបានចេញជាសាធារណៈអំពីការដោះស្រាយបញ្ហាកម្ពុជា ជាបីចំណុចគឺ ដកកម្លាំងកងទ័ពដែលមានវត្តមាននោះចេញឲ្យបាន<៥>គីឡូម៉ែត្រ ហើយចុះហត្ថលេខាពីការឈប់រំលោភបំពាន ហើយនិងចុះហត្ថលេខាលើអនុសញ្ញាព្រំដែន។ យើងទទួលស្គាល់<តាមរយៈមន្ត្រីម្នាក់របស់>វៀតណាមថា <ខ្មែរក្រហម>មិនទទួលស្គាល់ទេ<គោលជំហរបែបហ្នឹង> ក៏ប៉ុន្តែ<យ៉ាងហោចណាស់>ទំនួលខុសត្រូវនៃការ<បដិសេធនឹងគម្រោងហ្នឹងគឺអាស្រ័យទៅលើពួកគេ>។ អ៊ីចឹងរឿងរ៉ាវនោះបើកឱកាសឲ្យមានការឃោសនាការជ្រុលហួសហេតុមួយ តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ បណ្ដាប្រទេសនៅក្នុងប្លុក<សូវៀតនឹង>យល់ស្របតាមផែនការរបស់វៀតណាម ដែលពួកគេវិនិច្ឆ័យថាសមហេតុផល។ ដូច

ជាការទាយទុកជាមុន ក្រុងភ្នំពេញបានច្រានចោលផែនការនេះ របៀបពេបជ្រាយ ដោយកត់សម្គាល់ថា នេះគ្រាន់តែជាមធ្យោបាយគំរាមមួយ បូកផ្សំនឹងការប៉ុនប៉ងបន្លំសាធារណៈមតិអន្តរជាតិប៉ុណ្ណោះ។"

របាយការណ៍របស់លោក ប៉ៃ ហើយនិងការកត់សម្គាល់របស់សម្រង់របស់ ណាយ៉ាន់ ចាន់ដា ហ្នឹង តើលោកយល់ឃើញថា<វាដូចទៅនឹងអ្វីដែលលោករកឃើញតាមរយៈការស្រាវជ្រាវរបស់លោកថា>នៅដើមឆ្នាំ១៩៧៨នេះ វៀតណាមនុ៎ង <យោងតាម ណាយ៉ាន់ ចាន់ដា> បានដាក់លក្ខខណ្ឌដែលថា លក្ខខណ្ឌហ្នឹង ដែលខ្មែរមិនអាចទទួលបាននោះឡើយ ពីព្រោះថាការសម្រេចចិត្តរបស់គេនោះ វាហើយស្រេចទៅហើយ <នៅពេល>ចូលឈ្លានពានប្រទេសកម្ពុជានោះ <ក្នុងករណីណាក៏ដោយ> ដោយ-សារគេសម្រេចចិត្ត<>ជាស្ថាពរហើយថាត្រូវតែ<ឈ្លានពាន>ចូលមកប្រទេសកម្ពុជា? <>

[១៣:៥១:០១]

**លោក ស្ទីហ្វិន ម៉ររីស៖**

**ឆ៖** ខ្ញុំគិតថា ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺនៅ<ដើម>ឆ្នាំ៧៨គឺថា ភាគីទាំងពីរស្ថិតក្នុងគោលជំហរមួយដែលថា ពួកគេចង់ការចរចាតាមផ្លូវការទូត ហើយគេគិតថា ការចរចាហ្នឹងវាអាចប៉ះពាល់ទៅដល់គំនិតរបស់ពិភពលោក។ នៅពេលនោះខ្ញុំមិនដឹងថា វៀតណាមមានចេតនាយ៉ាងដូចម្ដេចទេ ប៉ុន្តែអាចថានៅដើមឆ្នាំ៧៨ វៀតណាមការសម្រេចផ្សេង ក្រៅពីការចង់ឈ្លានពាននោះ គឺមានគំនិតផ្សេងក្រៅពីការចង់ផ្ដួលរំលំគឺថាគេគិតថា វាហាក់ដូចជាមិនមានប្រសិទ្ធភាពអីនោះឡើយ។ បន្ទាប់មកទៀតគឺពួកគេប្ដូរចិត្ត ដោយគេសម្រេចចិត្តថា ត្រូវតែឈ្លានពាន។ ដូច្នេះខ្ញុំគិតថាសេចក្ដីសម្រេចដែលវៀតណាមបានធ្វើនេះ គឺធ្វើឡើងនៅក្នុងឆ្នាំ៧៨ ដើម្បីផ្ដួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែថាតើផ្ដួលរំលំដោយរបៀបណានោះ គឺគេបានផ្លាស់ប្ដូរ។ ហើយដើម្បីឲ្យវៀតណាមប្រាកដប្រជាថា គេអាចឈ្លានពានបានគឺគេចាំបាច់ត្រូវតែប្រាកដក្នុងចិត្តថា គេអាចទប់ទល់ជាមួយនឹងការធ្វើបាបពីខាងប្រទេសចិន។ ហេតុដូច្នេះហើយទើបវៀតណាមស្វែករកការគាំទ្រពីប្រទេសសូវៀត ដើម្បីទប់ទល់ជាមួយចិនមិនឲ្យមកធ្វើបាបខ្លួនបាន។ ខ្ញុំគិតថា វាមិនមែនជា គឺថានៅដើម៧៨ គឺមិនទាន់មានអ្វីដែលបង្កើតឲ្យប្រាកដប្រជានោះឡើយ គឺនៅក្នុងឆ្នាំ៧៨ពេញមួយឆ្នាំហ្នឹងឯង ដែលគេចាប់ផ្ដើមរៀបចំឲ្យអ្វីៗដំណើរការទៅដោយស្រួល។

[១៣:៥២:៥០]

**សៈ** ឲ្យដើម្បីឲ្យគ្រប់ជ្រុងជ្រោយ ផ្នែកដែលខ្ញុំរកអម្បាញ់មិញ ទាក់ទងនឹងគោលជំហររបស់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កម្ពុជាប្រជាធិបតេយ្យ គឺឯកសារ E3/1773, ERN ជាភាសាអង់គ្លេសគឺ <01246919>, ជាភាសាខ្មែរគឺ <01320160> <និងនៅទំព័របន្ទាប់>។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "លក្ខខណ្ឌបួនចំណុចដែលបានបញ្ជាក់ឡើងវិញ តាមរយៈលិខិតមួយច្បាប់ពីថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ទៅកាន់រដ្ឋាភិបាលសាធារណសង្គមនិយមវៀតណាម មានដូចតទៅ បញ្ឈប់ការឈ្លានពានតាមផ្លូវគោក និងតាមផ្លូវសមុទ្រ បញ្ឈប់ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការផ្ទៃក្នុងរបស់របបកម្ពុជាប្រជាធិបតេយ្យ និងការប៉ុនប៉ងដើម្បីផ្តួលរំលំរដ្ឋាភិបាល បោះបង់គំនិតនៃការបង្កើតសហព័ន្ធឥណ្ឌូចិន និងគោរពសិទ្ធិស្វ័យសម្រេច។" សូមបញ្ចប់ការដកស្រង់។

នេះគឺជាលក្ខខណ្ឌដែលកំណត់ឲ្យ ដែលគេដាក់មក។ ដោយសារខ្ញុំសល់ពេលវេលាតិចនេះ ខ្ញុំនឹងបញ្ចប់ដោយនិយាយអំពីជំងឺត្រដេវរិច។ លោកបាននិយាយថា គោលជំហរក្នុងការផ្តួលរំលំរដ្ឋាភិបាលដោយប្រើកម្លាំងពីសំណាក់វៀតណាមនេះ គឺជាយុទ្ធសាស្ត្រមួយដែលយើងអាចយល់បាន។ ក៏ប៉ុន្តែផ្ទុយទៅវិញ ឆន្ទៈក្នុងស្ថិតនៅប្រទេសកម្ពុជា ក្រោយពេលដែលឈ្លានពានបានសម្រេចហើយនោះ បានជោគជ័យ<ពីសំណាក់វៀតណាម និងក្រុមសម្ព័ន្ធមិត្តកម្ពុជា>ហើយនោះ នេះគឺជាសេចក្តីសម្រេចចិត្តមួយដែលចេញពីការភ័យខ្លាច ឬក៏ជាជំងឺត្រដេវរិចរបស់ប្រទេសវៀតណាម។ ប្រសិនបើខ្ញុំនិយាយខុសកែខ្ញុំផង។ <លោកបាននិយាយថា> នេះគឺជាលទ្ធផលនៃការភ័យខ្លាចរបស់វៀតណាមចំពោះចិន។ លោកប្រើពាក្យ "ភ័យខ្លាចជំងឺ ១ខ្លាចស្រមោលខ្លួនឯង" នេះ ច្រើនចំពោះលទ្ធិម៉ាក្ស-ឡេនីន ហើយនិងកុម្មុយនីស្តហ្នឹងជាទូទៅ។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើលោកប្រើពាក្យពេចន៍ហ្នឹងសម្រាប់តែរបបប្រភេទរបបហ្នឹងនៅក្នុងអំឡុងសង្គ្រាមត្រជាក់ ឬក៏ពាក្យហ្នឹងលោក<ប្រើក្នុងជំហរផ្ទុយគ្នានៃមនោគមន៍វិជ្ជា? តើមិនមានពេលណាមួយនោះដែលផ្ទុះអំពីជំងឺត្រដេវរិចហ្នឹងទេឬ?> ខ្ញុំសួរលោកថាតើជំងឺខ្លាចស្រមោលខ្លួនឯងហ្នឹង វាមានគ្រប់ភាគីទាំងអស់ ឬក៏យ៉ាងម៉េច ឬក៏វាមានតែម្ខាង ១ទៀតអត់មានទេ <ក្នុងពេលសង្គ្រាមត្រជាក់ហ្នឹង>?

[១៣:៥៦:០៧]

**ឆ៖** នៅពេលដែលលោកនិយាយទាំងសងខាងនេះ តើលោកស្រីចង់សំដៅទៅលើខាងណាដែរ?

**ស៖** ខ្ញុំគួរតែនិយាយឲ្យច្បាស់ជាងហ្នឹង។ តាមពិតខ្ញុំចង់និយាយថា ខាងសង្គមនិយម ហើយនិងកុម្មុយនីស្ត ហើយម្ខាងទៀតហ្នឹងគឺខាងប្លុកលោកខាងលិច គឺពួកសេរី។

**ឆ៖** ខ្ញុំគិតថា មិនមានការខ្លាចស្រមោលខ្លួនឯងចំពោះខាងលោកខាងលិចជាមួយនឹងខាងសង្គម

01365108



និយមទេ គឺថាលោកខាងលិចគ្រាន់តែបារម្ភទៅលើអាកប្បកិរិយារបស់សង្គមនិយមមួយចំនួនប៉ុណ្ណោះ ឧទាហរណ៍ដូចជាសូវៀតជាដើមនោះ។ គឺថានៅក្រោយឆ្នាំ៧៥ គឺក្រោយពេលដែលអាមេរិកបានផ្លាស់ប្តូរគោលជំហរទាក់ទងទៅនឹងឥណ្ឌូចិន នៅពេលហ្នឹងសូវៀតបានក្លាយទៅជាមហាអំណាចខ្លាំង ហើយ <ខ្ញុំមិនគិតថាវាជា>ការភ័យខ្លាចស្រមោលខ្លួនឯង<នោះទេ>។ គឺថាសូម្បីតែនៅពេលនោះក៏ដោយ ក៏មានការចរចាគ្នាជាមួយនឹងខាងសូវៀតផងដែរ ហើយមានការគិតថា ម្ខាងទៀតហ្នឹង ក៏មានមនុស្សប្រហែលៗគ្នាដែលអាចចរចាបាន។ ដូច្នេះខ្ញុំ<មិន>គិតថា <លោកខាងលិចរីក>ឡើងដោយសារតែការភ័យខ្លាចស្រមោលខ្លួនឯងនោះឯង។ ហើយខ្ញុំគិតថា ដោយសារតែមានការភ័យខ្លាចស្រមោលខ្លួនឯងហើយ ទើបមានអំពើហិង្សាទៅលើប្រជាជនខ្លួនឯង។ ហើយឧទាហរណ៍ដូចជានៅស-២១ជាដើម គឺមិនមានទេនៅអាមេរិក នៅអង់គ្លេស នៅបារាំងអីនោះ។ ខ្ញុំអាចនិយាយបានថា នៅខាងលោកខាងលិចគឺមានអ្នកភ័យខ្លាចដែរ ហើយរដ្ឋាភិបាលខ្លះ ក៏ហាក់ដូចជាមានទំនោរទៅខាងភ័យខ្លាចស្រមោលខ្លួនឯងដែរ ប៉ុន្តែមិនធ្ងន់ធ្ងរខ្លាំងដូចរដ្ឋបដិវត្តនោះទេ។

[១៣:៥៨:៣១]

ខ្ញុំព្យាយាមបង្ហាញនៅក្នុងសៀវភៅរបស់ខ្ញុំនូវឧទាហរណ៍មួយចំនួន ដែលមានការវាយតម្លៃមិនត្រឹមត្រូវទៅលើគោលដៅរបស់ខ្លួនឯង ដោយសារតែការភ័យខ្លាចស្រមោលខ្លួនឯង ការបដិសេធមិនទទួលស្គាល់ថា អ្វីៗអាចកើតឡើងដោយចៃដន្យជាដើម។ <ឧទាហរណ៍ បើសិនជាមាន>ការគំរាមកំហែងហ្នឹង គឺ<ពិតជាមានការចូលរួមឃុបឃិតណាមួយមិនខាន>។ <ខ្ញុំព្យាយាមបញ្ជាក់យ៉ាងច្បាស់នៅក្នុងសៀវភៅរបស់ខ្ញុំថា> ឧទាហរណ៍ដូចជាវៀតណាមគិតថា ចិនរុញកម្ពុជាប្រជាធិបតេយ្យទៅលើផ្លូវមួយដែលខ្លួនចង់ទៅដែរ<ក្នុងគោលនយោបាយបរទេស។ ការពិតទៅ គឺគ្មានភស្តុតាងដែលបង្ហាញថាយ៉ាងដូច្នោះទេ។> ដូច្នេះខ្ញុំគិតថា<>កម្ពុជាប្រជាធិបតេយ្យ គឺធ្វើដំណើរដោយមិនមានការជួយពីចិន<ទេ។ ក្នុងអំឡុងឆ្នាំ១៩៧៨ ចិនព្យាយាមកំហិត>អាកប្បកិរិយា<គោលនយោបាយបរទេស>របស់កម្ពុជាប្រជាធិបតេយ្យ <ព្រោះចិន>ភ័យខ្លាច<>ថា វៀតណាមនឹងឈ្លានពាននោះ។

ខ្ញុំគិតថា វៀតណាមគិតខុសចំពោះកម្ពុជាប្រជាធិបតេយ្យ ហើយកម្ពុជាប្រជាធិបតេយ្យ ក៏គិតខុសអំពីវៀតណាម គឺគិតខុសដូចគ្នា។ ដូចដែលខ្ញុំបានបញ្ជាក់ វៀតណាមមានចេតនា ឬក៏មានគោលបំណងចក្រពត្តិចំពោះកម្ពុជា។ <ប៉ុន្តែផ្នែកខ្លះពួកគេធ្វើមិនបានសម្រេចទេដោយសារតែ ប៉ុល ពត។> ហើយខ្ញុំគិតថា ប៉ុល ពត មានចេតនាក្នុងការកម្ទេចឲ្យអស់នូវខ្មែរវៀតមិញ<នៅដើមទសវត្សរ៍ទី៧០។>

ហើយវៀតណាមក៏មានការលំបាក ដោយសារតែបារម្ភពីការធ្វើបាបពីសំណាក់ប្រទេសចិនផងដែរ។ ដូច្នេះ<> ប្រសិនបើសួរថាតើមានការភ័យខ្លាចស្រមោលខ្លួនឯងនៅគ្រប់កន្លែង នៅទូទាំងពិភពលោកទេ? ខ្ញុំឆ្លើយថា បាទ ពិតជាមាន ប៉ុន្តែវាមិននៅក្នុងកម្រិតខ្លាំង ដូចដែលរដ្ឋបដិវត្តមាននោះឡើយ។ គឺថាខ្ញុំចង់និយាយអំពីក្នុងចំណោមថ្នាក់ដឹកនាំ។

[១៤:០០:៤២]

**ស៖** ដោយសារពេលវេលាហ្នឹង វាជិតអស់ទៅហើយ ខ្ញុំសូមឧទាហរណ៍មួយ។ តើសញ្ញាណនៃជំងឺគ្រដេវវិចនេះ ឬក៏ជំងឺខ្លាចស្រមោលខ្លួនឯងនេះ លោកអាចយកទៅអនុវត្តនៅប្រទេសឥណ្ឌូនេស៊ីដែរឬទេ?

**ឆ៖** ខ្ញុំគិតថា វាជាលទ្ធផលដែលលោកស្រីនិយាយអំពីនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ៦០នោះមែនទេ? បាទ ប្រសិនបើអ៊ីចឹងមែន គឺមានការផ្សំគំនិតមួយ ទាក់ទងទៅនឹងប្រទេសឥណ្ឌូនេស៊ី គឺក្រុមកុម្មុយនីស្តឥណ្ឌូនេស៊ី គឺគេព្យាយាមទប់ទល់ជាមួយនឹងរបប ហើយធ្វើឱ្យរបបដឹកនាំគឺមិនអាចគ្រប់គ្រងបាន ហើយក៏ត្រូវធ្វើការសម្លាប់ជនជាតិចិន។ ហើយខ្ញុំគិតថានៅឥណ្ឌូនេស៊ីក៏មានការភ័យខ្លាចស្រមោលខ្លួនឯងដែរ។ ខ្ញុំមិនដែលនិយាយថា ជំងឺភ័យខ្លាចស្រមោលខ្លួនឯងហ្នឹង មានតែនៅក្នុងរដ្ឋបដិវត្តនោះទេ គឺមាននៅទូទាំងពិភពលោក។

**ស៖** ខ្ញុំដឹងថា ឥឡូវនេះ លោកប្រធាន ខ្ញុំសំណួរចុងក្រោយរបស់ខ្ញុំហើយ លោកប្រធាន ខ្ញុំសូមសន្យា។ អ៊ីចឹងការដែលពិបាកក្នុងការជ្រើសរើសគោលនយោបាយ ឬក៏ជំនឿជឿជាក់របស់ខ្លួន ដែលរដ្ឋមួយចំនួន<បានធ្វើឡើង>នោះ តើលោក<គិត>ថា <នេះជាអ្វីដែលមាននៅក្នុង>របបម៉ាក្ស-ឡេនីនហ្នឹង<ឬ? ខ្ញុំសំដៅទៅលើ> ការលំបាកក្នុងការទទួលស្គាល់ពី<ការសម្លាប់រង្គាលក្រោមអាណានិគមដោយ>បារាំងអ៊ីចឹង <ឧទាហរណ៍ ហើយមានពេលមួយទៀតគឺពីការសម្រេចចិត្ត>ទម្លាក់គ្រាប់បែក<នៅហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគីដោយអាមេរិក។ ឬក៏ភ្នាក់ងារទឹកក្រូចនៅវៀតណាម។> អ៊ីចឹងខ្ញុំសួរថា<>តើវាជាការលំបាកដែរឬទេ ចំពោះរដ្ឋមួយនៅពេលដែលខ្លួនបានធ្វើការជ្រើសរើសគោលនយោបាយ<ទៅតាមមនោគមន៍វិជ្ជា>របស់ខ្លួនហើយ ក្រោយមកវាមានកំហុសជ្រុលជ្រួសទៅ<ដែលធ្វើឱ្យមានការស្លាប់រហូតដល់ទៅរាប់ពាន់ ឬក៏ដល់ទៅរាប់លាននាក់ឯណោះ តើវា>មានការលំបាកក្នុងការទទួលស្គាល់ដែរឬទេ ព្រោះពីដំបូងទីមក មិនចង់ធ្វើអ៊ីចឹងទេ ដល់ក្រោយមកទៅជាអ៊ីចឹងនេះ?

[១៤:០៣:២៩]

**ឆ៖** លោកស្រីនិយាយ ចង់សួរថា ថាតើវា<>អាចដែរឬទេ ដែលថា<សកម្មភាពរបស់មនុស្សម្នាក់អាចធ្វើមានការឈឺចាប់ដ៏មហិមាបាន បើទោះជាមិនមែនជាចេតនារបស់ខ្លួនក៏ដោយ?> ប្រសិនបើរដ្ឋាភិបាលមួយបានធ្វើសកម្មភាពមួយ ឧទាហរណ៍ថា រដ្ឋមិនមែនជាបដិវត្ត គឺថាធ្វើសកម្មភាពមួយដែលបណ្តាលឲ្យមានការរងគ្រោះយ៉ាងខ្លាំង ទោះបីថាមិនមែនជាចេតនារបស់ខ្លួនក៏ដោយ តើលោកស្រីចង់សួរខ្ញុំអ៊ីចឹងមែនទេ?

**ស៖** ប្រហាក់ប្រហែលអ៊ីចឹងដែរ។ សំណួរខ្ញុំអម្បាញ់មិញនេះ គឺចង់ថា ទោះបីជាយើងប្រកាន់មនោគមន៍វិជ្ជាយ៉ាងណាក៏ដោយ បុគ្គលណាក៏ដោយដែលពេលកាន់អំណាចនោះ គាត់សម្រេចចិត្ត ធ្វើសេចក្តីសម្រេចមួយ ហើយបង្កឲ្យមានការឈឺចាប់ដល់ប្រជាជន។ ហើយខ្ញុំសួរថា តើចំពោះអ្នកអតីតអ្នកទទួលខុសត្រូវ ឬក៏អ្នកមានអំណាចនោះ គាត់ពិបាកក្នុងការទទួលស្គាល់ទំនួលខុសត្រូវរបស់គាត់ ហើយក៏ពិបាកនឹងទទួលស្គាល់ថា ការសម្រេចចិត្តនៅពេលនោះ បង្កឲ្យមានគ្រោះថ្នាក់<ដែរឬទេ>? អ៊ីចឹងហើយ ខ្ញុំឧទាហរណ៍អំមិញនេះ ខ្ញុំឧទាហរណ៍ប្រទេសអម្បាញ់មិញ មានអាមេរិកអីទម្លាក់គ្រាប់បែកលើជប៉ុន លើអីជាដើមនោះ <ក្រៅពីឧទាហរណ៍ដែលលោកបានលើកឡើងនោះ។>

**ឆ៖** ពិតហើយ វាពិបាកដើម្បីឲ្យរដ្ឋាភិបាលទទួលស្គាល់ថា គោលនយោបាយរបស់ខ្លួនមិនល្អ ឬក៏មានគ្រោះថ្នាក់ គឺប្រទេសជាច្រើន។

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងហើយលោកប្រធាន ខ្ញុំសួរអម្បាញ់មិញរាងវែងបន្តិចហើយ។

[១៤:០៥:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការស្តាប់សក្ខីកម្មអ្នកជំនាញសាស្ត្រាចារ្យ ស្ទីហ្វិន ម័ររីស បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកសាស្ត្រាចារ្យ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយនិងធ្វើដំណើរមកពីទីឆ្ងាយឯនាយសមុទ្រមកផ្តល់សក្ខីកម្ម ចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាអ្នកជំនាញ ក្នុងរយៈពេល៣ថ្ងៃកន្លងមកនេះ ប្រកបដោយភាពអត់ធ្មត់ គុណធម៌ និងសីលធម៌ វិជ្ជាជីវៈខ្ពស់បំផុត។ ហើយសក្ខីកម្មរបស់លោកសាស្ត្រាចារ្យនៅចំពោះមុខអង្គជំនុំជម្រះកន្លងមកនេះ នឹងអាចរួមវិភាគទានសំខាន់ក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ឥឡូវនេះ វត្តមានរបស់លោកសាស្ត្រាចារ្យនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់ ត្រឡប់ទៅវិញបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយ។ ហើយសូមលោកសាស្ត្រាចារ្យបានសេចក្ដីសុខ ជួបតែសំណាងល្អ មានសុខភាពល្អ ហើយនិងសេចក្ដីសុខ សេចក្ដីចម្រើន និងទទួលបានជោគជ័យថ្មីៗថែមទៀត និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកសាស្ត្រាចារ្យវិលត្រឡប់ទៅកន្លែងគាត់ស្នាក់នៅវិញចុះ។

លោកសាស្ត្រាចារ្យអាចចាកចេញបានហើយ។ បាទ អញ្ជើញចុះបាទ!

*(អ្នកជំនាញចាកចេញពីបន្ទប់សវនាការ)*

ហើយបង្គាប់មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:០៨:១៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ខ្ញុំសូមគោរពចៅក្រម។ នាងខ្ញុំឈ្មោះ ព្រាប សុឃឿន។

**ស៖** បាទ អរគុណ។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណាដែរលោកស្រី?

**ឆ៖** ចាស នាងខ្ញុំបើគិតជាថ្ងៃខែកំណើតនៅក្នុងអត្ត កើតថ្ងៃទី១២ ខែ១០ ឆ្នាំ១៩៥១។ បើកំណើតពិតប្រាកដ គឺកើតនៅឆ្នាំវក។

**ស៖** អរគុណ។ ទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ចាស ស្រុកកំណើតខ្ញុំកើតនៅភូមិអណ្ដូងតាពេជ្រ ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

**ស៖** ចុះទីលំនៅសព្វថ្ងៃរបស់លោកស្រី ៗរស់នៅទីកន្លែងណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់! កុំអាលទាន់!

**ឆ៖** ចាស ខ្ញុំនៅភូមិអណ្ដូងតាពេជ្រ ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាមដដែលចាស។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:០៩:៣២]

**ស៖** លោកស្រីប្រកបមុខរបរអ្វីដែលសព្វថ្ងៃនេះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់! កុំអាលទាន់!

**ឆ៖** ចាស ខ្ញុំសព្វថ្ងៃកសិករ និងបម្រើការងារនៅក្នុងក្រុមប្រឹក្សាឃុំ។

**ស៖** បាទ ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ចាស ឪពុកខ្ញុំឈ្មោះ ព្រាប ឡុង, ម្ដាយខ្ញុំឈ្មោះ ពេជ្រ យន់។

**ស៖** បាទ អរគុណ។ ហើយលោកស្រីមានគ្រួសារទេសព្វថ្ងៃនេះ? ហើយបើមាន គាត់ឈ្មោះអី ប្ដីលោកស្រី?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាល់ទាន់! កុំអាលទាន់!

**ឆ៖** ចាស ក្រោយមកខ្ញុំមានប្ដី ម្ដាយឪពុកបានរៀបឲ្យ ឈ្មោះ ឯម គឹមអៀន។

**ស៖** ហើយមានកូនប៉ុន្មាននាក់លោកស្រី?

**ឆ៖** ចាស បានកូនពីរនាក់ គឺស្រីទាំងអស់។

[១៤:១០:៤៥]

**ស៖** លោកស្រី ព្រាប សុឃឿន ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី គឺលោកស្រីមានសិទ្ធិថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម បានន័យថា ផលអន្តរាយទាំងឡាយដែលកើតមានចំពោះលោកស្រី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

ហើយលោកស្រី ព្រាប សុឃឿន តើលោកស្រីធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ រយៈពេលកន្លងមកនេះ? ប្រសិនបើធ្វើ គឺធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា?

**ឆ៖** ចាស ខ្ញុំបានធ្វើសក្ខីកម្មហ្នឹង បើពីមុនខ្ញុំធ្វើនៅអាដហុកពីដំបូងគេ។ ដល់ក្រោយមកខ្ញុំធ្វើទៅតាមកាលពីដំបូងបង្អស់ ខ្ញុំភ្លេច ហ្នឹងនៅ ឆាំង យុ ដែលគាត់ហៅមកដំបូង។ បានក្រោយមកខ្ញុំដាក់ពាក្យនៅអាដហុក។ ក្រោយមកបានមកធ្វើនៅសាលាក្ដី និងមេធាវីបន្តបន្ទាប់មកដែលគាត់បានជួប។

**ស៖** លោកស្រីដែលផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមកនេះ?

**ផ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់! កុំអាលទាន់! ចាំឲ្យក្បាលមីក្រូហ្វូនក្រហមសិនណ៎ា! និយាយឆ្ងាយក៏អត់ដឹងដែរ អាហ្នឹងស្រួបទេ មិនបាច់ងាកមកក៏បានដែរណ៎ា។

**ផ៖** ខ្ញុំបានមកម្តងនៅកន្លែងហ្នឹង ប៉ុនខាងណោះ។

[១៤:១២:២៧]

**ស៖** ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកស្រីបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកស្រីបានផ្តល់សក្ខីកម្មកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ដើម្បីរំឭកការចងចាំរបស់លោកស្រី?

**ផ៖** ចាស ខ្ញុំបានអាន និងពិនិត្យជារៀងដែរ ជាបន្តបន្ទាប់ដែរ ពីមុនមកនៅផ្ទះក៏ខ្ញុំបានពិនិត្យដល់ពេលមកនេះក៏ខ្ញុំបានអានជាប់ដែរចាស។

**ស៖** ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបានហ្នឹង តើលោកអាចបញ្ជាក់ -- លោកស្រីបានបញ្ជាក់បានទេថា សក្ខីកម្មដែលលោកស្រីបានផ្តល់ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុននោះ ហើយលោកស្រីបានអានដើម្បីរំឭកការចងចាំហ្នឹង វាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកស្រីបានផ្តល់កាលពីពេលមុននោះដែរឬទេ?

**ផ៖** ចាស ការអានហ្នឹងខ្ញុំបានគឺថា កាលហ្នឹងមានពាក្យដែលនិយាយថាថ្ងៃខែឆ្នាំរៀបអាពាហ៍ពិពាហ៍ហ្នឹង ខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែគ្រាន់ឧទាហរណ៍ ឲ្យគាត់ដាក់ជាថ្ងៃកំណត់ទេចាស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អនុវត្តតាមបទបញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយបញ្ជាក់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គ នៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៤:១៤:១៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានផ្ដល់សិទ្ធិជូនលោកមេធាវី ឡោ ជុនធី ដើម្បីសួរសំណួរទៅដល់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន សូមប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ហើយខ្ញុំបាទសូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម ហើយនិងភាគីនៅពេលនេះ។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីហើយនិងខ្ញុំមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាផងដែរ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ពេលនេះខ្ញុំបាទសុំជម្រាបសួរសំណួរមួយចំនួនទៅអ្នកស្រី ព្រាប សុឃឿន ដែលបានឆ្លងកាត់នៅរបបកម្ពុជាប្រជាធិបតេយ្យនេះ ពីឆ្នាំ ១៧ មេសា ឆ្នាំ១៩៧៥ ទៅដល់០៦ មករា ឆ្នាំ១៩៧៩។ ជាដំបូងខ្ញុំបាទសុំបញ្ជាក់បន្តិចដែលអ្នកស្រីបញ្ជាក់ជូនលោកប្រធានអម្បាញ់មិញ ពាក់ព័ន្ធទៅនឹងថ្ងៃខែឆ្នាំកំណើតរបស់លោកស្រី ។ថា តើថ្ងៃខែឆ្នាំកំណើតដែលលោកស្រីបានដាក់នៅក្នុងអត្តសញ្ញាណប័ណ្ណហើយនិងអ្វីដែលលោកស្រីបាននិយាយអម្បាញ់មិញ វាជាការមួយដែលយើងពីមុនមកមានហេតុការណ៍អីបានយើងដាក់ទៅតាមនុ៎ង?

[១៤:១៦:៣៣]

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយ។ កាលដែលខ្ញុំបានធ្វើអត្តកាលពីឆ្នាំដែលគេធ្វើឆ្នាំមុននុ៎ង ខ្ញុំបានប្រាប់ខែឆ្នាំគេថា ខ្ញុំកើតនៅឆ្នាំរក ប៉ុន្តែខ្ញុំអត់ដឹងថាកើតនៅខែអីទេ។ អ៊ីចឹងអ្នកសរសេរគាត់ថា អ៊ីចឹងគិតមើលកើតខែណា។ អាហ្នឹងក៏យើងនិយាយពីរដូវកាលប្រាប់គាត់។ ដល់អ៊ីចឹងគាត់ដាក់តាមថ្ងៃខែឆ្នាំហ្នឹងឲ្យទៅ។ អ៊ីចឹងគឺថា ខ្ញុំអត់ចេះអី គឺខ្ញុំទទួលយកពីនុ៎ងមកប្រើប្រាស់ទល់សព្វថ្ងៃ។

**ស៖** បាទ អរគុណ។ អ៊ីចឹងមានន័យថា ការអ្វីដែលការកត់ត្រានៅក្នុងអត្តសញ្ញាណប័ណ្ណ ហើយ

និងអាយុពិតវាខុសគ្នា ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស បើខ្ញុំរាប់ទៅតាមក្នុងអត្តខ្ញុំកើតថ្ងៃទី១២ ខែ១០ ១៩៥១ និងខ្ញុំកើត គឺអត្តបង ៗអាយុខ្ញុំ ខ្ញុំប្អូនទេ ព្រោះខ្ញុំកើតឆ្នាំវក។

**ស៖** តើឆ្នាំនេះអ្នកស្រីអាយុប៉ុន្មានហើយ?

**ឆ៖** ចាស ខ្ញុំបើរាប់ទៅតាមរដូវកាលនៃឆ្នាំ ខ្ញុំគិតស្មើនឹងសព្វថ្ងៃ៦២ឆ្នាំ។

**ស៖** បាទ អរគុណ។ ខ្ញុំសុំចូលទៅប្រវត្តិរបស់អ្នកស្រីបន្តិច ថាតើក្រោយឆ្នាំ១៩៧៥ គឺមុនឆ្នាំ៧៥តិច អ្នកស្រីបានចូលធ្វើអ្វីដែរ?

[១៤:១៨:៥៣]

**ឆ៖** ចាស កាលមុន៧៥នុ៎ង នៅសហករណ៍គេឲ្យខ្ញុំចូលទៅនៅក្នុងក្រុមសិល្បៈ។ ដល់ក្នុងសិល្បៈហើយ គេឲ្យយកស្បៀងយកអីទៅសមរភូមិវ៉ៃនៅកំពង់ចាម។ ដល់ក្រោយមក ដល់៧៥ហ្នឹង វ៉ៃរំដោះដាច់ទៅក្រុងភ្នំពេញ គេប្រមូលខ្ញុំឲ្យទៅសហជីពដើម្បីបង្កបង្កើនផលដាំដំណាំកប្បាស។

**ស៖** បាទ អរគុណ។ នៅពេលដែលអ្នកស្រីបានទៅដាំដំណាំកប្បាសហ្នឹង តើដាំនៅកន្លែងណាដែរ?

**ឆ៖** សហជីពដែលកើតនៅឆ្នាំ១៩៧៥ គឺកើតនៅភូមិអណ្ដូងតាឡឹង ក្នុងទឹកដីឃុំថ្មពូន។

**ស៖** ខេត្ត ៗអីដែរ?

**ឆ៖** ខេត្តកំពង់ចាម។

**ស៖** អរគុណ។ ហើយថាតើនៅទីនោះ គេឲ្យអ្នកស្រីធ្វើអ្វីខ្លះ?

**ឆ៖** ចាស ខ្ញុំសូមរៀបរាប់ការងារ។ ពីដំបូងគេឲ្យខ្ញុំនៅក្នុងសហជីពហ្នឹង គេឲ្យនៅជាក្រុមតាមរយៈក្រុមនៅឡើយទេ គេមិនទាន់បញ្ចូលទៅក្នុងសហជីពប្រមូលផ្ដុំទេ។ គេវាល់អង្ករចែកឲ្យក្នុងមួយថ្ងៃពីរកំប៉ុង ដើម្បីឲ្យទៅពលកម្ម កាប់ឆ្ការព្រៃធំ រំលំព្រៃតូច រានដើម្បីយកដីដាំព្រៃកប្បាស។

**ស៖** បាទ អរគុណ។ ហើយនៅពេលណាដែលអ្នកស្រីត្រូវបានគេរៀបចំគូស្រករឲ្យ?

**ឆ៖** ចាស ការរៀបចំហ្នឹង ខ្ញុំមិនចាំច្បាស់ទេ ព្រោះសម័យនោះ វាមិនបានគិតថ្ងៃខែឆ្នាំទេ ប៉ុន្តែខ្ញុំដឹងថា នៅរដូវកាលហ្នឹងកប្បាសហ្នឹង វាផ្លែចាស់ហើយ ហើយគេប្រើខ្ញុំទៅធ្វើព្រៃ។ ដល់ថ្ងៃមួយហ្នឹង គេប្រើនីរសារហ្នឹង ឲ្យទៅហៅខ្ញុំពីចម្ការ រសៀល មិនដឹងម៉ោងប៉ុន្មានទេ ថ្ងៃជ្រេហើយ។ ហៅឲ្យខ្ញុំមក មកក៏ មិត្តលី ហ្នឹង មិត្តនី លី ហ្នឹង គាត់បានហៅខ្ញុំទៅសួរ។ ថាមិត្តឯងរស់នៅសព្វថ្ងៃ រស់នៅសព្វថ្ងៃហ្នឹង

គោរពអង្គការវិន័យដែរឬទេ? ខ្ញុំក៏ឆ្លើយថា ខ្ញុំរស់ក្រោមការដឹកនាំរបស់អង្គការ គឺខ្ញុំគោរពគ្រប់ពេលវេលា។ ខ្ញុំឧទាហរណ៍ទៀតថា បើសិនជាឲ្យខ្ញុំចូលរន្ធក្តាម បើអង្គការចូលរួច ក៏ខ្ញុំចូលតាមដែរ។ ហ្នឹងខ្ញុំនិយាយឧទាហរណ៍ប្រាប់ដល់មិត្ត លី ហ្នឹង។

[១៤:២២:២៥]

**ស៖** ក្រោយពីគេបានសួរសំណួរហ្នឹងទៅអ្នកស្រី ហើយថាតើក្រោយមកទៀត មានព្រឹត្តិការណ៍អីកើតឡើងទៀត?

**ឆ៖** ចាស ខ្ញុំគេគ្រាន់តែសួរហើយ គេមិនប្រាប់ថា ត្រៀមខ្លួនរៀបការទេ គេអត់បានប្រាប់ថាស្អែកត្រូវរៀបការខ្ញុំ ឬក៏ព្រឹកហ្នឹងរៀបការខ្ញុំទេ គេអត់បានប្រាប់ខ្ញុំទេ។ ខ្ញុំមិនបានចាប់អារម្មណ៍ការសួរពាក្យសម្តីទាំងអស់ហ្នឹង ខ្ញុំក៏បានរៀបចំខ្លួនទៅចម្ការវិញ។ ព្រលឹមឡើងម៉ោងប្រាំមួយហ្នឹង គឺខ្ញុំចេញទៅដល់ចម្ការ។ ដល់ពេលខ្ញុំទៅដល់ចម្ការ ម៉ោងប្រហែលជា អើយ! ថ្ងៃទ្រេតខ្ពស់ដែលហើយ ជិតហូបបាយហើយ ឃើញនីរសារគេទៅតាមហៅខ្ញុំថា អ្នស! មិត្តនេះ ក្រែងគេឲ្យទៅកន្លែង មិត្តសូ ម៉េចមិនទៅ បានមកណេះ។ រួចខ្ញុំក៏ឆ្លើយថា ឲ្យខ្ញុំទៅធ្វើអី បើមិនប្រាប់មុន ម៉េចនឹងដឹង។ ខ្ញុំក៏ឆ្លើយប៉ុណ្ណឹងទៅ។ គេថា មកអ៊ីចឹងទៅវិញ។ ដល់ទៅ ក៏គេហៅខ្ញុំ បណ្តើរខ្ញុំដើរមកវិញមក ខ្ញុំមកដល់កន្លែងខ្ញុំសម្រាកហ្នឹង ខ្ញុំក៏ចូលទៅកន្លែងសម្រាកហ្នឹងទៅ ស្រាប់តែមិត្តនី លី ហ្នឹង គាត់បានទៅហៅខ្ញុំ អ្នស! មិត្តនេះ មិនមកយកខោអាវ ទៅកន្លែងគេរៀបចំណោះ ហើយទៅសម្ងំឯណា។ ខ្ញុំថា អ្នស! ទៅរៀបចំឯណា ក៏មិនប្រាប់ខ្ញុំ បើខ្ញុំមិនដឹងផងនោះ។ ពេលនោះគាត់ឲ្យខោមួយ អាវមួយ ក្រមាមួយ ឲ្យខ្ញុំស្លៀក។

[១៤:២៤:០៤]

**ស៖** បាទ ហើយថាតើនៅពេលដែលគេទៅហៅអ្នកស្រីនោះ តើមាននរណាគេខ្លះ ដែលទៅហៅហ្នឹង គឺមានប៉ុន្មាននាក់ ដែលហៅមកចូលរួមការហ្នឹង?

**ឆ៖** ចាស ថ្ងៃហៅមកពីចម្ការហ្នឹង មានតែខ្ញុំ ព្រោះត្បិតអី ខ្ញុំអត់បាន គេប្រាប់ រួចកងនានាទៀត ខ្ញុំអត់បានដឹងផង គេ ព្រោះគេការតាម គេឲ្យតាមកងមួយៗ មានឈ្មោះអ្នកណាអាយុច្រើនទៅគេឲ្យរៀបការ។ អ៊ីចឹងខ្ញុំអត់បានតាមដានផង។ ខ្ញុំដឹងតែមកម្នាក់ឯង មកដល់ហ្នឹង ក៏គេហៅឲ្យយកខោអាវទៅ ខ្ញុំក៏ទៅៗ ក៏បានឃើញនារីៗនៅនុំងទៅ ស្គាល់ខ្លះ មិនស្គាល់ខ្លះ។ ក៏ឃើញគេយំ ខ្ញុំក៏យំនឹងគេទៅខ្ញុំមានបានដឹងថា ការហ្នឹង វាមានរបៀបជោគជ័យសប្បាយអី ខ្ញុំអត់ដឹង ដឹងតែពីសេចក្តីសោកទុក្ខព្រួយខ្ញុំ។

**ស៖** តើគេបានជម្រាបអ្នកស្រីដែរឬទេ ថាតើទៅរៀបការហ្នឹងរៀបការជាមួយបុគ្គលឈ្មោះអី ឬមួយនរណាច្បាស់លាស់ដែរឬទេ?

**ឆ៖** ចាស កាលដែលហៅមករៀបការហ្នឹង គេមិនបានប្រាប់ថា មិត្តឯងគេរៀបឱ្យមិត្តនេះៗ ឈ្មោះនេះ នៅកន្លែងនេះ គេអត់មានប្រាប់ទេ។ ចាស ទាល់តែដល់ពេលគេហៅចូលទៅប្រជុំ គេនិយាយពីគោលដៅរបស់បក្សរបស់គេ អប់រំយើងសព្វបែបយ៉ាងទៅ គេដាក់ស្រីម្ខាង បុរសម្ខាង ហើយគេរៀបតុកណ្តាលអ៊ីចឹងទៅ ទុកឱ្យយើងហ្នឹងឡើងកាន់តុហ្នឹង មួយតុពីរគូចាស។

**ស៖** តើនៅពេលដែលអ្នកស្រីរៀបការហ្នឹងមានប៉ុន្មានគូដែរនៅពេលនុំង? ហើយនរណាគេដែលមកជួយរៀបចំហ្នឹងជាគណៈអធិបតី ឬមួយជាអ្នកណែនាំឱ្យធ្វើអីៗ ឱ្យអង្គុយយ៉ាងណាយ៉ាងណីហ្នឹង?

[១៤:២៦:៣២]

**ឆ៖** ចាស កាលនុំង ខ្ញុំទៅនុំងមានតែតំណាងកងៗធំៗហ្នឹង គេនៅជាមួយប្រធានសហជីពហ្នឹង សហជីពហ្នឹងគេអង្គុយធំខ្ពស់អ៊ីចឹងទៅ ហើយទៅមានអ្នកដែលនេះហ្នឹង ឧទាហរណ៍ថាគេប្រាប់ឱ្យយើងស្តាប់ឈ្មោះយើងនិងគូយើងទៅ បើគេហៅឈ្មោះគូយើង ហើយមានឈ្មោះយើងហើយ ឱ្យយើងលើងបន្តបន្ទាប់អ៊ីចឹងទៅ។ ដូចឧទាហរណ៍ថាខ្ញុំ កាលហ្នឹងខ្ញុំឈ្មោះ ភាស់ គេឱ្យដាក់ឈ្មោះ ភាស់ ហើយគ្រួសារដែលគេរៀបឱ្យខ្ញុំហ្នឹងឈ្មោះ មិត្តកែវ។ អ៊ីចឹងបើគេហៅថា មិត្តកែវ បុរសគូនឹង មិត្តភាស់ នារី អ៊ីចឹងគេឱ្យយើងស្គាល់ឈ្មោះយើងហ្នឹង គេផ្គូនឹងឈ្មោះហ្នឹង យើងអត់បានឃើញគ្នាស្គាល់គ្នាទេ។ គេហៅឈ្មោះ ឱ្យយើងចាំឈ្មោះហ្នឹងឱ្យឡើងតាមគ្នាមក បើបុរសហ្នឹងឡើងមុន ឱ្យយើងឡើងក្រោយ។

**ស៖** អ៊ីចឹងមិនមែនគេរៀបកៅអីជាកន្លែងឱ្យយើងអង្គុយទល់មុខគ្នាហើយ ហៅឡើង ទើបបានទៅអង្គុយទល់មុខគ្នា ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស គេៗដាក់បុរសខាងណោះ នារីនៅខាងណេះ ហើយកណ្តាលអ៊ីចឹងគេរៀបតុសម្រាប់ផ្គូ។ ហើយអង្គការគេនៅពីមុខអ៊ីចេះ ហើយខ្ញុំអង្គុយខាងហ្នឹងជាមួយនារីៗហ្នឹងទៅ ដល់គេហៅអ៊ីចឹង យើងមិនបានចាប់អារម្មណ៍ថាយើងហ្នឹងរៀបការរៀបអី គិតតែយំ សោកសង្រេង ស្តាយខ្លួនស្តាយម៉ែឪដែលគាត់អត់បានដឹង។ ដល់ពេលគេហៅខ្ញុំ តុហ្នឹងគេដាក់តុវែង តុវៀនយើងហ្នឹង មិនមែនតុកៅអីអ៊ីចេះទេ តុវៀនវែងៗហ្នឹង ក្នុងមួយតុហ្នឹងពីរគូ។ គេហៅ បុរសមិត្តកែវ អ៊ីចឹងមកគូនឹង មិត្តភាស់ នារី។ ដល់ក្រោយមកគេហៅ វុន នារី គូនឹងមិត្ត ឈាង បុរស។ អ៊ីចឹងតុហ្នឹងវាមានពីរគូហ្នឹង នារីអង្គុយ

កណ្តាល បុរសៗអង្គុយខាងៗ។

[១៤:២៨:៤០]

**ស៖** តើអ្នកស្រីមានចាំទេថា ពេលដែលគេរៀបការហ្នឹងគេមានហៅឡើងប្តេជ្ញាចិត្តចំពោះបដិវត្តន៍យ៉ាងម៉េចដែរ?

**ឆ៖** កាលហ្នឹង កាលដែលខ្ញុំការនុ៎ងគេមិនឱ្យយើងឡើងប្តេជ្ញាទេ គេមានតំណាង។ នារីតំណាងឱ្យគូដែលអ្នករៀបជាស្រ្តីហ្នឹង ហើយបុរសតំណាងឱ្យបុរស។ អ៊ីចឹងអ្នកប្តេជ្ញាហ្នឹង គេនិយាយខ្លួនគេពីគោលការណ៍របស់បក្សគេទៅ យើងគ្រាន់តែអង្គុយចាំតែស្តាប់ទៅ។

**ស៖** អម្បាញ់មិញអ្នកស្រីបានលើកឡើងថា មានអ្នកចូលរួម ឬមួយឪពុកម្តាយ តើគេឱ្យមកចូលរួមដែរ ឬមួយញាតិសណ្តានអីឱ្យចូលរួមដែរអត់ នៅពេលនោះ?

**ឆ៖** ចាស កាលការនុ៎ង ញាតិសណ្តានម៉ែឪមិនបានចូលរួមទេ មានតែក្នុងកងធំៗដែលតំណាងឱ្យដែលនារីដែលយើងត្រូវទៅរៀបការហ្នឹង គេតំណាងឱ្យគូៗហ្នឹងមានបុរសហ្នឹង គឺតំណាងក្នុងកងហ្នឹង នារីក៏ក្នុងកងហ្នឹងដែរ។ គេយកមក គេឡើងចេះ គេចេះនិយាយគេនិយាយទៅ ពីៗការប្តេជ្ញាចិត្តអីៗអ៊ីចឹងទៅ យើងអង្គុយស្តាប់គេទៅ យើងមិនពេញចិត្តទេ អង្គុយតែយំទៅ។

**ស៖** តើក្រោយពីរៀបចំពិធីរៀបការហ្នឹងហើយចប់ តើគេឱ្យអ្នកស្រីទៅៗណាទៀត?

**ឆ៖** ចាស កម្មវិធីគេរៀបអាពាហ៍ពិពាហ៍នេះ គេរៀបការរួចគេមានធ្វើរោងវែងៗៗអ៊ីចឹងគេខណ្ឌៗបាំងបន្ទាំ ខណ្ឌមួយកងៗៗៗ ឱ្យយើងទៅនៅមួយគូៗនៅក្នុងរោងហ្នឹង។ អ៊ីចឹងបើសិនជាខ្ញុំទៅគេរៀបអ៊ីចឹងទៅរហូត ១៥បន្ទប់ហ្នឹងទៅ។ ឱ្យទៅតាមបន្ទប់ៗៗហ្នឹងមួយជួរអ៊ីចឹង គេអត់មានឱ្យយើងទៅដេកឯណាទេ គេមានកន្លែងរបបឱ្យយើងដេក ដាច់ដោយឡែកឆ្ងាយពីកន្លែងនារីកន្លែងបុរស។

[១៤:៣១:១៤]

**ស៖** តើនៅពេលនោះមានការណែនាំឱ្យរួមដំណេកគ្នា ឬមួយមានការតាមដាន ឬមួយអត់ទេ?

**ឆ៖** ចាស សម័យហ្នឹងបើនិយាយភាពជូរចត់ ការហើយគេតាមដាន គេនៅពី គេអើតមើលតាមបង្អួច គេឈរពីចំហៀង គេតាមដានយើងគ្រប់ជំហាន ឱ្យយើងការរួចឱ្យយើងរស់នៅជាមួយគ្នា។ គេតាមពិនិត្យគ្រប់បែបយ៉ាង គឺថាបើយប់ហ្នឹងគឺទល់តែភ្លឺ យើងចេញមកគេជួប ចេញមកក្រៅអ៊ីចឹងគឺជួបតែម្តង ដើរចេញក្រៅមកជួប។ គេ បើគេឃើញយើងចេញព្រឹកពេកគេសួរថា មិត្តឯងទៅណា? ខ្ញុំកាលហ្នឹង ខ្ញុំអត់មានអារម្មណ៍អីចេះស្រលាញ់ ហើយនិងពេញចិត្តអីនឹងអ្នករៀបការជាមួយ ខ្ញុំប្រាប់គាត់

ថា ខ្ញុំចេញមកបត់ជើងអ៊ីចឹងទៅ ខ្ញុំភូតគាត់អ៊ីចឹងទៅ។ ខ្ញុំចេញមកសំកុកខាងក្រៅទៅ កុំឱ្យនៅក្បែរបុរសហ្នឹង។

**ស៖** តើនៅៗរួមរស់ជាមួយគ្នាហ្នឹង នៅបានប៉ុន្មានថ្ងៃដែរ?

**ឆ៖** ចាស កាលសម័យហ្នឹងគេការរួច គេឱ្យរស់នៅជាមួយគ្នាតែ៣ថ្ងៃទេ។ គេមានរបប មួយខែគេឱ្យជួបគ្នាម្តង។

**ស៖** ចាតើនៅពេលនោះដែលបានរស់នៅជាមួយគ្នា៣ថ្ងៃនោះ អ្នកស្រីបានរួមដំណេកជាមួយគ្នា និយាយចំថាបានរួមរក្សជាមួយគ្នាដែរអត់នៅពេលនោះ?

[១៤:៣៣:៣១]

**ឆ៖** ចាស ខ្ញុំការរួច ខ្ញុំគ្មានអារម្មណ៍ទៅរួមរក្សជាមួយបុរសដែលខ្ញុំអត់ពេញចិត្ត។ ខ្ញុំ គាត់ដេកទៅ ខ្ញុំអង្គុយទៅ គាត់ក្រោកខ្ញុំចេញមក ខ្ញុំខ្លាចគាត់ចាប់ខ្ញុំដែរ។ កាលនៅហ្នឹងសហជីពហ្នឹង ខ្ញុំចេះចេញដើរផុតៗដែរ ខ្ញុំអត់បានទៅដេកជាមួយផង។ ថ្ងៃមួយខ្ញុំ វារបៀបអស់កម្លាំងហត់នឿយនឹងការងារផងគាត់មក ខ្ញុំក៏ប្រាស់ដេក ដល់ដេកទៅ លក់។ ដឹងខ្លួនឡើងគាត់ដាក់ដៃលើខ្លួនខ្ញុំអ៊ីចឹង ខ្ញុំក៏ចាប់ដៃគាត់ខាំគាត់ក៏ ខ្ញុំក៏ប្រាប់គាត់ថាកុំដាក់លើខ្លួនខ្ញុំ ព្រោះខ្ញុំមិនអាចបុរសណាប៉ះខ្លួនខ្ញុំបានទេ ព្រោះខ្ញុំតាំងចិត្តតាមឪពុកខ្ញុំគាត់បានអប់រំថា យើងខ្លួនជាស្រី មិនត្រូវការឱ្យប្រុសប៉ះដៃប៉ះជើងទេ។ អ៊ីចឹងខ្ញុំកាន់ពីឪពុកបាន ខ្ញុំអត់ដឹងថាការហ្នឹង ប្រពៃណីរបស់សង្គមផង។ ខ្ញុំអត់ទទួលស្គាល់គាត់ជាប្តីទេ ចាសកាលហ្នឹង។ អ៊ីចឹងខ្ញុំត្រូវមានប្រតិកម្មជាមួយគាត់ ខាំគាត់ឱ្យមានរបួស។

**ស៖** តើរហូតទៅដល់ពេលណាទៅ បានអ្នកស្រីបានអាចចុះសម្រុងជាមួយគាត់ ឬមួយមានការព្រឹត្តិការណ៍អីកើតឡើង ចំពោះអ្នកស្រីនៅពេលនោះ?

[១៤:៣៥:០០]

**ឆ៖** ចាស ខ្ញុំនៅសហជីព អត់ដែលបានរស់នៅជាមួយប្តីរួមរក្សទេ ព្រោះត្បិតអីខ្ញុំ កន្លែងហ្នឹងវាមានកន្លែងដើរចេញបានច្រើន។ ដល់អ៊ីចឹង ការដែលមានស្លាកស្នាមហ្នឹងទៅពីសហជីពខ្ញុំហ្នឹងទៅ គាត់ទៅធ្វើការនៅកន្លែងគាត់ គេឃើញស្លាកស្នាមហ្នឹង គេសួរៗពីមូលហេតុដៃហ្នឹងកើតអី ស្នាមដូចស្នាមធ្មេញ។ គាត់ថា មិនមែន គាត់ភរគេថារលាក ថាអី ក៏អត់ជឿ។ ដល់ហើយគេសួរពីមូលហេតុថា ហេតុអីបានមិត្តឯងមុខស្លូត គេសួរមូលហេតុអីៗអ៊ីចឹង បែបជាគាត់ប្រាប់គេក៏មិនដឹង។ ថ្ងៃក្រោយមក មានរទេះគោមួយមកដឹកខ្ញុំ ម៉ោងប្រហែលជាដប់យប់ មកយកខ្ញុំទៅខាងបុរសហ្នឹង។ ខ្ញុំទៅតវ៉ាជាមួយ

ប្រធានហ្នឹងថា ខ្ញុំមិនទៅទេម្នាក់ឯង ព្រោះសម័យហ្នឹងឲ្យតែរទេះមកយកទៅ គឺបាត់ខ្លួនហើយ អត់មានវិលវិញទេ។ ខ្ញុំថា ខ្ញុំអត់ទៅទេ។ បើឲ្យខ្ញុំទៅម្នាក់ឯង ខ្ញុំអត់ទៅទេ ខ្ញុំប្រកែកអ៊ីចឹង។ ដល់អ៊ីចឹង គេក៏ឲ្យនារីម្នាក់ទៀតឈ្មោះ សុជាតិ ហ្នឹងឲ្យទៅខ្ញុំជាមួយខ្ញុំ។ យប់ហ្នឹងបររទេះគោទាល់តែម៉ោងប្រហែលជាមួយនោះ បានទៅដល់ព្រៃទទឹងហ្នឹង។ ទៅ ក៏គេឲ្យស្នាក់ផ្ទះអ្នកស្រុកមួយ ឲ្យដេកនឹងគេសិន។ ព្រលឹមឡើងបានគេនាំឲ្យទៅផ្ទះគេធ្វើស្ករហ្នឹង គ្រួសារខ្ញុំហ្នឹងគាត់មកនៅនុំងដែរ រម្ងាស់ស្ករនឹងគេ។ គេឲ្យទៅជួបនៅត្រឹមហ្នឹង។ ដល់ពេលទៅ គាត់អត់ទាន់មក មានយាយតាពីរនាក់ តាហ៊ិន យាយឃឹម ហ្នឹង គាត់នៅរម្ងាស់ស្ករហ្នឹង គាត់និយាយជាមួយខ្ញុំថា មិត្តអើយ! សម័យនេះហើយ គេការហើយ រួមរក្សគេទៅជាប្ដីជាប្រពន្ធទៅ។ អត់ដឹងគេសម្លាប់មនុស្សទេអ្ហ៎? ន៎ែ! ឥឡូវតែយើងប្រឆាំងនឹងអង្គការ គេសម្លាប់យើងចោល។ គាត់និយាយខ្ញុំហើយ និយាយទៀត។ ដល់ពេលល្ងាច គេឲ្យគ្រួសារខ្ញុំហ្នឹងឌុបមកកន្លែងប្រធានគាត់ហ្នឹង ប៉ុន្តែអត់បានជួបទេ មក ចុល ហ្នឹង។ អត់ជួប ដល់ទៅស្រាប់តែមានគេមកនាំខ្ញុំទៅដាក់ផ្ទះមួយ ឆ្លងផ្លូវទៅខាងនោះ ឲ្យខ្ញុំទៅសម្រាកឯនុំង។ ខ្ញុំក៏ទៅ ខ្ញុំប្រាប់យាយហ្នឹងថា កុំទៅចោលខ្ញុំ បើឲ្យខ្ញុំមកហ្នឹង ខ្ញុំអត់ហ៊ានដេកទេម្នាក់។ គាត់ក៏នៅនិយាយលេងៗអ៊ីចឹងទៅ ក៏គ្រួសារខ្ញុំគាត់ឡើងទៅ ក៏គាត់ចុះមក។ ហ្នឹងយប់ទី១ គាត់ចេះតែលួងលោមខ្ញុំ បបោសអង្អែលខ្ញុំដែរ ប៉ុន្តែខ្ញុំចេះតែរត់ ខ្ញុំមិនឲ្យគាត់ប៉ះខ្លួន។ ប៉ុន្តែបើខ្ញុំចុះទ្វារក្រោយ លោតទ្វារក្រោយ គាត់ថាលោតទៅ គេនៅចាំចាប់ខាងក្រោម។ ខ្ញុំមកខាងមុខ គាត់ថា ទៅៗ ប៉ុន្តែខ្ញុំឃើញមានមែន មានមនុស្សខ្មៅស្លុងៗនៅនុំងមែន។

[១៤:៣៧:៥៤]

ដល់យប់ទី២ យប់ទី៣ ខ្ញុំនឹងដូចថាថ្ងៃខ្ញុំមិនដែលចុះ ខ្ញុំខ្មាស់គេផង ខ្ញុំតូចចិត្តផង យប់ខ្ញុំចុះទៅងូតទឹក។ ទៅក៏មានយុវជននៅក្នុងនុំង គាត់ដើរមក។ ដើមមក សួរខ្ញុំធ្វើអី? ខ្ញុំថាខ្ញុំដងទឹកងូត។ គាត់ក៏ថា អ្ហ៎មកខ្ញុំដងឲ្យ ងឹតអ៊ីចឹងខ្ញុំដងឲ្យ។ គាត់ដងឲ្យខ្ញុំងូតឲ្យអីអ៊ីចឹងទៅ ខ្ញុំក៏ឡើងទៅលើវិញ។ ដល់ខ្ញុំឡើងទៅលើវិញ គាត់ក៏ចេះអង្វរថា ដេកទៅ ស្គមហើយ អត់ងងុយ។ មិត្តឯងចេះតែរត់ ខ្ញុំប្ដីសោះ មិត្តឯងអីៗចេះតែលួងលោមខ្ញុំ។ ដល់ខ្ញុំអត់ងងុយពីរបីយប់ដែរ ដល់ពេលនុំងក៏ខ្ញុំដេកលក់ទៅ។ លក់ទៅ ដឹងខ្លួនឡើង ក៏ឃើញគាត់ឱបខ្ញុំ រឹតខ្ញុំហ្នឹងទៅ ខ្ញុំរើបម្រាស។ ដល់រើបម្រាស គាត់ វាចៃដន្យថា ទឹកចិត្តបុរសពេលឃើញស្ត្រី ក៏គាត់ចាប់ខ្ញុំហែកអាវ ហែកខោខ្លីខ្ញុំ អាវទ្រនាប់ខ្ញុំដាច់ឡេវអស់ទៅ ក៏គាត់ចាប់ផ្ដើមរំលោភខ្ញុំ។ ខ្ញុំក៏យំ ខ្ញុំស្រែកទៅ។ គាត់ថា កុំស្រែកខ្មាស់គេ យើងប្ដីប្រពន្ធទេ។ អាហ្នឹងលើកទី១ ដំបូង។

**ស៖** បាទ អរគុណ។ អ៊ីចឹងចាប់មានន័យថា ចាប់ពីពេលនោះមក អ្នកស្រីបានរួមរស់នៅជាមួយ

គាត់រហូតមក ឬមួយយ៉ាងណា?

**ឆ៖** ចាស ខ្ញុំរស់តែដឹងគេរំលោភខ្លួនបានហ្នឹងទៅ ក៏ខ្ញុំមកនៅសហជីពវិញ។ គាត់ក៏នៅនុ៎ងទៅបែកគ្នាវិញដដែល។

**ស៖** ហើយបន្ទាប់ពីហ្នឹងមក ថាតើអ្នកស្រីមានអាការៈអ្វីទេនៅក្នុងខ្លួនហ្នឹង ដែលអាចសម្គាល់ឃើញថា វាមានបញ្ហាសុខភាពនៅក្នុងខ្លួនទេ?

[១៤:៤០:១៩]

**ឆ៖** ក្រោយមក ខ្ញុំនៅនឹងសហជីពហ្នឹង ដល់ក្រោយមកគេរំសាយ។ រំសាយ គាត់សុំខ្ញុំឱ្យទៅនៅជាមួយគាត់ទៅ ព្រោះត្បិតអីខ្ញុំបានលង់ខ្លួនជាមួយគាត់។ គាត់សុំទទួលស្គាល់ថា គាត់ហ្នឹងគ្រប់គ្រងខ្ញុំអ៊ីចឹងទៅ លួងលោមខ្ញុំ ខ្ញុំក៏តាមគាត់ចេញពីសហជីពទៅនៅសហករណ៍ នៅភូមិតាពយ ឃុំតាំងក្រាំង ស្រុកបាធាយ ចាសខ្ញុំទៅនុ៎ង។ ពេលខ្ញុំទៅនុ៎ងបានប្រហែលជាមួយខែ ក៏ខ្ញុំចាប់ឈឺ ឈឺកាលហ្នឹង ហូបមិនគ្រប់គ្រាន់ផង បែបជាខ្ញុំចាញ់ផង។ ខ្ញុំចាញ់កូនក្នុងផ្ទៃផង ប៉ុន្តែសម័យហ្នឹងអត់ដឹង។ ដល់ពេលទៅគេបញ្ជូនខ្ញុំមកដេកពេទ្យ។ ពេទ្យពីដំបូង ដេកពេទ្យឃុំគេហ្នឹង នៅភ្នំជីលានេះ នៅទីតាំងសព្វថ្ងៃ បើតាមខ្ញុំនៅភ្នំជីលាខាងណេះ នៅខាងណេះមន្ទីរពេទ្យហ្នឹង។ ដល់ខ្ញុំ ជំងឺខ្ញុំមិនធូរស្បើយ ក៏សុំបញ្ជូនមកបាធាយ។ ដល់មកបាធាយបានតែពីរបីថ្ងៃទេ បាធាយហ្នឹងវាពិបាក រឹតតែឈឺធ្ងន់ឡើង ថ្នាំក៏មិនមានព្យាបាល ហើយមានតែអ្នកស្លាប់ ហើយហូបមិនគ្រប់គ្រាន់ គ្មានទឹកគ្មានអី ថ្នាំក៏គ្មាន ក៏សុំមកតំបន់។ អ៊ីចឹងជំងឺខ្ញុំហ្នឹង ឈឺពីថ្នល់កែងហ្នឹងមក បានមករហូតដល់តំបន់៤១ហ្នឹងនៅស្រុកព្រៃឈរ ខេត្តកំពង់ចាមហ្នឹង មកមន្ទីរពេទ្យតំបន់ហ្នឹង។

**ស៖** ហើយថាតើនៅពេលណាដែលអ្នកស្រីបានដឹងថាមានគភ៌?

**ឆ៖** ចាស ដល់មកពេទ្យតំបន់ហ្នឹង ក៏គេព្យាបាលជំងឺផង គេពិនិត្យពីសុខភាពពីអីទៅ គេថាខ្ញុំហ្នឹងមានកូនអ៊ីចឹងទៅ នៅពេទ្យតំបន់ ដឹងត្រឹមនៅពេទ្យតំបន់ហ្នឹង។

**ស៖** នៅពេលដែលអ្នកស្រីដឹងថា មានកូនហើយហ្នឹង តើគេឱ្យថែរក្សាសុខភាពយ៉ាងដូចម៉េចដែរ ឬមួយនៅធ្វើការជាធម្មតាទេ?

[១៤:៤២:៥១]

**ឆ៖** ចាស ខ្ញុំចេញពីមន្ទីរពេទ្យទៅ ដឹងថាមានគភ៌។ នៅនុ៎ងខ្ញុំទៅដំបូង ខ្ញុំទៅសម្រាកបានប្រហែលជាកន្លះខែ ម៉ែខ្ញុំគាត់ថា អត់ឱ្យទៅថ្នល់កែងវិញទេ ព្រោះត្បិតអី គេត្រូវជម្លៀសគាត់ទៅនៅ

សហករណ៍ថ្មី។ អ៊ីចឹងគាត់សុខចិត្តឲ្យនៅជុំគ្នាទៅ ទៅណា ទៅទាំងអស់គ្នា។ ដល់អ៊ីចឹងទៅក៏នៅ ដល់នៅទៅ ទៅសុំប្រធានកងនៅ ប្រធានកងគេថា ឲ្យមានលិខិតបញ្ជាក់ពីភូមិឃុំដែលយើងទៅស្នាក់ដំបូងហ្នឹងមកវិញមក បានគេឲ្យ។ ទៅក៏គាត់ហ្នឹងសុំគេ ខ្ចីកង់គេហ្នឹងជិះមក នៅស្រុកបាធាយហ្នឹង នៅឃុំតាំងក្រាំងហ្នឹង ពីដើមគេហៅ ឃុំតាំងក្រាំង នៅថ្នល់កែងហ្នឹង។ ក៏បានលិខិតបញ្ជាក់ហ្នឹងបានមក បានគាត់យកទៅឲ្យមេកងនៅក្នុងសហករណ៍ហ្នឹង បានគាត់ទទួលឲ្យនៅ។

**ស៖** ទន្ទឹមអ្នកស្រីមានផ្ទៃពោះហ្នឹង ហើយតើប្ដីអ្នកស្រីគេបានបញ្ជូនទៅខាងណា ឬមួយនៅជាមួយ?

**ឆ៖** ចាស សម័យហ្នឹង អត់មានបាននៅជាមួយគ្នាទេ។ ដល់មកនៅសហករណ៍ហ្នឹង គេឲ្យប្ដីខ្ញុំនៅចិញ្ចឹមទា នៅកន្លែង ត្រង់នុំងគេហៅសង្កាត់ដែរ ពីដំបូងហ្នឹងគេឲ្យនៅចិញ្ចឹមទានុំង។ ខ្ញុំគេឲ្យនៅសហករណ៍ហ្នឹង គេឲ្យទៅធ្វើបាយ កាលនុំងគ្មានអង្ករអីច្រើនទេ មានតែពោត ឈូសពោត ឈូសចេកលាយបាយលាយអីហ្នឹង ទុកឲ្យប្រជាពលរដ្ឋហូប។ អ៊ីចឹងការងារដែលខ្ញុំនៅសហករណ៍ហ្នឹង ក៏អត់នៅជុំគ្នាដែរ នៅដោយឡែកពីគ្នា។

**ស៖** ចាតើ--

**ប្រធានអង្គជំនុំ៖**

បាន! បាន! បានហើយ! បានហើយ!

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

01365123



អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តី - - មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ បន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទ អរគុណលោកប្រធាន។ ខ្ញុំសូមបន្តសំណួរតិចទៀត។ អម្បាញ់មិញលោកស្រីបាននិយាយអំពីការរៀបការ ហើយនិងការផ្សំដំណេក ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ថាតើមុននឹងគេផ្តល់ព័ត៌មាន មុននឹងគេហៅទៅ ថាតើមានការផ្គូផ្គងជាមួយគូណា គូណាដែរអត់ទេ?

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** កាលដែលគេការហ្នឹង គេគ្មានប្រាប់គូយើងថា ខ្ញុំត្រូវជាគូជាមួយបុរសណាផង ព្រោះត្បិតអី ពេលហ្នឹងគេហៅខ្ញុំទៅការ ដល់ពេលគេផ្គូផ្គឹមទៅ ខ្ញុំឱនទៅក្រោមឃើញជើងគាត់ធំៗ ហើយពិការ ខ្ញុំមានបានមើលមុខមើលអីទេ។ ដល់ឃើញអ៊ីចឹងទៅ ខ្ញុំរឹតតែតូចចិត្តថែមទៀត ធ្វើឲ្យអារម្មណ៍ខ្ញុំហ្នឹងក្តុកក្តួល ចេះតែឃំ មានបានមើលទៅគាត់អី ថាគាត់ជាមនុស្សអីផង ខ្ញុំអត់បានមើល។

**ស៖** តើគាត់ពិការជើង ឬមួយពិការអីផ្សេងទៀត?

**ឆ៖** ចាស *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

[១៥:០៣:៣៦]

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ថ្ងៃការខ្ញុំឃើញពិការជើង។ ដល់ក្រោយមកបានដឹងថាគាត់ពិការដៃផង ពិការភ្នែកផងចាស។ ដៃគាត់ក្រងេម្រាមដៃអ៊ីចេះ ហើយភ្នែកគាត់ងងឹតមួយចំហៀងដែរ។ អ៊ីចឹងខ្ញុំឃើញភាពរឹតតែតូចចិត្តនឹងដែលគេផ្គូផ្គងឲ្យខ្ញុំហ្នឹងចាស។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** តើគេមានបានប្រាប់ជាៗការណែនាំថា អ្នកស្រីត្រូវតែរៀបការ? ហើយៗតើវាមានបញ្ហាអីអត់ បើពេលនុ៎ងយើងយល់ព្រមរៀបការ ឬមួយយើងអត់ទេ? ហ៊ានប្រឆាំងដែរអត់?

**ឆ៖** ចាស កាលក្នុងរបបហ្នឹងគ្មានមនុស្សណាហ៊ានប្រឆាំងនឹងអង្គការបក្សទេ បើគេថាឲ្យធ្វើអី

យើងធ្វើហើយ ទោះបីជាយើងត្រូវគ្នា មិនត្រូវគ្នា យើងលាក់លួចនៅក្នុងអារម្មណ៍ទៅ។ បើសិនជាយើងហ៊ានបញ្ចេញ មានតែសេចក្ដីស្លាប់ ព្រោះត្បិតអីសម័យនុំងគេមិនដែលឃោគយល់ថា ម៉ែឪ ដូចម៉ែឪរៀបចំឲ្យ បើអ្នកឯងមិនស្រឡាញ់ទេ អាចលែងគ្នាបាន សម័យនុំងគ្មានឲ្យលែងបានទេ។ បើអ្នកឯងមិនស្រឡាញ់ មិនពេញចិត្ត មិនគោរពតាមអង្គការវិន័យ គេនឹងសម្លាប់មិនឲ្យយើងឃើញម៉ែឪទៀតអុំ្ហសម្លាប់ចោលដូចសត្វដូចធាតុអ៊ីចឹង។

**ស៖** អរគុណ។ ត្រង់ចំណុចហ្នឹងហើយដែលថា តើមាននរណាជាអ្នកណែនាំ? តើមេកង ឬមួយមេក្រុម ឬមួយនរណាដែលណែនាំអាភាសាអស់ហ្នឹង?

[១៥:០៥:៣៤]

**ឆ៖** ចាស កាលនុំងដែលខ្ញុំរៀបរួចទៅ ដូចថាអាពាក្យចចាមអារ៉ាមគេដឹងល្បៀងៗទៅ គេនិយាយថា មិត្តឯង! តែបើមិនគោរពអង្គការវិន័យទេ មិត្តឯងមុខជាទៅនៅដេកកន្លែងសុបហើយ គេប្រាប់ខ្ញុំអ៊ីចឹង។ ហើយខ្ញុំធ្វើអារម្មណ៍នឹងនរ ខ្ញុំធ្វើថាដូចត្រូវរូវគ្នាទៅ ខ្ញុំមានទៅផ្ដាស់ប្ដូរឲ្យគេដឹងចរិតអី ខ្ញុំចេះតែថា ទៅនៅសុបអី បើដេកជាមួយគ្នារាល់យប់ ទៅនៅឯណា បើខ្ញុំមកខ្ញុំដែលទៅដេកឯណា ខ្ញុំមានមកដេកកន្លែងណា ខ្ញុំដេកតែជាមួយគាត់ដែរ។ ខ្ញុំបាននិយាយប្រាប់គាត់អ៊ីចឹង អ៊ីចឹងក៏គាត់តាមដានដឹងថាខ្ញុំ សួរមិត្តនៅកន្លែងអ៊ីចឹងទៅ សួរថាមិនដែលឃើញមកដេកមែនពេលគ្រួសារមក។ ដល់អ៊ីចឹងគេជឿនៅសហជីពហ្នឹងគេជឿខ្ញុំ។

**ស៖** តើចំណុចហ្នឹងអ្នកស្រីមានការភ័យខ្លាចដែរអត់ទេ?

**ឆ៖** ខ្ញុំក្រោយពីរៀបការរួច អារម្មណ៍ខ្ញុំភ័យខ្លាច គិតដេកមិនលក់ ស៊ីមិនឆ្ងាញ់ ទៅធ្វើការងារហើយទាំងលំបាក ការងារផង មកវិញហូបចុកមិនគ្រប់គ្រាន់ផង អារម្មណ៍ភ័យខ្លាចគេសម្លាប់ផង។ ដល់អ៊ីចឹងគឺថាអារម្មណ៍ខ្ញុំហ្នឹង គិតតែពីសេចក្ដីស្លាប់មួយមុខ គិតឃើញថាបើសិនជារឿងរ៉ាវដែលខ្ញុំធ្វើនេះដឹងដល់អង្គការ គេនឹងសម្លាប់ខ្ញុំ។ ប៉ុន្តែខ្ញុំខំកែប្រែចរិត ធ្វើឲ្យល្អ មិនឲ្យមិត្តក្នុងរួមការងារជាមួយនឹងអត់ឲ្យដឹង ទោះអ្នកណាក៏គេ ខ្ញុំមិនដែលនិយាយប្រាប់គេថាខ្ញុំមិនត្រូវរូវគ្នាដែរ។ ខ្ញុំនៅតែលាក់គំនិតរហូតបើគេមក កាលហ្នឹងវាមួយខែមកម្ដង រួចខ្ញុំចង់ភ្លេចប្ដីបាត់ទៅហើយ បានគេឲ្យជួបម្ដងទៀត។ ដល់ពេលទៅជួបហ្នឹងវាភ្លេចមុខភ្លេចមាត់អស់ ដល់អ៊ីចឹងទៅគេសួរថា អ្ហា! គ្រួសារមកហើយ ប៉ុន្តែវាមិនចាំថាមុខហ្នឹងជាគ្រួសាររបស់ខ្ញុំ។ ដល់ទៅគេសួរថា មិត្តនេះឡើឡើៗ ប្ដីមកដើរហួសទៅហួសមក។ ប៉ុន្តែខ្ញុំភ្លេច ខ្ញុំភ្លេចថា ប្ដីហ្នឹងមុខខ្ញុំ មិនបានមើលមុខគាត់ច្បាស់ ដល់អ៊ីចឹងខ្ញុំអត់ដឹងថា គាត់ហ្នឹងមុខអ៊ីចឹង។ ដល់អ៊ីចឹង

ខ្ញុំមិនដឹងមួយណាប្តីខ្ញុំ បើបុរសគេអង្គុយគ្រែដែរ ខ្ញុំអត់ស្គាល់។ ដល់តែទៅ គេបានគេឲ្យ គេជូនខ្ញុំថា ទៅនាំគ្រួសារទៅកន្លែង។ ដល់ពេលទៅ មានប្រធានកងហ្នឹងគាត់នាំខ្ញុំមក បានគាត់ដើរតាមមក បានខ្ញុំដឹងថាគាត់ជាប្តីរបស់ខ្ញុំ។

[១៥:០៨:១៥]

**ស៖** ចំណុចមួយទៀតដែលលោកស្រីបានរៀបរាប់អម្បាញ់មិញថា ពេលដែលរៀបការរួចគេឲ្យទៅសម្រាន្តនៅផ្ទះល្វែងមួយ។ ផ្ទះហ្នឹងវាជា រៀបចំជាផ្ទះសម្រាប់ទុកអ្នកដែលរៀបការហើយហ្នឹងទៅសម្រាន្តហ្នឹង ឬមួយយ៉ាងណា?

**ឆ៖** ចាស កាលហ្នឹងគេធ្វើផ្ទះល្វែងហ្នឹង គេធ្វើទុកសម្រាប់តែអ្នកដែលរៀបការទេ។ រៀបការបើពួកនៅនឹងសហជីពហ្នឹងការរួច គេឲ្យទៅជួបគ្នាមួយខែបីដងដូចគ្នា បីថ្ងៃដូចគ្នា។ អ្នកគ្រួសារនៅឆ្ងាយក៏ជួបដូចគ្នា។ ដល់កំណត់ណាត់ បើគេអ្នកយល់ចិត្តគ្នា ដល់កំណត់ណាត់ គេកាត់ទៅកន្លែងគេស្រេចទៅ។ បើដូចយើងអត់ត្រូវចិត្តគ្នាអ៊ីចឹង គេមកយើងអត់ចង់ទៅ ដល់អ៊ីចឹងការតាមដានរបស់អង្គការហ្នឹង គេចេះតែគឺថាប្រមាថមើលងាយ គំរាមកំហែង ឲ្យយើងហ្នឹងតក់ស្លុតខ្លាច ថាឲ្យតែពេលគ្រួសារមកខ្ញុំយំរហូត ព្រោះគេគំរាមខ្ញុំរហូត ខ្ញុំអត់មានសេចក្តីសុខ។ ទៅដេកគ្មានមុង គ្មានភួយទេ កន្លែងហ្នឹងមានតែផ្ទើរហ្នឹង គេឲ្យដេកទៅ មានតែកន្ទេលកញ្ចាស់ៗ គេក្រាលឲ្យទេ គ្មានភួយ គ្មានមុងឲ្យយើងដណ្តប់ទេ គ្មានខ្នើយឲ្យយើងកើយទេ។ កន្លែងហ្នឹងគឺឲ្យយើងរស់នៅដោយវេទនា។ បើសិនជាយើងគេខ្លះគេបានត្រៀមលក្ខណៈខ្លួនគេទៅ គេរៀបចំខ្លួនគេ គេមានសម្ភារៈ បើដូចខ្ញុំ ទៅដូចទៅខ្មួចម្ការ កើយគល់ឫស្សីអ៊ីចឹង គ្មានអីទេ។

**ស៖** តើចំណុចដែលគេថា ឲ្យមួយខែជួបម្តងហ្នឹង ថាតើនរណាជាអ្នកដាក់ឲ្យការជួបហ្នឹង?

[១៥:១០:៣០]

**ឆ៖** ក្រោយពីរៀបការរួច មិត្តសូ ហ្នឹងគេប្រជុំ មានវេទិកាមួយអ៊ីចឹង គេប្រាប់ថា អ្នកដែលបានរៀបការហើយ គឺមិនបានរស់នៅជាមួយគ្នាស្ថិតថេរទេ គេឲ្យមានរបបជួបគ្នា ថា១ខែត្រូវជួបគ្នា៣យប់ បើអ្នកណាហួសកម្រិត ក៏គេដាក់ពិន័យដែរ។ ដល់អ៊ីចឹង ក្រោយៗមកក៏អ្នកការ ដែលក្រោយៗទៀតហ្នឹង ក៏គេអត់ដាក់ពិន័យតាមហ្នឹងដែរ។ ហើយខ្ញុំ ការហ្នឹងអ៊ីចឹងដែរ។ គាត់ ការរួចគាត់ទៅកន្លែងគាត់បាត់ទៅ ខ្ញុំនៅកន្លែងសហជីពហ្នឹងទៅ។ ដល់ពេលគាត់ គេឲ្យគាត់មកបានគាត់មកដែរ។ មកទៅគាត់ត្រូវទៅជួប មិត្តសូ ហ្នឹងសិន។ មិត្តសូ ហ្នឹងត្រូវនាំព័ត៏មានមកឲ្យខ្ញុំដឹង បានខ្ញុំទៅជួប។

**ស៖** ចំណុចអ្នកស្រីបានលើកឡើងអម្បាញ់មិញថា មានការបង្ខិតបង្ខំចាប់រំលោភពីសំណាក់ប្ដី។ ថាតើពេលនុំងគាត់ធ្វើយ៉ាងដូចម្ដេចដែរ ឬមួយគាត់បាននិយាយថា យ៉ាងដូចម្ដេចដើម្បីឲ្យអ្នកស្រីយល់ស្រប ឬមួយបញ្ចុះបញ្ចូលយ៉ាងដូចម្ដេចដែរ?

**ឆ៖** ចាស កាលដែលគាត់បង្ខំឲ្យខ្ញុំរួមរក្ស គាត់ពេលហ្នឹងគាត់ ថ្ងៃហ្នឹងខ្ញុំងងុយដេកពេក ខ្ញុំទៅដំបូង ខ្ញុំចេះអត់ប៉ានដេកទេ ដល់ថ្ងៃហ្នឹងខ្ញុំដេកលក់។ ដល់ដេកលក់ទៅ គាត់ឱបខ្ញុំ ដល់ខ្ញុំរើបម្រះ រករត់រកអី អ៊ីចឹងទៅ គាត់ចាប់ខ្ញុំរំលោភ ដូចថា បើនេះទៅគាត់ដោះអាវ ដោះខោខ្ញុំទៅ គាត់ហែកខោខ្លីខ្ញុំហ្នឹងទៅ ហើយទៅគាត់ទាញបណ្ដាច់ឡេវអាវខ្ញុំ ខ្ញុំខំយកដៃខ្ទប់អ៊ីចេះ គាត់ថា ប្ដីប្រពន្ធសោះ នែ៎អង្គការសម្លាប់ចោល ងាប់ទាំងអស់គ្នា។ គាត់សម្លុតខ្ញុំដែរ គាត់គំរាមខ្ញុំដែរ។ ដល់ទៅ ខ្ញុំយំផងអីផងទៅ ខ្ញុំថា ឪខ្ញុំមិនឲ្យគេធ្វើអ៊ីចឹងទេ ព្រោះត្បិតអី ឪខ្ញុំហាមណាស់ ខ្ញុំស្រី មិត្តឯងប្រុស មកធ្វើអីខ្ញុំអ៊ីចឹង។ គាត់ថា អត់ទេ អានេះគឺទិសដៅរបស់អង្គការទេ អ៊ីចឹងគាត់ត្រូវធ្វើទៅតាមទិសដៅអង្គការ។ ខ្ញុំយំរហូតទល់តែភ្លឺ។

[១៥:១៣:១៨]

**ស៖** ខ្ញុំសូមបញ្ជាក់មួយថា តើប្ដីអ្នកស្រីហ្នឹងមានបានជម្រាប បានលើកថា គាត់ត្រូវបានគេបង្ខំឲ្យធ្វើអ៊ីចឹង ឬមួយយ៉ាងណា?

**ឆ៖** កាលនុំងគាត់ធ្វើហ្នឹង ខ្ញុំមិនដឹងថា អង្គការគេអ្នកឲ្យធ្វើឬអត់ទេ ព្រោះកាលណាដែលគាត់ទៅធ្វើលើខ្ញុំហ្នឹង ដូចយើងមនុស្សកំរោលដែរហ្នឹង គាត់ទៅបំពារបំពានលើខ្ញុំដើម្បីសម្រាប់គោលបំណងគាត់ដែរ។ ប៉ុន្តែខ្ញុំមិនបានដឹង ប៉ុន្តែដល់ពេលខ្ញុំយំស្រែក គាត់ថា ទិសដៅរបស់អង្គការ គេឲ្យយើងរស់នៅអ៊ីចឹង។ បើយើងនៅតែមិនអ៊ីចឹង យើងគឺត្រូវតែស្លាប់ទាំងអស់គ្នា។ អ៊ីចឹងខ្ញុំមិនដឹងថា អង្គការគេប្រើគាត់ធ្វើ ឬក៏គាត់ធ្វើខ្លួនគាត់ទេ។

**ស៖** តើពេលនោះ អ្នកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំ ពេលហ្នឹងខ្ញុំឈឺចាប់ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ។ ទី១ ការរួមរស់ដែលយើងមិនដែលធ្លាប់ធ្វើឲ្យចុកចាប់នៅលើរាយកាយរបស់ខ្លួន។ ហើយទី២ ចុកចាប់លើផ្លូវចិត្តដែលខ្ញុំមិនមានបំណងកសាងអនាគតប្ដីសីសោះ។ ដល់អ៊ីចឹងខ្ញុំមានតែសេចក្ដីយំស្រែក ស្ដាយ។ ណាមួយគឺថាក្បត់នឹងបណ្ដាំឪពុកផងអ៊ីចឹងធ្វើឲ្យអារម្មណ៍ខ្ញុំហ្នឹងណ៎ា ឈឺចាប់ក្នុងការរួមរក្សហ្នឹងផង ឈឺចាប់ផ្លូវចិត្តផង ធ្វើឲ្យខ្ញុំដេកមិនលក់ហូបបាយមិនឆ្ងាញ់។ ដល់អ៊ីចឹង វាឲ្យប្រែអាកាសធាតុខ្ញុំទៅជាស្លេកស្លាំង។

[១៥:១៥:៣០]

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំសូមចូលទៅចំណុចមួយទៀតដែលអ្នកស្រី ពេលដែលអ្នកស្រីមានគភ៌ ថាតើក្នុងរយៈពេលហ្នឹង ប្ដីអ្នកស្រីត្រូវបានគេបញ្ជូនចេញទៅឆ្ងាយ ថាតើទៅខាងណា? ទៅធ្វើការ ទៅ គាត់ទៅធ្វើការអី? នៅកន្លែងណា?

**ឆ៖** ចាស ប្ដីខ្ញុំមកពីថ្នល់កែង មកនៅថ្មពួនដំបូង បានទៅសុំប្រធានកង សុំលិខិតមកនៅនឹងសហករណ៍នៅក្នុងឃុំថ្មពួនហ្នឹង។ ដល់ពេលទៅ គេបំបែកឲ្យទៅធ្វើការនៅ ចិញ្ចឹមទានៅជាមួយសង្កាត់។ ដល់សង្កាត់ហ្នឹង គេចិញ្ចឹមទាហ្នឹងរីកចម្រើនទៅ គេបញ្ជូនប្ដីខ្ញុំហ្នឹងឲ្យទៅនៅឯព្រៃឈរហ្នឹង កន្លែងសិប្បកម្មហ្នឹង គេត្បាញក្រមា គេវ៉ៃកាំបិត វ៉ៃពូថៅ សម្រាប់កសិករធ្វើស្រែចម្ការហ្នឹង សម្រាប់សហករណ៍ហ្នឹង។ ដល់ទៅ ក៏គាត់ទៅនៅនុ៎ង ទៅនៅនុ៎ងគេឲ្យភ្ញាស់ទាដែរ។ រួចគាត់ យូរៗគាត់មកលេងម្ដង គាត់ចេះតែនិយាយប្រាប់ខ្ញុំថា អូ្ន! គេចេះតែប្រជុំលើកថា ជនពិការទុកមិនចំណាញ យកចេញមិនខាតទេ ខ្ញុំប្រហែលជាមិនបានឃើញមុខកូនទេមើលទៅ។ គាត់ចេះតែនិយាយប្រាប់ខ្ញុំ។ រួចខ្ញុំ ថ្ងៃមួយនោះ ប្រហែលជាមុននឹងខ្ញុំកើតហ្នឹង គាត់មកម្ដងហ្នឹង គាត់មកសុំខ្ញុំរត់ចូលព្រៃ។ ខ្ញុំថា "អូ្ន! កែវ អើយ! បើបងកែវ ឯងចង់រត់ចូលព្រៃ ខ្ញុំក៏ស្លាប់ដែរ។ បើបងកែវ ឯងរត់ចូលព្រៃ បងកែវ ឯងស្លាប់ខ្ញុំឲ្យស្លាប់សិនទៅ ឲ្យមានបញ្ហាថា បងកែវ ឯងហ្នឹង មានបញ្ហាទំនាស់ជាមួយខ្ញុំចុះ។ ហើយបងកែវ ឯងរស់ចុះ ខ្ញុំស្លាប់។" ខ្ញុំនិយាយទាំងយំប្រាប់ប្ដីអ៊ីចឹង។ គាត់ក៏ថា អូ្ន! អាណាដាច់ចិត្តសម្លាប់។ គាត់និយាយទាំងទឹកភ្នែក គាត់ថាហើយ បើអ៊ីចឹងបណ្ដោយទៅតាមគេអ្នកប្រមាថទៅ បើសិនអាយុខ្ញុំវែ្វ ខ្ញុំនៅចិញ្ចឹមឯង។ បើសិនជាខ្ញុំ គេយកខ្ញុំទៅសម្លាប់ យើងព្រាត់គ្នាត្រឹមហ្នឹង។ ដូចផ្ដាំចុងក្រោយអ៊ីចឹង។ គាត់មកអ៊ីចឹងទៅ គាត់និយាយប្រាប់អ៊ីចឹងហូរហែ រួចទៅគាត់ទៅវិញហ្នឹង។ គាត់ទៅឯព្រៃទទឹងហ្នឹងវិញទៅ បាត់រហូត។ បាត់រហូត ដល់១០ថ្ងៃក្រោយមក ឪខ្ញុំហ្នឹង គាត់ទៅសួរសង្កាត់ កប ហ្នឹងថា នែ៎! មិត្តអ្នា! មិត្តកែវ នៅធ្វើការឯណា ក៏មិនឲ្យមកផង ប្រពន្ធឈឺពោះកើតហើយណេះ? ឪខ្ញុំហ្នឹងទៅប្រាប់ មិត្តកប អ៊ីចឹង។ រួចទៅមិត្តកប ហ្នឹងថា អត់អីទេ! អ៊ំៗ ចាំខ្ញុំប្រាប់ឲ្យ។ ភរឪខ្ញុំអ៊ីចឹង។ ឪខ្ញុំមកវិញ រួចសម័យនុ៎ងមានចង្កៀងមានអីអុជ មានប្រេងអីអុជ គាត់ទៅស្ពាយតែអាចម៍រណារគេឈូសសិប្បកម្មហ្នឹង យកមកដុតទ្រោលមើលចៅ។ អត់មានអីប្រើប្រាស់។

[១៥:១៨:៤០]

ជីវិតខ្ញុំ បើសម័យហ្នឹងបើសិនជា គឺថាអារម្មណ៍ខ្ញុំហ្នឹង កាត់ខ្លះអីខ្លះ កុំអីខ្ញុំស្លាប់សម័យនុ៎ងហើយ ប៉ុន្តែខ្ញុំគិតថា បើខ្ញុំស្លាប់ អាណិតកូន។ អ៊ីចឹងខ្ញុំស៊ូទ្រាំ ខាំមាត់សង្កត់ចិត្ត ឱបកូនទាំងទឹកភ្នែក ដើម្បីឲ្យកូន

ហ្នឹងនៅនឹងខ្លួន។ ដល់កូនហ្នឹងកើតបាន ប្រហែលជាមួយខែ ខ្ញុំមិនទាន់គេហៅទៅធ្វើការទេ ស្រាប់តែ មិត្តយ៉េន ហ្នឹង គេឡើងមកពិនិត្យផ្ទះខ្ញុំ ឆែកមើល ក្រែងយើងលាក់អីៗអ៊ីចឹងទៅ គេមើលរួចអីរួច គេមក មើលកូនខ្ញុំ គេថា អ៊ា! កូនហ្នឹង បើអង្គការសុំយកទៅកម្ទេចចោល ឲ្យអត់? ហើយខ្ញុំក៏យំ។ ខ្ញុំយំថា បង យ៉េន ឯងគិតមើលទៅ កូនខ្ញុំកើតឡើងភ្នែកខ្មៅក្រិប បើ បងយ៉េន ឯងយកកូនខ្ញុំទៅសម្លាប់ សម្លាប់ខ្ញុំទៅ ក៏កូនខ្ញុំស្លាប់ដែរ វាអត់មានអីបៀទេ។ ខ្ញុំនិយាយទាំងទឹកភ្នែកប្រាប់គាត់អ៊ីចឹង។ ដល់ទៅក៏ មិត្តយ៉េន ហ្នឹង គាត់ចុះផុតទៅ។ ដល់ពីរបីថ្ងៃក្រោយមក មានឈ្មោះ មិត្តយួយ ហើយ មិត្តយូន នេះ គាត់មកលាខ្សែ អង្រឹងនឹងជណ្តើរផ្ទះខ្ញុំហ្នឹង។ ធ្វើឲ្យអារម្មណ៍ខ្ញុំនេះភ័យកត់ស្លុត ញាប់ញ័រ ទៅជាទាស់សរសៃ ឈឺរ៉ុាំរ៉ៃ។ អ៊ីចឹងថា នៅក្នុងពេលខ្ញុំឆ្លងទន្លេហ្នឹង ខ្ញុំទទួល គឺថារងទុក្ខការគំរាមកំហែងពីក្នុងរបបហ្នឹង មេដឹកនាំហ្នឹង អ្នកដែលនៅសហករណ៍ហ្នឹងខ្លាំងបំផុតមែនទែន។

[១៥:២០:២២]

**ស៖** តើនៅពេលដែលអ្នកស្រីសម្រាលកូនហ្នឹង ថាតើមានសេវាសុខាភិបាលគេទ្រទ្រង់យ៉ាង ម៉េចដែរ?

**ឆ៖** ចាស បើនិយាយជីវិតអ្នកឆ្លងទន្លេសម័យនុ៎ងវិញ ផ្សងព្រេងគ្មានពេទ្យ គ្មានឆ្មបជំនាញទេ កើតដោយអ្នកចេះបន្តិចបន្តួច។ បើខ្ញុំ ៗកើតហ្នឹងអ្នកជិតខាងគាត់នៅក្បែរនុ៎ងក្មេងដែរ ប៉ុន្តែដល់ពេល យើងគ្មានទៅ គាត់ថាមិនអីទេចាំខ្ញុំបង្កើតឲ្យ។ អ៊ីចឹងក៏គាត់មកបង្កើតទៅ បានសុខស្រួលដែរ អត់មាន បញ្ហាអីទេ បានឪពុកខ្ញុំគាត់ផ្សំថ្នាំខ្មែរទុកឲ្យផឹក។ ដូចថាទម្លាក់ឈាមក្នុងខ្លួនឲ្យអស់ កុំឲ្យវាកកដុំអ៊ីចឹង គាត់ដាំថ្នាំឲ្យផឹក។ បើសិនជារឿងថ្នាំពេទ្យ ឬក៏មានអ្នកជំនាញខាងបង្កើតហ្នឹង គ្មានសោះហើយ សង្គម ហ្នឹងគឺគ្មានតែម្តង កើតទៅតាមយថាកម្មទេ។

**ស៖** តើអ្នកស្រីមានការភ័យខ្លាចយ៉ាងណាដែរ នៅពេលដែលមានគភ៌ ហើយរហូតដល់មាន សម្រាលបុត្រហ្នឹង គឺមានការភ័យខ្លាចក្នុងបន្ទុករបស់ខ្លួនដែរអត់ទេ?

**ឆ៖** ចាស បើនៅសម័យនេះ -- សម័យនុ៎ងដែលខ្ញុំរស់នៅ ខ្ញុំគ្មានភាពកក់ក្តៅទេ ខ្ញុំមានតែភាព តក់ស្លុត ភ័យខ្លាច។ ពេលយប់ដេកបន់ឲ្យតែភ្លឺ ពេលភ្លឺបន់ឲ្យតែយប់ ព្រោះត្បិតអីវាមានតែការកាប់ សម្លាប់ គឺថាវិលៗឃើញ វិលៗឮ ការសម្លាប់ហ្នឹងជារៀងរាល់ថ្ងៃ។ ដល់អ៊ីចឹងគឺការភ័យតក់ស្លុតរបស់ ខ្ញុំនៅជាប់ៗក្នុងអារម្មណ៍ អត់មានស្រាកស្រាន្តទេ។ ព្រោះត្បិតអី គេនិយាយពីនិន្នាការផង ដល់អ៊ីចឹងប្តីខ្ញុំ ក៏បាត់ ដល់ខ្លួនឯងហ្នឹងត្រូវជាប់និន្នាការប្តីទៀត។ អ៊ីចឹងខ្ញុំហ្នឹងត្រូវទុក្ខសោកជាមួយកូនរហូត រហូតទល់

តែដល់សព្វថ្ងៃ បើនិយាយរួមទៅ ខ្ញុំនឹកឃើញឡើង ខ្ញុំឆ្អែតទល់សព្វថ្ងៃរឿងទុក្ខសោករបស់ខ្ញុំ។

[១៥:២៣:០៥]

**ស៖** ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិច ថាតើនៅពេលដែលអ្នកស្រីបានរៀបការហ្នឹង ថាតើនៅក្នុងរយៈពេលហ្នឹងមានគេរៀបការដែរអត់ទេ ឬមួយមានតែមួយក្រុមអ្នកស្រីហ្នឹងទេ?

**ឆ៖** កាលសម័យនុ៎ង គេការមានមួយវគ្គៗដែរ ការមុនខ្ញុំហ្នឹងបីវគ្គអ៊ីចឹងទៅ ការក្រោយខ្ញុំហ្នឹងមួយវគ្គទៅ ប៉ុន្តែខ្ញុំគ្រាន់តែមិនដឹងថា កាលហ្នឹងខ្ញុំអត់ដឹងថ្ងៃខែឆ្នាំអីទេ គ្រាន់ដឹងថារំលងមួយខែពីរខែបីខែអ៊ីចឹងទៅ តាមពេលវេលាគេអ៊ីចឹងទៅ គេរៀបមួយសាទៅ។ គេជ្រើសរើសអ្នកដែលចាស់ៗជាងគេនៅក្នុងកងហ្នឹងយកមករៀបមួយសាៗអ៊ីចឹងទៅ។ អ៊ីចឹងការរៀបហ្នឹង ខ្ញុំមិនដឹងថាចំនួនសរុបគេហ្នឹង ស្ថិតិគេហ្នឹង ខ្ញុំអត់ដឹងទេ ប៉ុន្តែដឹងថាបើការខ្ញុំ ៗដឹងតែ១៥គូ។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរប៉ុណ្ណេះ សូមផ្ទេរជូនលោក ពេជ អង្គ។ អរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីសួរសំណួរបន្ថែមទៅលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** មានសំណួរមួយចំនួន លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំជាមេធាវី ពេជ អង្គ។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរទៅលោកស្រី។ លោកស្រីអាចបញ្ជាក់បានទេ នៅពេលដែលលោកស្រីសម្រេចចិត្តថា រៀបការនោះ ថាតើលោកស្រីមានការភ័យខ្លាចអីដែរឬទេ ដែលលោកស្រីសម្រេចចិត្តថាទទួលរៀបការហ្នឹង? ហើយបើភ័យខ្លាច លោកស្រីមានហេតុផលអ្វីទេ?

[១៥:២៥:១៤]

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ឲ្យខ្ញុំឆ្លើយនូវសំណួរនេះ កាលហ្នឹង កាលដែលរៀបការហ្នឹង គេអត់បានប្រាប់ថាយើងការនឹងអ្នកនេះអ្នកនោះទេ គេហៅទៅ។ ដល់អ៊ីចឹង អារម្មណ៍យើងហ្នឹងវាអត់មានការចង់រៀបការអីទេ ប៉ុន្តែយើងខ្លាច ខ្លាចការកាប់សម្លាប់របស់គេដែលគេគំរាមយើង បើយើងមិនគោរពតាមវិន័យអង្គការ គេនឹងសម្លាប់យើង។ អ៊ីចឹងគេហៅយើងទៅហ្នឹង យើងទៅទាំងទឹកភ្នែក ទៅទាំងគ្រោតគ្រាត

គ្មានអារម្មណ៍។ បើនិយាយពីស្លៀកពាក់វិញមិនបានសមរម្យទេ ព្រោះ--

**ស៖** ខ្ញុំសូមៗកាត់លោកស្រីបន្តិច លោកស្រីបាននិយាយថា "ទាំងខ្លាច" លោកស្រីអាចពន្យល់បានទេ ហេតុអ្វីបានជាលោកស្រីខ្លាច?

**ឆ៖** ចាស ការខ្លាចហ្នឹងគឺក្នុងនុំងគេដាក់គំនាប គឺមានតែសម្លាប់ចោល និងដាក់គុក។ គេៗមិនមែនពាក្យថាគុកទេ គេបញ្ជូនទៅមន្ទីរសុប។ ដល់អ៊ីចឹងខ្ញុំមានអារម្មណ៍ខ្លាចហ្នឹង ខ្លាចដោយសារសេចក្តីស្លាប់មួយ ខ្លាចដោយសារតែឲ្យ គេឲ្យទៅដេកនៅក្នុងមន្ទីរសុប គេបង្អត់បាយ ធ្វើការ ហើយគេបិទសេរីភាពសុទ្ធសាធ មិនឲ្យយើងទៅណា គេដាក់គុកដាក់ខ្នោះ។ ដល់អ៊ីចឹងអារម្មណ៍ខ្ញុំខ្លាច។ ត្រង់ហ្នឹងហើយដែលខ្ញុំសុខចិត្តតស៊ូ ដើម្បីរស់នៅជាមួយប្តីដែលមិនបានរួមរស់ដោយរួមរក្សហ្នឹង បានរយៈខែ រយៈពេលដល់៤ខែហ្នឹង ដោយសារខ្ញុំខ្លាច ខ្ញុំចេះតែតស៊ូរស់នៅទៅ។

[១៥:២៧:០២]

**ស៖** តើលោកស្រីមានឃើញករណីជាក់ស្តែងណាមួយ ឬក៏គូណាមួយ ឬក៏នរណាគេម្នាក់បានបដិសេធមិនព្រមរៀបការ ហើយមានបញ្ហាអ្វីជាមួយគាត់ដែរឬទេ លោកស្រីអាចនៅចងចាំទេ?

**ឆ៖** ចាស ខ្ញុំកាលហ្នឹងបានដឹង ដឹងថា មានអ្នករៀបការហ្នឹងគាត់មិនបានចុះសម្រុង ព្រោះគាត់មានគូដណ្តឹងនៅស្រុកនៅអ៊ីចឹង។ ដល់អ៊ីចឹងគាត់អត់ព្រមទទួលស្គាល់បុរសដែលគាត់រៀបការជាមួយ។ ដល់ទៅថ្ងៃក្រោយមក ក៏គាត់បាត់ខ្លួនពីសហជីពទៅ។

**ស៖** លោកស្រីនៅចាំឈ្មោះរបស់គាត់ដែរឬទេ ម្នាក់ដែលបដិសេធមិនព្រមរៀបការ ហើយបាត់ខ្លួនដែលលោកស្រីមានប្រសាសន៍អម្បាញ់មិញ?

**ឆ៖** ចាស គាត់ៗហ្នឹងឈ្មោះ មិត្តព្រឿង។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមទៅលោកស្រីថែមទៀត។ លោកស្រីអម្បាញ់មិញបានឆ្លើយទៅនឹងលោកមេធាវី ឡោ ជុនធី រួចហើយអំពីការដែលថាពេលដែលលោកស្រីបានទៅនៅខាងប្តី គេ ប្តីរំលោភ ហើយបាននិយាយថាគឺគេគាត់ធ្វើតាមទិសដៅរបស់អង្គការទេ។ ចុះពេលក្រោយៗមកទៀត ពីពេលដែលគាត់ចាប់ផ្តើមរំលោភលើកដំបូងនោះ ថាតើគាត់មានធ្វើអំពើបែបនេះទៅលើលោកស្រីថែមទៀតដែរឬទេ? មានន័យថា គាត់មានរំលោភលោកស្រីដែរឬទេ នៅពេលក្រោយៗមកទៀត?

**លោក គង់ សំអុន៖**

លោកប្រធាន!

[១៥:២៩:០២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! អញ្ជើញ! អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមខ្ញុំស្ដាប់បានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គាត់ឆ្លើយថា គាត់មិនបានដឹងច្បាស់ថា វាជាទិសដៅរបស់អង្គការ ឬយ៉ាងណានោះទេ។ ដូច្នេះការសង្ខេបថា វាជាទិសដៅរបស់អង្គការនេះ វាជាការធ្វើឱ្យមានការភ័ន្តច្រឡំអង្គហេតុ។ បាទ សូមអរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ តាមដែលខ្ញុំក្ដាប់បាន ហើយដូចដែលលោកស្រីបានឆ្លើយនៅក្នុងចម្លើយទី៤៣ របស់លោកស្រីនៅក្នុងឯកសារ E3/9820 ក៏ដូចជាលោកស្រីបានឆ្លើយនៅទីនេះ លោកស្រីថាបាន ប្ដីរបស់គាត់បាននិយាយថា តាមទិសដៅរបស់អង្គការ។ ក៏ប៉ុន្តែអ្វីដែលលោកស្រីបានបញ្ជាក់ថាគាត់មិនច្បាស់លាស់គឺថា គាត់មិនដឹងថាមានគេណែនាំប្ដីគាត់ឱ្យនិយាយ ឱ្យអំពីពាក្យនេះ ឬក៏អត់ គាត់មិនច្បាស់ពីការណែនាំ។ តែពាក្យពេចន៍នេះ គឺប្ដីរបស់គាត់បាននិយាយចំពោះរូបគាត់។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីអំពីពាក្យពេចន៍នេះតែម្ដងទៅ ដើម្បីឱ្យមានភាពច្បាស់លាស់។

[១៥:៣០:១៨]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលប្ដីរបស់លោកស្រីធ្វើសកម្មភាពរំលោភទៅលើរូបលោកស្រី តើប្ដីរបស់លោកស្រីបានពន្យល់អំពីអ្វីទៅដល់លោកស្រីដែរឬទេ? ថាតើគាត់មានបាននិយាយពាក្យដែលខ្ញុំបានលើកអម្បាញ់មិញដែរឬទេ?

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស កាលដែលគាត់រំលោភហ្នឹង ពីដំបូងហ្នឹងគាត់ ដូចថា ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង ពេលខ្ញុំដេកលក់មួយរឹងទៅ គាត់ដាក់ដៃឱបខ្ញុំ ដល់ពេលខ្ញុំបេះរើអ៊ីចេះ គាត់រឹត។ ដល់ពេលរឹតទៅ ខ្ញុំយំ

ស្រែក ខ្ញុំថា កុំធ្វើអ៊ីចឹងខ្ញុំអត់ឲ្យធ្វើអ៊ីចឹងទេ។ គាត់ថា បើមិនឲ្យគាត់ធ្វើអ៊ីចឹង គាត់ម៉េចនឹងបានទៅតាមទិសដៅរបស់បក្សដែលអង្គការដែលប្រាប់គាត់ឲ្យគាត់ធ្វើ។ អ៊ីចឹងបើគាត់មិនធ្វើ គាត់ត្រូវស្លាប់ទាំងអស់គ្នា។ អ៊ីចឹងគាត់បង្ខំ គាត់ធ្វើបាបខ្ញុំ ទោះបីជាខ្ញុំយំ ខ្ញុំស្រែកគាត់ថា ឲ្យខ្ញុំស្រែកទៅអត់ចេះខ្មាសគេ ឲ្យខ្ញុំស្រែកទៅ។ គាត់ប្រាប់អ៊ីចឹងទៀត។ ដល់អ៊ីចឹងទៅ ខ្ញុំក៏ចេះតែខំរើបម្រះ ទៅតាមកម្លាំងដែលមាន។ ដល់ចុងក្រោយមក យើងស្រីវា ភេទស្រី វាខ្សោយកម្លាំង ដល់កាលណាយើងប្រឹងអស់លទ្ធភាព យើងចាញ់បុរស។ ហ្នឹងដោយសារការរំលោភបំពានហ្នឹង។ ខ្ញុំគ្រាន់ថា ការដែលគាត់មកនេះ គាត់និយាយនេះ ខ្ញុំដឹងតែតាមសម្ដីគាត់ទេ។ ខ្ញុំអត់បានដឹងថា អង្គការហ្នឹងជាអ្នកណា ដែលបានបញ្ជាគាត់ឲ្យមកធ្វើលើខ្ញុំទេ។

[១៥:៣២:០៨]

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់សួរបញ្ជាក់ថែមទៀត នៅពេលដែលមានពេលណាមួយលោកស្រីមានបានដឹងអំពី បានចូលរួមការប្រជុំ ឬក៏ឮគេនិយាយប្រាប់ ឬក៏កម្មាភិបាលណានិយាយប្រាប់លោកស្រីថា ការដែលថា លោកស្រីត្រូវរៀបការ ឬក៏ថាអ្នកផ្សេងៗទៀតត្រូវរៀបការ គឺដើម្បីគោលដៅអ្វីដែរទេ លោកស្រី?

**ឆ៖** ចាស ថ្ងៃរៀបការហ្នឹង ខ្ញុំឮខាងមេបក្សគាត់បានលើកឡើងថា អង្គការយើងត្រូវការបង្កើនកម្លាំង។ អ៊ីចឹងអង្គការយើង នឹងអនុញ្ញាតឲ្យគូស្រករដើម្បីបង្កើតកូនឲ្យបាន ពង្រីកកម្លាំងប្រជាពលរដ្ឋ។ អ៊ីចឹងត្រូវធ្វើម៉េច យើងត្រូវរៀបការ យើងត្រូវរួមរស់នៅជាមួយគ្នា ចេះស្រលាញ់គ្នា កសាង និងបង្កើតកូនឲ្យបក្ស។ ដល់អ៊ីចឹង ខ្ញុំឆ្ងល់ កាលហ្នឹងខ្ញុំអត់ដឹងថា គេបង្កើតកូនរបៀបម៉េចអីរបៀបម៉េច ខ្ញុំចេះតែយំ ខ្ញុំឆ្ងល់ ព្រោះម៉ែខ្ញុំគាត់បាននិយាយថា កូនកើតតាមកំភួនជើង ដល់អ៊ីចឹងខ្ញុំចេះតែឆ្ងល់។ ឆ្ងល់ថា ឲ្យកើតកូនម៉េច បើអញមិនដែលនេះផង បង្កើតតាមណា បើកំភួនជើងអញមិនទាន់ធំផង។ ខ្ញុំក៏ចេះតែយំទៅ។ ដល់ក្រោយមកហ្នឹង រស់នៅជាមួយគាត់ ក៏គាត់លួងលោមខ្ញុំ ក៏ខ្ញុំមិនស្ដាប់ ខ្ញុំមិនយកចិត្តទុកដាក់ ព្រោះអង្គការគេចង់បង្កើតកម្លាំង។ គាត់យកពាក្យ "អាបង្កើតកម្លាំង" ហ្នឹង គាត់និយាយប្រាប់ខ្ញុំ ឧទាហរណ៍ប្រាប់ខ្ញុំអ៊ីចឹង ហើយខ្ញុំវាអត់យល់។ ដល់អ៊ីចឹងខ្ញុំអត់ព្រមរស់នៅជាមួយគាត់ទេ។

**ស៖** បាទ លោកស្រីខ្ញុំគិតថា សហការីរបស់ខ្ញុំនិយាយថា គាត់មិនបានយល់អំពីអ្វីដែលលោកស្រីបានពន្យល់អម្បាញ់មិញទេ ជាភាសាបារាំង។ តើលោកស្រីអាចបញ្ជាក់សាជាថ្មីទេ ថាតើបង្កើតកូនដើម្បីអ្វី? គោលដៅអ្វី?

**ឆ៖** សម័យនុ៎ង អង្គការគេបានលើកឡើងថា ឲ្យយើងបង្កើតកូនជាកម្លាំង កម្លាំងបដិវត្តន៍ ឲ្យ

កើនឡើងដើម្បីកសាងប្រទេស។

[១៥:៣៤:៥១]

**ស៖** លោកស្រីអាចបញ្ជាក់បានទេ អ្នកដែលនិយាយពាក្យហ្នឹងនៅក្នុងពេលដែលលោកស្រីរៀបការនោះ គឺជាអ្នកណា? លោកស្រីអាចបញ្ជាក់ឈ្មោះ ហើយនិងតួនាទីរបស់គាត់បានដែរឬទេ?

**ឆ៖** កាលដែលគាត់និយាយពាក្យទាំងអស់ហ្នឹងគឺ មិត្តសូ ជាប្រធានសហជីពទាំងមូល ដែលគាត់បានលើកឡើងឲ្យយើងនៅក្នុងសហជីពហ្នឹង ឲ្យបានក្នុងមង្គល ពេលវារៀបការហ្នឹង ឲ្យយើងដឹងថា ដើម្បីបង្កើនកម្លាំងបដិវត្ត កសាងមហាលោតផ្លោះ មហាអស្ចារ្យនោះ ដើម្បីឲ្យមានកម្លាំងកាន់តែកើនឡើង។ ប៉ុន្តែខ្ញុំមិនដឹងថា ការបង្កើតមនុស្សហ្នឹងដើម្បីបង្កើនអី បើខ្ញុំអត់ដឹងផង ប៉ុន្តែខ្ញុំស្ដាប់ពីគាត់និយាយអ៊ីចឹង។ គាត់និយាយថា ការ – មិត្តសូ នោះគាត់លើកឡើងថា អង្គការត្រូវការបង្កើនកម្លាំងដើម្បីកសាងអភិវឌ្ឍប្រទេសជាតិ។ គាត់និយាយអ៊ីចឹង។ អ៊ីចឹងយើងរៀបការហ្នឹង ដើម្បីឲ្យកើតកូនគ្រប់ៗគ្នាមក ដើម្បីបង្កើនកម្លាំងបក្ស។ អាហ្នឹងខ្ញុំចាំតែប៉ុណ្ណឹងទេ។

**ស៖** ក្រោយពីឱកាសនោះ ថាតើលោកស្រីមានបាន នៅពេលណាមួយត្រូវបានគេនិយាយអំពីខ្លឹមសារ ឬក៏គំនិតដូចគ្នានេះ ឲ្យលោកស្រីស្ដាប់ដែរឬទេ ឬក៏លោកស្រីធ្លាប់បានឮទេ?

**ឆ៖** ការនិយាយនេះ គឺនៅពេលប្រជុំ ឬក៏ពេលអ្នកដែលរៀបការមុនៗ ដែលគេបានមកនិយាយប្រាប់ខ្ញុំថា បក្សត្រូវការកម្លាំង។ អ៊ីចឹងគេរៀបការយើង ឲ្យបង្កើតកម្លាំងហ្នឹង។ អាហ្នឹងខ្ញុំឮតែទៅតាមពេលប្រជុំ បក្សហ្នឹង ពេលប្រជុំអាការងារ គេហៅក្រុមទៅប្រជុំ ហើយនិងអ្នកដែលបានការមុនហ្នឹងគាត់និយាយថា គេត្រូវការកម្លាំង បានគេរៀបការយើង ឲ្យយើងមានកូន។

[១៥:៣៧:០៦]

**ស៖** លោកស្រីអាចបញ្ជាក់បានទេ ប្ដីរបស់លោកស្រីឈ្មោះអ្វី? ហើយគាត់ហ្នឹងយ៉ាងម៉េច រូបរាងកាយរបស់គាត់?

**ឆ៖** ប្ដីខ្ញុំឈ្មោះ មិត្តកែវ សម័យហ្នឹងគេហៅ មិត្តកែវ។ ដែលក្រោយមកដែលបានខ្ញុំឃើញច្បាស់ គាត់ជាជនពិការមួយ ដែលក្នុងសង្គ្រាម គាត់ឡើងវ៉ៃសមរភូមិ អ៊ីចឹងគាត់ត្រូវគ្រាប់។ ដៃគាត់ពិការម្រាមនេះបី ហើយភ្នែកគាត់ បើសិនជាផ្ទេចទៅ គាត់ត្រូវងងឹតមើលអត់ឃើញ។ ជើងគាត់ ភ្នែកគោរនេះជ្រុះបាត់ គាត់ខ្វេរជើងអ៊ីចេះ។ ដល់អ៊ីចឹងគាត់ជាមនុស្សពិការធ្ងន់ធ្ងរ។ គាត់ធ្វើការងារធ្ងន់មិនបាន។

**ស៖** គេមានបាននិយាយជម្រាបលោកស្រីទេ ហេតុអ្វីបានជាឲ្យលោកស្រីរៀបការជាមួយអ្នកដែលពិការយ៉ាងដូច្នេះ ពិការដោយសង្គ្រាម?

**ឆ៖** ថ្ងៃរៀបការ គេអត់បាននិយាយប្រាប់ខ្ញុំទេ ប៉ុន្តែពីមុនៗមក គេបាននិយាយ គេនិយាយតៗគ្នាថា តិចទៀត គេយកពិការមករៀបឲ្យពួកសហជីពហើយ ដឹងបានគេ បានយើងទេ។ នារីៗដូចគ្នាហ្នឹង គ្រាន់តែពួតៗគ្នាទេ មិនទាន់បានទទួលពាក្យជាក់លាក់ពីអ្នកណាដែល ឬក៏មេកង ឬក៏ពីប្រធានធំហ្នឹង និយាយទេ គ្រាន់តែចចាមអារ៉ាមទេ។ ដល់អ៊ីចឹង ខ្ញុំអត់បានទៅចាប់អារម្មណ៍ដែរ រឿងគ្រួសារហ្នឹងទេ ព្រោះត្បិតអី ខ្ញុំអត់មានចាប់អារម្មណ៍នឹងការរៀបការផង កាលសម័យនុ៎ង។

[១៥:៣៨:៥៩]

**ស៖** ចុះលោកស្រីមានធ្លាប់បានឮគេនិយាយអំពីការលើកទឹកចិត្តទៅដល់ជនពិការ ដើម្បីឲ្យគាត់មានគ្រួសារដែរឬទេ ដែលឲ្យ -- ដោយសារគាត់បានធ្វើសង្គ្រាម ហើយគេរៀបការជាមួយលោកស្រីដើម្បីលើកទឹកចិត្តឲ្យគាត់ មានធ្លាប់ឮពាក្យហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ឮដែរ ឮគេនិយាយតៗគ្នាថា គេនឹងយកជនពិការមករៀបការឲ្យ ដើម្បីលើកទឹកចិត្តដែលខំតស៊ូ ដូចថា រំដោះប្រទេសជាតិហ្នឹងបានមកគ្រប់គ្រងសព្វថ្ងៃហ្នឹង។ អ៊ីចឹងគេនឹងរៀបឲ្យនារីស្អាតៗទៅជនពិការ។ ខ្ញុំឮអ៊ីចឹងដែរ ឮនិយាយ។

**ស៖** អ្នកណាអ្នកនិយាយ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចាស អង្គាល់នុ៎ងអត់ទាន់មានប្រធានកងអីនិយាយទេ មានតែនារីៗគ្នាឯងហ្នឹងនិយាយតៗគ្នា ចចាមអារ៉ាមថា មានគេនិយាយថា តិចទៀតគេនឹងយកជនពិការមករៀបឲ្យកម្មករសហជីពដែលនារីស្អាតៗហ្នឹង គេរៀបឲ្យជនពិការហើយ។ រួចខ្ញុំមិនបានចាប់អារម្មណ៍ទេ ព្រោះត្បិតអីខ្ញុំគិតតែពីការងារដែលគេប្រើឲ្យទាំងយប់ទាំងថ្ងៃ ខ្ញុំគ្មានចាប់អារម្មណ៍រឿងគេរៀបចំអីឲ្យទេ។ ហើយក៏មិននឹកស្មានថាខ្ញុំបានជួបប្តីពិការដែរ ព្រោះត្បិតអីខ្ញុំអត់ដឹង។

**ស៖** ខ្ញុំត្រឡប់មកសំណួរខ្ញុំមុនដែលខ្ញុំបានសួរលោកស្រី អំពីការដែលថា លោកស្រីរួមដំណេកជាមួយប្តីលើកបន្តបន្ទាប់។ ថាតើលោកស្រីធ្វើដោយស្ម័គ្រចិត្តដែរឬទេ បន្ទាប់ពីលើកទី១ ដែលលោកស្រីរួមដំណេកជាមួយប្តីហ្នឹង លោកស្រីស្ម័គ្រចិត្តដែរឬទេ? ហើយហេតុអ្វី? ក្រោយពីរំលោភហើយ។

**ឆ៖** ចាស ក្រោយពីរំលោភហើយ គាត់ចេះតែលួងលោមខ្ញុំថា វាអស់សេចក្តីបរិសុទ្ធអីណាគាត់ចេះនិយាយ គាត់ចេះនិយាយច្រើន គាត់ថាទោះបីយ៉ាងណា ក៏វាគ្មានសេចក្តីបរិសុទ្ធទៅឲ្យឪម៉ែយើង

វិញដែរ គាត់ចេះនិយាយលួងលោមខ្ញុំអីចឹង។ គាត់ចេះតែប្រាប់ គាត់ចេះតែលួងលោមទៅ ៗបានខ្ញុំនឹកថា ខ្ញុំខកចិត្ត ហួសពេលខ្ញុំហ្នឹងទៅ ក៏ខ្ញុំបណ្ដោយទៅតាមយថាកម្មខ្ញុំទៅ។

[១៥:៤១:៤៧]

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់សួរបន្ថែមទៀត អម្បាញ់មិញលោកស្រីបាននិយាយអំពីការអស់ភាពបរិសុទ្ធ។ តើលោកស្រីមានបញ្ហាអ្វីទេនៅពេលដែលលោកស្រីអស់ភាពបរិសុទ្ធហ្នឹងទៅ? ថាតើលោកស្រីមានអារម្មណ៍យល់ គិតយ៉ាងម៉េចដែរ? មានការសោកស្ដាយអីយ៉ាងម៉េចដែរចំពោះបញ្ហានេះ?

**ឆ៖** ខ្ញុំបើនិយាយសេចក្ដីបរិសុទ្ធខ្ញុំកាលពីក្មេងហ្នឹង ខ្ញុំស្ដាយៗសេចក្ដីបរិសុទ្ធខ្ញុំទល់សព្វថ្ងៃ ព្រោះខ្ញុំក្មេងស្រីមួយដែលគោរពទៅតាមប្រពៃណី គោរពឪពុកម្ដាយ ពាក្យចាស់លោកថា "បើមុននឹងប្រគល់ខ្លួនឲ្យទៅបុរសណាម្នាក់ ទាល់តែឪពុកម្ដាយអង្គុយក្បាលកន្ទេល"។ ដល់ពេលនោះ ខ្ញុំអត់មានឪពុកម្ដាយអង្គុយក្បាលកន្ទេលផង ខ្ញុំត្រូវអស់ក្ដីបរិសុទ្ធរបស់ខ្លួនខ្ញុំ។ ដល់អីចឹងខ្ញុំសោកស្ដាយបំផុតទាល់សព្វថ្ងៃហ្នឹង ខ្ញុំនៅតែនឹកសោកស្ដាយថា មិនគួរណាអស់សេចក្ដីបរិសុទ្ធមុនឪពុកម្ដាយអង្គុយក្បាលកន្ទេល កាលសម័យនុ៎ងគាត់ចង់បានយើងអង្គុយក្បាលកន្ទេល រៀបចំទៅតាមប្រពៃណីត្រឹមត្រូវ មានភ្លេងភ្លាត់ មានអាចារ្យ មានភ្ញៀវកុះករ។ ដល់ពេលខ្ញុំ គេរៀបការឲ្យហ្នឹងមានតែអ្នកការ ហើយនិងប្រធានកង អត់មានភ្ញៀវផង។

**ស៖** ខ្ញុំចង់សួរបន្ថែមទៅលើគូផ្សេងៗដែលលោកស្រីមានប្រសាសន៍ហ្នឹងគឺ លោកស្រីថាមានបីវគ្គនៃការរៀបការមុនលោកស្រី។ អីចឹងលោកស្រីវគ្គទី៤ ហើយមានមួយវគ្គទៀតដែលរៀបការក្រោយលោកស្រី។ នេះដែលតាមដែលលោកស្រីដឹង។ លោកស្រីអាចបញ្ជាក់បានទេ វគ្គទី១ មានប៉ុន្មានគូ? វគ្គទី២ ប៉ុន្មានគូ? វគ្គទី៣ ប៉ុន្មានគូ? វគ្គទី៤ដែលជាវគ្គរបស់លោកស្រីមានប៉ុន្មានគូ? ហើយវគ្គទី៥ ដែលលោកស្រីបានដឹងហ្នឹង ឬក៏បានឮហ្នឹងមានប៉ុន្មានគូ? ហើយការរៀបការហ្នឹងនៅកន្លែងណា?

[១៥:៤៤:០១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** កាលដំបូង ដែលខ្ញុំបានដឹងរៀបដំបូងហ្នឹង ៥០គូហ្នឹង គេឲ្យខ្ញុំបានទៅឈរមើល។ ឈរ

មើលគេរៀបការ គ្រាន់តែទៅឈរមើលគេអង្គុយទេ មិនបានស្តាប់គេនិយាយទេ ព្រោះគេអត់ឲ្យយើងចូលរួម។ គ្រាន់តែពេលគេទៅអង្គុយៗអ៊ីចឹងទៅ គេឲ្យយើងចេញមកវិញ ហ្នឹងដំបូង។ ដល់ក្រោយមកទៀត គ្រាន់តែឮជាព័ត៌មាន ខ្ញុំមិនបានទៅ ព្រោះគេអត់ឲ្យយើងទៅជិត។ ដល់ក្រោយមកទៀត ឮព័ត៌មានរៀបទៀត គឺគេថារៀបអ៊ីចឹង ៤០គូ ៥០គូ អ៊ីចឹងមកទៀត។ ដល់ទៅខ្ញុំអត់បានទៅមើលទេ ដល់មកខ្ញុំផ្ទាល់ហ្នឹង ថ្ងៃខ្ញុំការហ្នឹង បានខ្ញុំដឹងខ្លួនឯងថា គេការអ៊ីចឹង។ ដល់មកក្រោយទៀត ១២គូហ្នឹងក៏ខ្ញុំអត់បានទៅដែរ គ្រាន់តែគេ ៗថាថ្ងៃហ្នឹងគេរៀបការទៀតហើយ គ្រាន់តែគេប្រាប់អ៊ីចឹង ប៉ុន្តែការសាហ្នឹងការតែចាស់ៗទេ ចាស់ៗដែលគាត់ពោះម៉ាយ មេម៉ាយ ហើយនិងនារីខ្លះ ទៅគេថា១២គូ។ ហ្នឹងខ្ញុំគ្រាន់តែឮជាព័ត៌មានអ៊ីចឹងទេ ព្រោះគេពេលការហ្នឹងគេមិនបានឲ្យយើងទៅមើល ហើយនិងទៅអង្គុយស្តាប់ទេ។

[១៥:៤៥:១៨]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ នៅក្នុងឯកសាររបស់លោកស្រី ពេលខ្លះលោកស្រីនិយាយថាលោកស្រីត្រូវបានគេឲ្យរៀបការ នៅក្នុងនោះមាន១២គូ។ ហើយអម្បាញ់មិញលោកស្រីក៏បញ្ជាក់ថា លោកស្រីបានរៀបការពេលដែលលោកស្រីរៀបការមាន១៥គូ នៅក្នុងឯកសារ E3/9820 សំណួរចម្លើយទី២៥។ អ៊ីចឹងលោកស្រីអាចបញ្ជាក់ឲ្យច្បាស់បានទេ ពេលដែលលោកស្រីការហ្នឹងគឺប៉ុន្មានគូឲ្យបានច្បាស់លាស់? ហើយបាទៗសូមអញ្ជើញបញ្ជាក់!

**ឆ៖** ខ្ញុំថ្ងៃដែលរៀបខ្ញុំ១៥គូ។ ១៥គូហ្នឹង ខ្ញុំក៏មិនបានដឹងថាគេរាប់គូណាៗ ខ្ញុំគូទីប៉ុន្មានអីខ្ញុំអត់បានរាប់ទេ ព្រោះកាលហ្នឹងវាអារម្មណ៍ភិតភ័យនឹងការគេយកទៅផ្គូផ្គងហ្នឹង ប៉ុន្តែគ្រាន់តែគេនិយាយថាការវគ្គហ្នឹង១៥គូ។ ចាស ខ្ញុំអត់បានរាប់ទេ។ ប៉ុន្តែកាលខ្ញុំដែលនិយាយនៅក្នុងចម្លើយហ្នឹង ខ្ញុំនិយាយថាការខ្ញុំហ្នឹងរួច មានគេការ១២គូក្រោយខ្ញុំទៀត អាហ្នឹងខ្ញុំបាននិយាយពាក្យហ្នឹងជាប់គ្នា។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបានពិភាក្សាជាមួយនឹងតំណាងសហព្រះរាជអាជ្ញាទេ ក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ចែកពេលវេលាគ្នាយ៉ាងម៉េចទៅ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខាងតំណាងសហព្រះរាជអាជ្ញាថាឲ្យខាងដើមបណ្តឹងរដ្ឋប្ប-

វេណីអាចយកពេលវេលាតាមដែលអាចមួយអស់សំណួរដែលតែម្តង។ អ៊ីចឹងទុកពេលខ្លះជូនគាត់ តែខ្ញុំមិននៅសល់សំណួរច្រើនទេ លោកប្រធាន។

[១៥:៤៧:០១]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ខ្ញុំចង់សួរបន្ថែមទៀត នៅពេលដែលប្តីលោកស្រីត្រូវបានគេយកទៅសម្លាប់ ហើយតើមាននរណាគេចង់ធ្វើអ្វីទៅលើកូនរបស់ស្រីដែលកើតមកដែរឬទេ?

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ក្រោយៗពីគេចាប់ប្តីខ្ញុំទៅ បានប្រហែលជា១០ថ្ងៃ លើសក៏មិនដឹង កាលហ្នឹងខ្ញុំវាមិនបានចាំ បានខ្ញុំឆ្លងទន្លេ។ ដល់ខ្ញុំឆ្លងទន្លេ កូនខ្ញុំហ្នឹងប្រហែលជាបានជិតមួយខែមើលទៅ ព្រោះកាលហ្នឹងគេមិនទាន់ហៅទៅធ្វើការទេ នៅផ្ទះនៅឡើយ។ ដល់ទៅ មិត្តយ៉េន ហ្នឹងគាត់ឡើងទៅ គាត់ទៅពិនិត្យលើផ្ទះខ្ញុំ ក្រែងលួចលាក់ ដូចថាយើងដាំរបស់ជុំវិញផ្ទះ មានល្ពៅ មានដំឡូង មានគ្រប់អ៊ីចឹងទៅ ក្រែងយើងលួចបេះយកមកទុកហូបអ៊ីចឹង គាត់ទៅពិនិត្យ។ ដល់ពេលពិនិត្យលើផ្ទះខ្ញុំគ្មានឃើញអី ក៏គាត់មកអើតមើលកូនខ្ញុំ ក៏គាត់ពោលពាក្យមកថា "កូនអាក្បត់ គួរតែឲ្យគេកម្ទេចចោលទៅ ទុកធ្វើអី។ មិត្តឯងទុកធ្វើអី"។ ចាស មិត្តយ៉េន គាត់និយាយមកម៉ាត់ៗដាក់ខ្ញុំអ៊ីចឹង។ ខ្ញុំថា "បងយ៉េន អ្ហា! កូនខ្ញុំនេះ វានៅក្នុង បើនិយាយទៅនៅនាមជាទារកមានតែភ្នែកខ្មៅក្រឹបទេ មិនទាន់ចេះអីពីគោលនយោបាយរបស់បក្សទេ។ រឿងអីចង់សម្លាប់កូនខ្ញុំ បើសម្លាប់កូន ខ្ញុំសម្លាប់ខ្ញុំទៅ"។ ខ្ញុំនិយាយទាំងយំប្រាប់គាត់អ៊ីចឹង។ បើខ្ញុំស្លាប់ទៅ វាកូនខ្ញុំក៏ស្លាប់ទៅជាមួយដែរ កុំឲ្យខ្ញុំរស់នៅនាំតែវេទនា។ ទៅក៏គាត់និយាយបានប៉ុន្មានម៉ាត់ប្រាប់ខ្ញុំខ្ញុំយំផងអីផងអ៊ីចឹងទៅ ក៏គាត់ចុះចេញទៅ មិត្តយ៉េន ហ្នឹងនោះ។

[១៥:៤៩:០៥]

**ស៖** ពេលនោះលោកស្រីមានការភ័យខ្លាចទេ ដែលគេនិយាយយ៉ាងដូច្នេះជាមួយលោកស្រី?

**ឆ៖** ចាស ក្រោយពីគេនិយាយពាក្យហ្នឹងមកលើខ្ញុំមក ធ្វើឲ្យអារម្មណ៍ខ្ញុំហ្នឹងតក់ស្លុត ភ័យខ្លាចចេះតែយំក្អុកក្អួល ណែនទ្រូង ចង់ស្ទះ ចង់សន្លប់អ៊ីចឹងទៅ ព្រោះកាលហ្នឹងខ្ញុំនៅសរសៃខ្ចី។ ទៅឪខ្ញុំហ្នឹងគាត់មក គាត់ចេះថា តាំងចិត្តទៅកូន កុំភ័យអី រឿងស្លាប់ជៀសមិនផុតទេ។ គាត់ចេះតែនិយាយលួងលោមខ្ញុំអ៊ីចឹង។ ហើយខ្ញុំចេះតែយំទៅ។

**ស៖** នៅពេលដែលលោកស្រីការ គេបាននិយាយថា ការដើម្បីបង្កើតកូនសម្រាប់បម្រើអង្គការ

ពង្រីកចំនួនប្រជាជន ហើយពេលនេះគេ ពេលអម្បាញ់មិញដែលលោកស្រីថា គេប្រុងយកកូន យកទៅសម្លាប់ដោយសារជាកូនរបស់ខ្មាំង។ នៅពេលដែលគេនិយាយរបៀបអ៊ីចឹង លោកស្រីអាចយល់យ៉ាងណាដែរ ដែលគេនិយាយអំពីរឿងពាក់ព័ន្ធនឹងនយោបាយថា បង្កើតកូនដើម្បីអង្គការហ្នឹង ហើយប្រុងយកកូនទៅសម្លាប់ហ្នឹង វាយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គិសសេ!

[១៥:៥០:៤៣]

**កញ្ញា អង់តា ហ្គិសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគួរតែក្រោកឡើងមុននេះបន្តិច ពីព្រោះថា ខ្ញុំឮពីរបីដងហើយ ឮលោកមេធាវីគាត់និយាយលើកឡើងហ្នឹង ហើយមិនមែនជាសម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះទេ។ ហើយប្រហែលជាខ្ញុំស្តាប់ការបកប្រែវាបាត់ខ្លះក៏មិនដឹង ក៏ប៉ុន្តែឮនិយាយថា គេ<ចង់>សម្លាប់កូនគាត់ដោយសារកូនហ្នឹងជាកូនរបស់ខ្មាំង។ ក៏ប៉ុន្តែខ្ញុំមិនឮដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បាននិយាយយ៉ាងដូច្នេះទេ គឺជាពាក្យពេចន៍របស់លោកមេធាវីដែលបាននិយាយដោយខ្លួនឯង។ <អ៊ីចឹង ខ្ញុំសូមជំទាស់។>

**លោក ពេជ អង្គ៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីគាត់បាននិយាយយ៉ាងដូច្នេះ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** អ៊ីចឹងលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចបញ្ជាក់បានទេ នៅពេលដែលគេមកនិយាយអំពីបញ្ហាកូនរបស់លោកស្រីហ្នឹង គេនិយាយថា យ៉ាងដូចម្តេច?

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀតថា កាលដែលកូនខ្ញុំកើតមកហ្នឹង ឈ្មោះមិត្តយ៉េន ហ្នឹងគាត់បានឡើងទៅ ថាកូនហ្នឹងក្បត់ ឪវាក្បត់ កូនអាក្បត់។ គាត់បាននិយាយអ៊ីចឹងមែន។ ខ្ញុំក៏បានតម៉ាត់ថា កូនខ្ញុំអត់ចេះនិយាយ មានតែភ្នែកខ្មៅក្រឹប មិនចេះនិយាយពីគោលនយោបាយបក្សអីទេ។ ខ្ញុំបានឆ្លើយកាត់ទាំងទឹកភ្នែកអ៊ីចឹង។

**ស៖** បាទ ខ្ញុំរំលងទៅសំណួរចុងក្រោយរបស់ខ្ញុំ។ លោកស្រី ៗរៀបការនៅក្នុងសម័យខ្មែរ

ក្រហម ប្ដីបានស្លាប់ ថាតើពេលក្រោយៗមកទៀត មានអ្នកណាគេរើសអើងលោកស្រី ដោយសារថាលោកស្រីបានរៀបការនៅក្នុងសម័យខ្មែរក្រហមហ្នឹង ហើយស្លាប់ប្ដីហ្នឹងដែរឬទេ?

[១៥:៥២:៥៣]

**ឆ៖** ក្រោយពេលគេចាប់ប្ដីសម្លាប់ទៅ គេដាក់ជាប់និន្នាការ ថាខ្ញុំហ្នឹងជាប្រពន្ធអាក្បត់។ អ៊ីចឹងគេតាមដាន គេគំរាមកំហែង គេសម្លុតគ្រប់ពេលវេលា ថាខ្ញុំរស់នៅគ្មានសេចក្ដីសុខ។ ជួនកាលនៅស្ងៀមៗគេថា គេថាមនុស្សដែលក្បត់នឹងអង្គការ គេមិនអាចទុកតទៅទៀតបានទេ។ គេនិយាយពាក្យចចាមអារ៉ាមដាក់ ដូចជាផ្ដែផ្ដាដាក់ខ្ញុំនៅក្នុងប្រធានសហករណ៍ហ្នឹង ប្រធានកងអីហ្នឹងគាត់ចេះតែនិយាយផ្ដែផ្ដាដាក់ឲ្យខ្ញុំអ៊ីចឹង។ ហើយខ្ញុំចេះតែតូចចិត្តខ្លួនឯង តែមិនហ៊ាននិយាយ ចេះតែទ្រាំ អត់ចិត្តមិនត ខ្លាចក្រែងស្លាប់មែន ព្រោះកាលហ្នឹងវាការសម្លាប់ហ្នឹងក្ដៅគគុក ក្ដៅគគុកតែម្ដង។ ទោះអ្នកគ្មានកំហុសក៏គេត្រូវសម្លាប់ ឲ្យតែគេត្រូវការសម្លាប់ គេយកសម្លាប់។ ដល់អ៊ីចឹងខ្ញុំនេះ បារម្ភ ខ្លាចស្លាប់ខ្លាចស្លាប់ចោលកូន កូននៅតូចៗ អ៊ីចឹងគេចេះតែរិះគន់ឲ្យខ្ញុំ ថាខ្ញុំហ្នឹងខ្សែអាក្បត់ ប្ដីក្បត់ បងក្បត់ គេដាក់ថាក្បត់ទាំងអស់ ដែលគេយកទៅសម្លាប់ គេដាក់ពាក្យ “ក្បត់” ទាំងអស់។

**លោក ពេជ អង្គ៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអនុញ្ញាតលោកប្រធានប្រគល់វេទិកាជូនទៅខាងសហព្រះរាជអាជ្ញា។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ សូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១៥:៥៤:៤៥]

**លោក វ៉ាំងសង់ វ៉ាយឌ័ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំនៅសល់តែ៥នាទីទេ ហើយនៅថ្ងៃចន្ទ ខ្ញុំនឹងប្រើពេល<២៥> ទៅ<៣០>នាទីទៀត។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ័ ដេស្សាឯល៖**

**ស៖** មុននឹងបិទសវនាការនេះ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូច។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីរយៈពេលក្រោយពេលដែលលោកស្រីសម្រាលកូន។ តើក្រោយពេលសម្រាលកូនហើយនោះ គេឲ្យលោកស្រី<ត្រូវតែ>ធ្វើការទេ? ហើយបើធ្វើមែននោះ តើសម្រាលកូនហើយបានប៉ុន្មានថ្ងៃ ដែលគេឲ្យលោកស្រីទៅធ្វើការវិញនោះ?

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ក្រោយសម្រាលកូនបាន២ខែ គេឲ្យទៅកាប់ស្លឹកត្នោត ទូលបាច់ គេចងបាច់ឲ្យស្រេច ប៉ុនៗណេះ។ ឲ្យទូលយកមកដេរ ប្រក់រោងបាយ។ អ៊ីចឹងខ្ញុំទៅធ្វើទាំងសរសៃខ្ចី ធ្វើរហូតដល់ខ្ញុំទាស់ ដើរលែងរួច។

**ស៖** បាទ ខ្ញុំយល់ អ៊ីចឹងការងារហ្នឹងគឺជាការងារធ្ងន់ធ្ងរគួរសមដែរ មែនទេ នៅពេលដែល<គេ>ឲ្យលោកស្រីធ្វើនោះ?

[១៥:៥៦:១២]

**ឆ៖** ការងារហ្នឹង មិនមែនគួរសមទេ ធ្ងន់បំផុតសម្រាប់មនុស្សស្ត្រីដែលសរសៃខ្ចី ព្រោះកាលណាលើកពីរនាក់ វាធ្ងន់ហើយ បើនិយាយរួមទៅ សម្រាប់តែបុរសទេ ប៉ុន្តែពេលហ្នឹងគេប្រើយើងអត់គិតពីបុរស ឬស្ត្រីទេ។ គេគិតតែធ្វើម៉េចឲ្យយើងធ្វើ ស្លាប់ក៏គេមិនស្តាយដែរ។ ខ្ញុំប្រឹងលើកពីរនាក់ យាយយន់។ យាយ យន់ ហ្នឹង គឺគាត់នៅជាមួយខ្ញុំហ្នឹង គាត់ចាស់។ រួចគេប្រើចាស់ និងក្មេង ហើយគាត់ចាស់ ខ្ញុំក្មេង ប៉ុន្តែខ្ញុំសរសៃខ្ចី។ ឲ្យទៅទូល ក្នុងស្លឹកត្នោតមួយដើមហ្នឹង ទូលពីរនាក់គាត់ មានតែបីជើងឯណោះ បានអស់។ រួចចងបាច់ឲ្យធំៗ លើកឲ្យណែនផ្អឹះ។ អ៊ីចឹងការងារនេះ គឺធ្ងន់ធ្ងរបំផុតសម្រាប់រូបខ្ញុំ។

**ស៖** តើលោកស្រីមានទឹកដោះដើម្បីបំបៅកូនទេ ទោះបីជាលោកស្រីធ្វើការធ្ងន់ ហើយនិងមិនសូវបានសម្រាកក៏ដោយនោះ លោកស្រីមានទឹកដោះគ្រប់គ្រាន់ដើម្បីបំបៅកូនទេ?

**ឆ៖** ក្រោយពីធ្វើការងារ ខ្ញុំមានជំងឺទាស់សរសៃទៅ ធ្វើឲ្យខ្ញុំអត់មានទឹកដោះឲ្យកូនបៅទេ។ ដល់អ៊ីចឹងកូនខ្ញុំហ្នឹង វាធ្លាក់ខ្លួនទៅជាស្គមរីងរៃ ដូចគេបង្អត់បាយអ៊ីចឹង។ ទៅសុំទឹកបបរគេបញ្ចុកកូន។ អ៊ីចឹងធ្វើឲ្យកូនខ្ញុំស្គមស្លេកស្លាំង។ នាងខ្ញុំឆ្អែតហើយ ខ្ញុំនិយាយអត់ចង់ចេញទេ ខ្ញុំនិយាយពីរឿងកូនខ្ញុំឆ្អែត។

**ស៖** មុនខែមករា ឆ្នាំ១៩៧៩ ពេលដែលលោកស្រីត្រឡប់មកធ្វើការវិញហ្នឹង លោកស្រីអាចមកមើលកូនបានទេ ឬក៏គេបំបែកមិនឲ្យលោកស្រីមកជួបកូនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១៥:៥៨:២៩]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោកស្រី ព្រាប សុឃឿន៖**

**ឆ៖** ចាស ក្នុងឆ្នាំ១៩៧៩ហ្នឹង ថ្ងៃ០១ មករា ហ្នឹងគឺជាថ្ងៃរំដោះ។ រំដោះបានពីក្នុងរបបហ្នឹង អ៊ីចឹងខ្ញុំរស់ជុំកូន ជុំម៉ែ ជុំប្អូន។ អ៊ីចឹងខ្ញុំបាន គឺថាកាលហ្នឹងយើងវាមិនទាន់មានហូបគ្រប់គ្រាន់ទេ ប៉ុន្តែបានហូបឆ្អែត ដោយយើងរកខ្លួនឯងបាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំចង់ត្រឡប់មក ពេលដែលលោកស្រីបាននិយាយមុននេះ គឺថាពេលដែលការហើយលោកស្រី និងប្ដីហ្នឹងនៅកន្លែងខុសគ្នា ហើយគេឲ្យជួបគ្នាហ្នឹងគឺថាបីយប់ ក្នុងមួយខែ។ ដូច្នេះខ្ញុំចង់ដឹងថា របបខ្មែរក្រហមចង់បង្កើនប្រជាជនដើម្បីឲ្យមាន ហើយឲ្យប្ដីប្រពន្ធហ្នឹងមានកូន។ អ៊ីចឹងហេតុអីបានគេឲ្យជួបគ្នាតែបីដងក្នុងមួយខែអ៊ីចឹង?

**ឆ៖** នេះក្នុងសំណួរនេះ ខ្ញុំមិនអាចដឹងបាន ព្រោះគោលការណ៍របស់បក្សគេ គេគ្រាន់តែថា ក៏មិនដឹង បានជាគេ ដល់ក្រោយមក គេធ្វើអ៊ីចឹង។ អ៊ីចឹងខ្ញុំអត់ដឹងគោលការណ៍របស់បក្សគេយ៉ាងណាផង។

[១៦:០០:១០]

**ស៖** ប្រហែលជាសំណួរចុងក្រោយហើយ។ ខ្ញុំចង់ដកស្រង់នូវបទសម្ភាសន៍ដែលលោកស្រីបានផ្ដល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/10710 នៅទំព័រចុងក្រោយទាំងបីភាសា។ គឺជាសេចក្ដីសន្និដ្ឋានអំពីរបបនោះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ព្រោះថាអង់គ្លេសបកទៅល្អជាង។

"អំឡុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ គឺថាជាអំឡុងពេលមួយពោរពេញទៅដោយទឹកភ្នែក <ប្ដីមិនបានជួបប្រពន្ធ> ក្មេងៗមិនបានមានឱកាសជួបឪពុកម្ដាយទេ ពួកគេមិនអនុញ្ញាតឲ្យស្គាល់គ្នាទេ ពួកគេត្រូវបានកាត់ផ្ដាច់រាល់មនោសញ្ចេតនាទាំងអស់ ហើយមិនឲ្យស្គាល់គ្នានោះទេ។"

បើតាមការសង្កេតឃើញរបស់លោកស្រីនៅសម័យនោះ ហេតុអ្វីបានជាក្មេងៗមិនត្រូវបានឲ្យជួបម្ដាយនិងស្គាល់ម្ដាយ? ហេតុអីបានជាប្ដីហ្នឹងគេមិនឲ្យជួបប្រពន្ធនោះ? ហេតុអីបានជាគេមិនឲ្យមានមនោសញ្ចេតនាជាមួយនឹងគ្នា គេកាត់ផ្ដាច់ចោលទាំងស្រុងហ្នឹង?

**ឆ៖** កាលនៅក្នុងសម័យហ្នឹង ខ្ញុំឆ្ងល់ដែរ ឲ្យតែក្មេងចាប់ពីអាយុ៦ឆ្នាំ, ៧ឆ្នាំ គេរំសាយចេញពីឪពុកម្ដាយ ទៅដាក់មណ្ឌលកុមារមួយ ឲ្យធ្វើការងារពលកម្មផ្សេង។ ហើយបើសិនជាកូនស្រីក៏ដោយប្រុសក៏ដោយ ឲ្យតែវ័យជំទង់គេឲ្យដាក់ទៅខាងយុវជនហ្នឹង គេហៅកងឈ្លប គេឲ្យទៅមួយកន្លែងផ្សេង ម៉ែនៅផ្សេង ឪនៅផ្សេង គេអត់ឲ្យនៅជាមួយគ្នា ហូបក៏ដោយខ្លួន នៅក៏ដោយខ្លួន។ ក្នុងគោលបំណងរបស់គេ ខ្ញុំមិនដឹងថា គោលបំណងគេធ្វើនេះដើម្បីអ្វី ខ្ញុំអត់ដឹង ព្រោះសម័យហ្នឹងយើងរស់នៅក្រោមការដឹកនាំរបស់គេ គេអត់ដែលប្រាប់ថា អង្គការត្រូវការអី អត់ដឹង ដឹងតែពីការ ដែលការងារដើម្បីកសាងប្រទេស ការងារកសាងប្រទេស។ ប៉ុន្តែមិនដឹងកសាងទៅលើអ្វី បើមនុស្សកើតមកឲ្យហូបមិនគ្រប់គ្រាន់រស់នៅ ធ្វើស្រែបានស្រូវទាំងជង្រុក ឲ្យហូបបបររាវៗ។ បើសិនជាបាយ ដាំបាយទាល់តែលាយដំឡូងលាយពោត លាយចេក បានៗបាយហូប។ ពេលខ្លះ បបរហើយមិនបបរទាំងអង្ករឲ្យហូបទៀត លាយទាំងពោតឲ្យហូបទៀត។ អ៊ីចឹងខ្ញុំមិនយល់ពីគោលការណ៍របស់បក្សសម័យនុ៎ងទេ សូមជម្រាបជូនអង្គប្រជុំ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងចម្លើយរបស់លោកស្រីនេះ នៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ តើកូនៗត្រូវតែស្រឡាញ់អង្គការ ឬក៏ស្រឡាញ់ឪពុកម្ដាយ?

**ឆ៖** ចាស កាលសម័យនុ៎ង គេឲ្យកុមារហ្នឹងគោរពអង្គការវិន័យ អ៊ីចឹងបើតាមយល់ដឹងរបស់ខ្ញុំ គេឲ្យស្រឡាញ់អង្គការជាងឪពុកម្ដាយ គេៗមិនឲ្យស្គាល់ឪពុកម្ដាយ គេឲ្យប្រើកូនឲ្យសម្លាប់ម្ដាយបាន។ អ៊ីចឹងគេឲ្យៗកូនយើងហ្នឹង ទៅស្រឡាញ់អង្គការច្រើនជាងឪពុកម្ដាយ។

[១៦:០៤:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៤ ខែតុលា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ហើយនិងធ្វើសវនាការស្ដាប់សេចក្ដីថ្លែងទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី លើអង្គហេតុបទបញ្ហារៀបអាពាហ៍ពិពាហ៍ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី ព្រាប សុឃឿន សវនាការស្ដាប់សក្ខីកម្មរបស់លោកស្រី ក្នុង

ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទដើមសប្ដាហ៍ក្រោយទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ព្រាប សុឃឿន ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់មកកាន់បន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី២៤ ខែតុលា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*